TRUTH CENTERED TRANSFORMATION

MODULE TWO



## ព្រះរាជ្យរបស់ព្រះជាម្ចាស់

# មគ្គុទ្ទេសក៍សម្រាប់គ្រូបង្រៀន

reconciledworld

This is a training tool designed by Reconciled World. visit TCTprogram.org for more information

# សេចក្តីថ្លែងអំណរគុណ

គំនិតក្នុងការបណ្តុះបណ្តាលនេះគឺមិនមែនជារបស់ខ្ញុំទេ។ ដូចសព្វដង ខ្ញុំកំពុងកសាងនៅលើបទពិសោធន៍របស់អ្នកដែលបានដើរមុនខ្ញុំ។ នៅក្នុងករណីនេះ សម្ភារៈនេះទទួលបានការបំផុសគំនិតពីកិច្ចការរបស់អង្គការ Disciple Nations Alliance (disciplenations.org)។ ក្រុមជំនុំជាច្រើនដែលបានសិក្សា បានជួយសម្រិតសម្រាំងមេរៀនជាច្រើនតាមរយៈមតិយោបល់ ឬបានចាកចេញពីការយល់ច្រឡំរបស់ពួកគេ។ ខ្ញុំសូមថ្លែងអំណរគុណដល់ពួកគេ និងការអត់ធ្មត់ស៊ូទ្រាំដែលពួកគេមានចំពោះខ្ញុំ នៅពេលដែលខ្ញុំរៀនប្រាស្រ័យទាក់ទងនូវសេចក្តីពិត នៅក្នុងរបៀបមួយដែលងាយស្រួលអនុវត្ត។

ភាគច្រើននៃមាតិកានៅក្នុងការបណ្តុះបណ្តាលនេះ ត្រូវបានដកស្រង់ពីគំនិតនៅក្នុងសៀវភៅរបស់លោក បប់ ម៉ូហ្វិត (Bob Moffitt) ដែលមានចំណងជើងថា «ប្រសិនបើព្រះយេស៊ូជាអភិបាលក្រុង (If Jesus was Mayor)»។ គំនិត និងការបង្ហាញនៅក្នុងមេរៀនទី២ ទី៥ និងទី៦ត្រូវបានដកស្រង់ចេញដោយផ្ទាល់នៅក្នុងសៀវភៅនេះ។ មេរៀនទី៣ គុណតម្លៃនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ត្រូវបានយកស្រង់ចេញពីមគ្គុទ្ទេសក៍សិក្សាព្រះគម្ពីរ «ព្រះរាជ្យដែលមិនចេះរង្គើ (God's Unshakable Kingdom)» (ការសិក្សាព្រះគម្ពីរស្តីអំពីរបៀបរស់នៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ - Kingdom Lifestyle Biblie Studies) និពន្ធដោយលោកដារ៉ូ មីលលើរ (Darrow Miller) លោក បប់ ម៉ូហ្វិត (Bob Moffitt) និងលោក ស្កត់ អាលែន (Scott Allen)។

ខណៈដែលខ្ញុំទទួលបានការជំរុញទឹកចិត្តមកពីអ្នកដទៃ សៀវភៅនេះក៏មិនទាន់បានល្អឥតខ្ចោះនៅឡើយដែរ។ សូមអនុញ្ញាតឲ្យខ្ញុំដឹងផង ប្រសិនបើមានការផ្តល់យោបល់ណាមួយ ពីរបៀបដែលយើងអាចបន្តដើម្បីសម្រិតសម្រាំងលើសម្ភារៈទាំងនេះ។

# មាតិកា


**មេរៀនទី១៖ ព្រះរាជ្យរបស់ព្រះជាម្ចាស់ ........ ៥**

តើព្រះរាជ្យរបស់ព្រះជាម្ចាស់ជាអ្វី? ........ ៥

ស្តាប់បង្គាប់គ្រប់អ្វីៗទាំងអស់ ........ ៧

ការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ ........ ៨

**មេរៀនទី២៖ សហគមន៍ក្នុងព្រះរាជ្យរបស់ព្រះ ........ ៩**

ព្រះរាជ្យរបស់ព្រះនៅលើផែនដី ........ ៩

ព្រះជាម្ចាស់ជាព្រះដែលត្រួតត្រាលើសហគមន៍របស់យើង ........ ១០

ព្រះយេស៊ូប្រៀបដូចជាអ្នកដឹកនាំក្នុងសហគមន៍ ........ ១១

ការផ្លាស់ប្រែនៅក្នុងសហគមន៍នៅលើផ្នែកទាំងបួន ........ ១២

**មេរៀនទី៣៖ គុណតម្លៃនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ........ ១៤**

គោលការណ៍គ្រឹះ ........ ១៤

ការយកអ្វីដែលមាននៅក្នុងព្រះគម្ពីរ មកអនុវត្តនៅលើគ្រប់ផ្នែកនៃជីវិតរបស់យើង ........ ១៧

ស្វែងរកគោលការណ៍របស់ព្រះជាម្ចាស់ ........ ១៨

**មេរៀនទី៤៖ គុណតម្លៃនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ និងការងារ ........ ២០**

សេចក្តីផ្តើម ........ ២០

ទស្សនៈស្តីពីការងារតាមបែបព្រះគម្ពីរ ........ ២១

ប្រភេទនៃការងារ ........ ២២

ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះរបៀបដែលយើងធ្វើការ ........ ២៥

**មេរៀនទី៥៖ ការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ ........ ២៧**

ចាប់ផ្តើមចេញពីយើង ........ ២៧

ការផ្លាស់ប្រែសហគមន៍ ........ ២៧

តើយើងផ្លាស់ប្រែសហគមន៍របស់យើងដោយរបៀបណា? ........ ២៩

បងប្រុស ឡារ៉ែនស៍ ........ ៣១

ពីបុគ្គលទៅកាន់គ្រួសារ ទៅកាន់សហគមន៍ ........ ៣២

គ្រួសារ ........ ៣២

សហគមន៍ ........................................................................................................... ៣៣
គំរូផ្សេងទៀតរបស់មនុស្សដែលបានកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ ................................ ៣៦
របៀបក្លាយជាអ្នកកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ ...................................................... ៣៩
**មេរៀនទី៦៖ តួនាទីរបស់ក្រុមជំនុំ ក្នុងការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ ................... ៤១**
សេចក្តីផ្តើម ......................................................................................................... ៤១
បំពាក់បំប៉នបុគ្គលម្នាក់ៗ .......................................................................................... ៤២
ហេតុអ្វីបានជាមនុស្សគ្រប់គ្នា ចាំបាច់ត្រូវបម្រើ? ......................................................... ៤៤
ការផ្លាស់ប្តូរនៅក្នុងក្រុមគ្រួសារ .................................................................................. ៤៥
ការផ្លាស់ប្តូរនៅក្នុងសហគមន៍ ..................................................................................... ៤៦
**មេរៀនទី៧៖ កម្មវិធីផ្លាស់ប្រែសហគមន៍ ដោយផ្តោតលើសេចក្តីពិត .............................. ៥០**
សេចក្តីផ្តើម ......................................................................................................... ៥០
និមិត្តរបស់គម្រោង ................................................................................................ ៥១
វិធីសាស្រ្ត ............................................................................................................ ៥៥
ប្រធានបទសម្រាប់វគ្គបណ្តុះបណ្តាលនាពេលអនាគត ....................................................... ៥៦
**មេរៀនទី៨៖ ជំហានបន្ទាប់ ..................................................................................... ៥៧**
ហេតុផលដែលការរៀបចំផែនការសំខាន់ ......................................................................... ៥៧
ការជួបជុំ .............................................................................................................. ៥៨
សកម្មភាពនៃសេចក្តីស្រលាញ់ ....................................................................................... ៥៩
ជំហាននៃការរៀបចំផែនការ ......................................................................................... ៦០

### មេរៀនទី១

# ព្រះរាជ្យរបស់ព្រះជាម្ចាស់

**គោលបំណង**

១. ព្រះរាជ្យរបស់ព្រះជាម្ចាស់ មានវត្តមាននៅពេលដែលយើងប្រព្រឹត្តតាមសេចក្តីបង្គាប់របស់ព្រះអង្គទាំងស្រុង។
២. ព្រះរាជ្យរបស់ព្រះជាម្ចាស់រីកចម្រើននៅពេលដែល មានមនុស្សកាន់តែច្រើនឡើងៗ ស្តាប់បង្គាប់ព្រះជាម្ចាស់ នៅពេលដែលយើងស្តាប់បង្គាប់ទ្រង់យ៉ាងពេញលេញ។

## តើព្រះរាជ្យរបស់ព្រះជាម្ចាស់ជាអ្វី?

នៅពេលដែលព្រះយេស៊ូយាងមកលើផែនដីនេះ ទ្រង់បានចែកចាយនូវផែនការរបស់ទ្រង់។ ផែនការនេះត្រូវបានលើកឡើង ៩៨ដងនៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី។ ព្រះយេស៊ូបានបន្ទូលថា នេះជាមូលហេតុដែលព្រះបិតាបានចាត់ទ្រង់ឲ្យមក ហើយទ្រង់បានចាត់សាវ័ករបស់ទ្រង់ទៅដើម្បីបង្រៀនអំពីផែនការនោះដែរ។ លោកប៉ូលបាននិយាយអំពីផែនការនោះ ហើយលើកទឹកចិត្តឲ្យយើងអធិស្ឋានអំពីផែនការនោះផងដែរ។

- តើអ្នកដឹងថា ផែនការនោះជាអ្វីដែរឬទេ?

**<u>នៅក្នុងក្រុមតូចៈ</u>**

ចូរអានខគម្ពីរ និងឆ្លើយសំណួរដូចខាងក្រោមៈ

- ម៉ាថាយ ១០៖៥-៨ តើព្រះយេស៊ូបានចាត់ពួកសាវ័ករបស់ទ្រង់ឲ្យបង្រៀនពីអ្វី?
- លូកា ៤៖៤៣ ហេតុអ្វីបានជាព្រះបិតាបានចាត់ព្រះយេស៊ូឲ្យមក?
- កិច្ចការ ១៖៣ តើព្រះយេស៊ូបានបង្រៀនអ្វី នៅក្នុងកំឡុងពេល៤០ថ្ងៃចុងក្រោយនៅលើផែនដីនេះ?
- កិច្ចការ ២៨៖៣០-៣១ តើលោកប៉ូលបានបង្រៀនអំពីអ្វី?

ផែនការរបស់ព្រះជាម្ចាស់គឺ ការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ដូចដែលយើងឃើញនៅក្នុងខគម្ពីរខាងលើ នេះគឺជាគំនិតចម្បង ដែលព្រះយេស៊ូ និងលោកប៉ូលបង្រៀន។ វាគួរតែមានសារៈសំខាន់ជាខ្លាំង

ចំពោះយើងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ មនុស្សយើងជាច្រើនមិនយល់ពីឃ្លាដែលនិយាយថា «ព្រះរាជ្យរបស់ព្រះជាម្ចាស់» ឡើយ។

- សូមបែរទៅរកមនុស្សម្នាក់ទៀត ហើយគិតពីរបៀបដែលនឹងពណ៌នាពីព្រះរាជ្យរបស់ព្រះជាម្ចាស់ នៅកាន់គ្រិស្តបរិស័ទថ្មីម្នាក់។

  សូមចែករំលែកពីចម្លើយនីមួយៗជាមួយនឹងក្រុមទាំងមូល។

ព្រះរាជ្យរបស់ព្រះជាម្ចាស់ មិនមែនពិបាកក្នុងការពន្យល់ទេ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺស្ថិតនៅគ្រប់ទីកន្លែងដែលចាត់ទុកថាព្រះយេស៊ូជាស្តេច និងគោរពតាមក្រឹត្យវិន័យរបស់ទ្រង់។ ដូច្នេះនៅគ្រប់ទីកន្លែងដែលយើងឃើញមនុស្សស្តាប់បង្គាប់ព្រះជាម្ចាស់ និងប្រព្រឹត្តតាមបំណងព្រះហឫទ័យរបស់ទ្រង់ នោះជាផ្នែកតូចមួយនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ជាក់ស្តែងព្រះរាជ្យរបស់ព្រះជាម្ចាស់ នឹងមិនមកដល់ពេញលេញនៅឡើយទេ ទាល់តែព្រះយេស៊ូយាងមកម្តងទៀត ហើយអ្វីៗទាំងអស់ត្រូវបានបង្កើតឲ្យទៅជាថ្មី ដោយគ្មានអំពើបាប។

ដើម្បីជួយយើងឲ្យយល់កាន់តែច្បាស់ សូមគិតពីប្រទេសថៃ។ ព្រះរាជាណាចក្រថៃ៖ គឺពួកគេមានស្តេច ហើយនៅពេលដែលស្តេចមានព្រះបន្ទូល ប្រជាជននៅប្រទេសថៃស្តាប់បង្គាប់តាម។ ទ្រង់មានបន្ទូលថា ទ្រង់ចូលចិត្តពណ៌លឿង ហើយឥឡូវនេះប្រជាជនទាំងអស់ពាក់អាវពណ៌លឿងនៅថ្ងៃច័ន្ទ។ ទ្រង់មានបន្ទូលថា ព្រះមហេសីរបស់ទ្រង់ចូលចិត្តពណ៌ស្វាយ ហើយឥឡូវនេះប្រជាជនជាច្រើនពាក់អាវពណ៌ស្វាយនៅថ្ងៃសុក្រ។ ទ្រង់ត្រូវបានប្រជាជនគោរពស្រលាញ់ និងកោតសរសើរជាខ្លាំង សូម្បីគ្រាន់តែទ្រង់និយាយថា ទ្រង់ពេញព្រះទ័យនឹងពណ៌ណាមួយ ទ្រង់អាចធ្វើឲ្យមានឥទ្ធិពលទៅលើសំលៀកបំពាក់របស់មនុស្ស។

កាលពីរបីឆ្នាំមុន កងយោធាបានចូលកាន់កាប់ និងគ្រប់គ្រងរដ្ឋាភិបាលនៅក្នុងប្រទេសថៃ។ មានការប្រយុទ្ធគ្នាតាមដងផ្លូវ។ អ្នកគាំទ្រខាងរាជរដ្ឋាភិបាល ប្រយុទ្ធគ្នាជាមួយអ្នកគាំទ្រខាងយោធា។ មនុស្សគ្រប់គ្នាពិតជាខ្វល់ខ្វាយខ្លាំងណាស់ ថាវានឹងកាន់តែធ្ងន់ធ្ងរឡើងៗ។ នៅពេលដែលស្តេចមានព្រះបន្ទូល ទ្រង់បានប្រាប់មនុស្សគ្រប់គ្នាឲ្យឈប់ឈ្លោះប្រកែក និងប្រយុទ្ធគ្នា ហើយត្រៀមខ្លួនធ្វើការបោះឆ្នោតវិញ។ រួចការប្រយុទ្ធគ្នាក៏ត្រូវបានបញ្ឈប់ភ្លាមៗ។ គ្មាននរណាម្នាក់ចោទសួរទៅកាន់ស្តេចនោះទេ ពួកគេគ្រាន់តែធ្វើតាមអ្វីដែលស្តេចមានបន្ទូល។ ទោះបីជាពួកគេនៅតែមានអារម្មណ៍ខឹងសម្បារក៏ដោយ ក៏ពួកគេចាត់ទុកថាមិនសំខាន់ដែរ។ ស្តេចមានព្រះបន្ទូល និងការផ្គាប់ព្រះទ័យស្តេចគឺមានសារៈសំខាន់ជាងអារម្មណ៍របស់ពួកគេ។

យើងក៏មានស្តេច ដែលស្តេចរបស់យើងគឺព្រះយេស៊ូ។ តើយើងមិនគួរខិតខំផ្តាប់ព្រះហឫទ័យទ្រង់ និងធ្វើអ្វីៗទាំងអស់តាមដែលទ្រង់មានបន្ទូល ដូចគ្នានឹងប្រជាជនថៃដើម្បីផ្គាប់ព្រះទ័យស្តេចរបស់គេទេឬ? ប្រសិនបើជនជាតិថៃស្រលាញ់ស្តេចរបស់គេជាខ្លាំង សូម្បីតែទ្រង់មានបន្ទូលពីពណ៌ដែលទ្រង់ចូលចិត្ត ក៏ទ្រង់អាចជះឥទ្ធិពលលើរបៀបដែលមនុស្សស្លៀកពាក់បានដែរ តើជីវិតរបស់យើងគួរតែត្រូវបានជះឥទ្ធិពលដោយសេចក្តីស្រលាញ់ដល់ព្រះអម្ចាស់យេស៊ូដែរឬទេ?

**ការពិភាក្សានៅក្នុងក្រុមធំៈ**

- តើយើងគួរតែផ្គាប់ព្រះហឫទ័យស្តេចរបស់យើង ក្នុងការធ្វើគ្រប់អ្វីៗទាំងអស់ដែរឬទេ? បើគួរ ហេតុអ្វី? បើមិនគួរ តើហេតុអ្វី?
- តើមានផ្នែកណានៅក្នុងជីវិតរបស់យើង ដែលយើងគួរតែរៀនស្តាប់បង្គាប់ព្រះជាម្ចាស់ឲ្យកាន់តែប្រសើរ?

## ការស្តាប់បង្គាប់ក្នុងគ្រប់កិច្ចការទាំងអស់

ព្រះជាម្ចាស់ចង់ឲ្យយើងផ្គាប់ចិត្ត និងថ្វាយព្រះកិត្តិយសដល់ទ្រង់គ្រប់ពេលវេលា។ សូមអាន កូឡុស ៣ៈ១៧ និង ១កូរិនថូស ១០ៈ៣១។ នៅក្នុងខគម្ពីរទាំងនេះ ប្រាប់យើងថាអ្វីៗទាំងអស់ដែលយើងធ្វើ យើងគួរតែធ្វើដោយថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។ នៅក្នុងខគម្ពីរទាំងពីរនេះ និយាយពីគំនិតនេះដដែលៗ ពីកិច្ចការដែលយើងធ្វើៈ នៅក្នុងគម្ពីរកូឡុស «ការអ្វីក៏ដោយដែលបងប្អូនធ្វើ ទោះជាពាក្យសម្ដី ឬកាយវិការក្តី ត្រូវធ្វើក្នុងព្រះនាមព្រះអម្ចាស់យេស៊ូទាំងអស់ ទាំងអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតា តាមរយៈព្រះអង្គផង។» ហើយនៅក្នុងគម្ពីរកូរិនថូសវិញ «ដូច្នោះ ទោះបីបងប្អូនពិសាម្ហូបអាហារអ្វី ពិសាភេសជ្ជៈអ្វី ឬទោះបីបងប្អូនធ្វើការអ្វីក៏ដោយ ត្រូវធ្វើទាំងអស់ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។» ប្រសិនបើមានអ្វីមួយត្រូវបានថែងម្តងហើយម្តងទៀតនៅក្នុងព្រះគម្ពីរ វាតែងតែបង្ហាញពីគំនិតដែលសំខាន់។ លោកប៉ូលចង់ឲ្យយើងយល់ច្បាស់ថា យើងគួរតែធ្វើអ្វីៗទាំងអស់ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។

**ការពិភាក្សានៅក្នុងក្រុមធំ**

- តើមានអ្វីខ្លះដែលយើងធ្វើប្រចាំថ្ងៃ? (ចូរសរសេរពីចំណុចទាំងអស់ដាក់នៅលើក្តារខៀន)។

**ការពិភាក្សានៅក្នុងក្រុមតូច**

- តើយើងអាចថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់ នៅពេលដែលយើងធ្វើកិច្ចការទាំងអស់នេះបានដោយរបៀបណា? (មើលពីចំណុចទាំងនោះ ម្តងមួយៗ)

យើងគួរតែយកចិត្តទុកដាក់ក្នុងការស្តាប់បង្គាប់ព្រះអម្ចាស់ព្រះយេស៊ូ និងផ្គាប់ព្រះហឫទ័យទ្រង់។ ព្រះជាម្ចាស់បានធ្វើកិច្ចការជាច្រើនសម្រាប់យើងរួចមកហើយ គឺទ្រង់បញ្ជូនព្រះបុត្រារបស់ទ្រង់មកដើម្បីសុគតសម្រាប់យើង។ នៅពេលដែលយើងគិតពីអំណោយដ៏អស្ចារ្យនេះ យើងគួរតែមានបំណងចិត្តក្នុងការស្តាប់បង្គាប់ និងប្រតិបត្តិតាមក្រឹត្យវិន័យរបស់ទ្រង់។

## ការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់

អាននៅក្នុង ម៉ាថាយ ៦៖៩-១០

- តើព្រះយេស៊ូសុំឲ្យយើងអធិស្ឋានដូចម្តេច?
- តើយើងបានឃើញព្រះរាជ្យរបស់ទ្រង់បានមកដល់ដោយរបៀបណា?

ព្រះជាម្ចាស់ចង់កសាងព្រះរាជ្យរបស់ទ្រង់នៅលើផែនដីនេះ (សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់)។ ហើយព្រះរាជ្យរបស់ទ្រង់ត្រូវបានកសាងនៅលើផែនដីនេះ ដោយសារតែមនុស្សកំពុងធ្វើតាមព្រះហឫទ័យរបស់ទ្រង់ (សូមឲ្យព្រះហឫទ័យរបស់ទ្រង់បានសម្រេច)។

យើងអាចកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់បានដោយរបៀបពីរសំខាន់ៗ។ របៀបទីមួយ គឺតាមការបង្កើនចំនួនមនុស្សនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ ដោយបានឃើញមនុស្សជាច្រើនបានទទួលការសង្គ្រោះ។ របៀបទីពីរ គឺការឃើញបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នឹងបានសម្រេចកាន់តែច្រើនឡើងៗ ដោយសារតែមនុស្ស។ ដូចដែលយើងដឹងថា ព្រះយេស៊ូបានយាងមកដើម្បីផ្សះផ្សាអ្វីៗទាំងអស់ (កូឡូស ១៖១៨-២០)។

ប្រសិនបើយើងចង់ឃើញ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់កាន់តែសម្រេចបានច្រើនឡើងៗ យើងត្រូវតែឃើញមនុស្សជាច្រើនបានទទួលការសង្គ្រោះ និងស្តាប់បង្គាប់តាមព្រះជាម្ចាស់ ហើយយើងចង់ឃើញមនុស្សកាន់តែច្រើនឡើងៗ រស់នៅតាមបំណងព្រះជាម្ចាស់នៅក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់ពួកគេ។

# មេរៀនទី២

# សហគមន៍ក្នុងព្រះរាជ្យរបស់ព្រះ

**គោលបំណង៖**

-  ប្រសិនបើយើងពិតរស់នៅដោយស្ដាប់បង្គាប់មែន យើងគួរតែឃើញសហគមន៍របស់យើងទាំងមូលកាន់តែក្លាយដូចជា ព្រះរាជ្យរបស់ព្រះជាម្ចាស់។

**មេរៀន៖**

២.១ ដំណើររឿងនៅក្នុងសហគមន៍

**សម្ភារៈដែលត្រូវការ៖**

ផ្ទាំងក្រដាសធំមួយចំនួន

កូល័រទៀន ឬហ្វឺត

## ព្រះរាជ្យរបស់ព្រះនៅលើផែនដី

តើអ្នកអាចស្រមៃឃើញថា តើព្រះរាជ្យរបស់ព្រះនៅលើផែនដីនេះមានលក្ខណៈបែបណា? នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី យើងឃើញនូវគំរូជាច្រើនពីរបៀបដែលគ្រិស្តបរិស័ទសម័យដំបូង បានមកជួបជុំគ្នាដើម្បីបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់។

សូមអាននៅក្នុង កិច្ចការ ២៖៤២-៤៧

-  តើអ្នកទើបតែជឿថ្មី បានធ្វើអ្វី?
-  តើវាជាផ្នែករូបកាយ ឬខាងវិញ្ញាណ? (ទាំងពីរ)
-  តើមានលទ្ធផលបែបណា?
    - គ្មាននរណាម្នាក់មានតម្រូវការអ្វីទេ មនុស្សគ្រប់គ្នាចេះអនុគ្រោះគ្នា ហើយមានមនុស្សកាន់តែច្រើនឡើងៗ ក្លាយជាអ្នកជឿ។
-  តើយើងគួរតែឃើញលទ្ធផលបែបណានៅក្នុងសហគមន៍របស់យើង នៅពេលដែលយើងមានការប្រកបគ្នាដូចអ្នកជឿសម័យដំបូងបានធ្វើ?

# ព្រះជាម្ចាស់ជាព្រះដែលត្រួតត្រាលើសហគមន៍របស់យើង

ព្រះជាម្ចាស់ចង់ឃើញសហគមន៍របស់យើង បន្តរីកចម្រើនចម្រើនក្នុងជីវិតតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ទ្រង់មិនគ្រាន់តែចង់ឃើញបំណងព្រះហឫទ័យរបស់ទ្រង់បានសម្រេចតែក្នុងជីវិតរបស់យើងម្នាក់ៗទេ ប៉ុន្តែគឺក្នុងសហគមន៍របស់យើងទាំងមូលដែរ។

**បែងចែកជាក្រុមតូចៗ**

នៅក្នុងក្រុមនីមួយៗ សូមអានដំណើររឿង និងឆ្លើយនូវសំណួរដូចខាងក្រោម។ (មេរៀន ២.១)

មានបុរសម្នាក់មកពីប្រទេសឥណ្ឌា បានមកលេងភូមិមួយជាកន្លែងដែលគាត់ធ្លាប់ធ្វើការ។ គាត់បានសួរទៅកាន់ស្ត្រីៗនៅក្នុងភូមិថា តើសហគមន៍របស់គេនឹងមានលក្ខណៈបែបណា ប្រសិនបើមានព្រះយេស៊ូធ្វើជាមេភូមិ។ អ៊ូម៉ាយ (Umrai) ជាស្ត្រីម្នាក់ដែលនិយាយមិនសំចៃ និងបានពណ៌នាពីភូមិមួយដែលមានការឯកភាពគ្នា និងសាមគ្គីគ្នា។ គាត់បានដឹងថានៅក្នុងភូមិ មនុស្សមានការបែកបាក់គ្នា ហើយការណ៍នេះមិនបានថ្វាយព្រះកិត្តិយសដល់ព្រះយេស៊ូទេ។ គ្រួសារនីមួយៗរស់នៅសម្រាប់តែខ្លួនឯងប៉ុណ្ណោះ។

ដោយសារតែការឆ្លើយតបរបស់នាង ក្រុមស្ត្រីនៅក្នុងភូមិបានបង្កើតគណៈកម្មាធិការសុខភាព និងក្រុមដែលចេះជួយខ្លួនឯង។ មានស្ត្រី១៤នាក់ដែលនៅក្នុងក្រុមចេះជួយខ្លួនឯង ចាប់ផ្តើមជួបជុំគ្នាជាទៀងទាត់ជាមួយនឹងសេចក្តីរំភើបក្រៃលែង។ សមាជិកក្រុមបានប្រមូលប្រាក់បន្តិចបន្តួចពីការសន្សំរៀងៗខ្លួន ដាក់ចូលជាមួយគ្នា ហើយពួកគេអាចចាប់ផ្តើមដោះស្រាយបញ្ហារបស់សហគមន៍ជាមួយគ្នាបាន។ អ៊ូម៉ាយបានក្លាយជាប្រធាននៃគណៈកម្មាធិការនេះ ហើយបានប្រើប្រាស់ព្រះអំណោយទានក្នុងភាពជាអ្នកដឹកនាំរបស់គាត់ ដើម្បីរៀបផែនការ និងរៀបចំនៅក្នុងភូមិ ក្នុងការធ្វើអ្វីៗដូចព្រះយេស៊ូនឹងធ្វើ ប្រសិនបើទ្រង់ជាមេភូមិ។

ស្ត្រីៗដែលមកពីក្រុមសិក្សាព្រះគម្ពី នៅប្រទេសយូកាន់ដា (Uganda) បានសម្រេចចិត្តបម្រើនៅក្នុងភូមិរបស់ពួកគេ ដូចដែលព្រះយេស៊ូនឹងបម្រើ។ ពួកគេបានរៀបនូវគម្រោងដំបូងរបស់ពួកគេដោយប្រុងប្រយ័ត្នះ ប្រមូលសំរាមជុំវិញរង្គសាលនៅក្នុងតំបន់។ មានស្ត្រីពីរនាក់បានចូលទៅក្នុងរង្គសាលដោយចិត្តក្លាហាន។ (ភាគច្រើនស្ត្រីៗចូលក្នុងរង្គសាលគឺជាស្ត្រីពេស្យា) ពួកគេបានសុំការអនុញ្ញាតដើម្បីប្រមូលសំរាម។ ម្ចាស់រង្គសាលបានសើចដោយភ្ញាក់ផ្អើលជាខ្លាំង ប៉ុន្តែគេក៏យល់ព្រម។ ស្ត្រីទាំងនោះបានរៀបចំសហគមន៍ ដោយមានមនុស្សជាច្រើនស្ម័គ្រចិត្តជួយ។ ក្រុមនេះបានជីករណ្តៅពីរះ ទីមួយសម្រាប់ដាក់សំរាមដែលរលួយ និងមួយទៀតដាក់សម្រាមដែលមិនរលួយ។ នៅពេលដែលភ្ញៀវនៅក្នុងរង្គសាល បាន

ឃើញមនុស្សកំពុងតែជួយប្រមូលសម្រាម ពួកគេក៏បានជួយប្រមូលដែរ។ ដើម្បីជាជំនួយដល់សហគមន៍ ម្ចាស់រង្គសាលនោះបានបន្តដើម្បីថែរក្សាតំបន់នោះឲ្យបានស្អាតជានិច្ច។

ដោយមានការជួយជ្រោមជ្រែង ស្ត្រីៗទាំងនោះក៏បានសម្រេចចិត្តសាងសង់ចង្ក្រានប្រើប្រេងចំនួន៩ សម្រាប់ក្រុមគ្រួសារនៅក្នុងតំបន់ និងផ្តល់ជើងសម្រាប់ដាក់ទឹកដល់ប្រជាជនក្រីក្រ។ បន្ទាប់មក ក្រុមសិក្សាព្រះគម្ពីរបានធ្វើគម្រោងធំជាងមុនគឺ ទីផ្សារសហគមន៍។ ស្ត្រីៗនៅក្នុងភូមិត្រូវដើរជាច្រើនម៉ោងដើម្បីជញ្ជូនបន្លែ និងទំនិញផ្សេងៗពីផ្សារដែលនៅឆ្ងាយ។ ប្រសិនបើមានផ្សារនៅក្បែរផ្ទះ នោះនឹងជួយឲ្យពួកគេបង្កើតប្រាក់ចំណូល និងអាចឲ្យពួកគេនៅជិតក្រុមគ្រួសារ សហគមន៍ និងសួនដំណាំរបស់ពួកគេ។ ទោះបីជាមានដីដែលគេបរិច្ចាគឲ្យក៏ដោយ ប៉ុន្តែវាត្រូវចំណាយច្រើនក្នុងការសាងសង់ផ្សារ។ ស្ត្រីៗនៅក្នុងក្រុមសិក្សាព្រះគម្ពីរបានអធិស្ឋាន ហើយកម្មករដែលជួសជុលផ្លូវជាតិនៅជិតនោះ មានចិត្តមកជួយឈូសដីដែលទុកសម្រាប់ធ្វើផ្សារ ដោយមិនបានយកថ្លៃអ្វីឡើយ។ ដោយមានជំនួយមកពីព្រះជាម្ចាស់ ក្រុមតូចស្ត្រីៗគ្រិស្តបរិស័ទនៅតាមជនបទ បានរកឃើញ និងប្រមូលធនធាន សន្សំប្រាក់ ដោះស្រាយទុក្ខលំបាក និងសាងសង់ទីផ្សារសហគមន៍។ ជីវិតខាងវិញ្ញាណរបស់ពួកគេ ក៏បានរីកចម្រើននៅពេលដែលពួកគេបម្រើគ្នាទៅវិញទៅមកក្នុងនាមព្រះយេស៊ូ។

**ការពិភាក្សា**

- តើមានរឿងអ្វីកើតឡើងនៅក្នុងសាច់រឿងនីមួយៗខាងលើនេះ?
- ដោយសារតែប្រជាជននៅក្នុងសាច់រឿងខាងលើ ប្រសិនបើមនុស្សគ្រប់គ្នារស់នៅតាមគោលបំណងរបស់ព្រះយេស៊ូ តើសហគមន៍របស់ពួកគេនឹងកាន់តែប្រសើរឡើងទៅតាមអ្វីដែលព្រះជាម្ចាស់បានរៀបចំដែរឬទេ? ហេតុអ្វី?
- តើមានសកម្មភាពអ្វីខ្លះដែលក្រុមនីមួយៗបានធ្វើនៅក្នុងសាច់រឿងនេះ?
- តើអ្នកអាចធ្វើដូចគ្នាបានដោយរបៀបណា នៅសហគមន៍របស់អ្នក?

## ព្រះយេស៊ូរៀបដូចជាអ្នកដឹកនាំសហគមន៍

**<u>នៅក្នុងក្រុមធំ</u>**

សូមស្រមៃថាព្រះយេស៊ូជាអ្នកដឹកនាំសហគមន៍របស់អ្នក។ តើអ្នកគិតថា មានអ្វីខ្លះដែលទ្រង់ផ្លាស់ប្រែដំបូងគេ?

*(ប្រសិនបើនៅក្នុងក្រុមផ្តោតតែទៅលើការផ្លាស់ប្តូរមេដឹកនាំនយោបាយ សូមរំឭកប្រាប់ពួកគេថាខណៈពេលដែលទ្រង់ស្ថិតនៅលើផែនដី ព្រះយេស៊ូមិនបានផ្លាស់ប្តូរមេដឹកនាំនយោបាយនោះទេ។ សារ៉ៃកទាំង*

*អស់រំពឹងថាទ្រង់នឹងផ្តួលរំលំរចនាសម្ព័ន្ធនយោបាយ ទោះជាយ៉ាងណាក៏ទ្រង់មិនបានប៉ះពាល់នឹងកិច្ចការនោះដែរ។ ទ្រង់បានធ្វើការនៅលើបុគ្គលនីមួយៗដើម្បីផ្លាស់ប្រែពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត។ នៅក្នុងកម្មវិធីនេះ ការយកចិត្តទុករបស់យើងគឺស្ថិតលើការរស់នៅស្របតាមគោលបំណងរបស់ព្រះ និងជួយអ្នកដទៃទៀតឲ្យបានធ្វើដូចគ្នាដែរ។)*

*ប្រសិនបើក្រុមពិបាកក្នុងការគិតរកគំនិត អ្នកអាចប្រើសំណួរមួយចំនួនដូចខាងក្រោមនេះ ដើម្បីជួយឲ្យមានការពិភាក្សា៖*

- តើព្រះយេស៊ូនឹងធ្វើអ្វីចំពោះស្ត្រីមេម៉ាយ និងក្មេងកំព្រា?
- តើទ្រង់នឹងជួយពង្រឹងដល់គ្រួសារយ៉ាងដូចម្តេច?
- តើទ្រង់នឹងលើកកម្ពស់ការផឹកទឹកស្អាត ការស្នាក់នៅនិងអាហារគ្រប់គ្រាន់ សេវាកម្មសុខភាព ប្រព័ន្ធលូទឹកស្អុយនិងសំរាម ហើយនិងផ្លូវថ្នល់សមរម្យដោយរបៀបណា?
- តើគួរនឹងមានកើតឡើងចំពោះការអប់រំដល់ក្មេងៗ និងមនុស្សពេញវ័យ?
- តើទ្រង់នឹងធ្វើអ្វីចំពោះ អ្នកញៀនស្រា គ្រឿងញៀន និងការញៀនអ្វីផ្សេងៗទៀត?
- តើទ្រង់នឹងធ្វើអ្វីចំពោះអាពាហ៍ពិពាហ៍ និងការរំលោភបំពានលើកុមារ?
- តើទ្រង់នឹងធ្វើឲ្យទំនាក់ទំនងរវាងមនុស្សនិងមនុស្ស កាន់តែប្រសើរឡើងយ៉ាងដូចម្តេច?

## ការផ្លាស់ប្រែនៅក្នុងសហគមន៍នៅលើផ្នែកទាំងបួន

តើអ្នកចាំពីផ្នែកទាំងបួនដែលយើងគួរតែរីកចម្រើនដូចដែលព្រះយេស៊ូបានធ្វើដែរឬទេ? (លូកា ២៖៥២)

  - ប្រាជ្ញា រូបកាយ សង្គម និងព្រលឹងវិញ្ញាណ

ព្រះរាជ្យរបស់ព្រះជាម្ចាស់ នាំការផ្លាស់ប្រែនៅលើផ្នែកទាំងបួន។ ប្រសិនបើយើងចង់ឃើញសហគមន៍របស់យើងកាន់តែដូចជាព្រះរាជ្យរបស់ព្រះ នោះយើងត្រូវតែសម្រេចឃើញថាផ្នែកទាំងបួននោះ នឹងផ្លាស់ប្រែសហគមន៍របស់យើង។

**<u>ក្រុមតូច</u>**

សូមចែកសិស្សជាក្រុម ហើយសុំឲ្យពួកគេចំណាយពេលពិភាក្សាពីគំនិតដែលទាក់ទងនឹងលក្ខណៈដែលសហគមន៍គួរតែប្រែក្លាយទៅជា។ ជាពិសេស ចូរសុំឲ្យពួកគេគិតអំពីព្រលឹងវិញ្ញាណ រូបកាយ សង្គម និងប្រាជ្ញា។ សូមប្រាប់ឲ្យពួកគេគូររូប ពីបំណងព្រះហឫទ័យដែលព្រះជាម្ចាស់ចង់មានសម្រាប់សហគមន៍របស់ពួកគេ។

**<u>ពន្យល់</u>**

ព្រះជាម្ចាស់ក៏ចង់ឃើញសហគមន៍របស់យើងបានផ្លាស់ប្រែក្លាយកាន់តែដូចជាព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទ្រង់បានលើកទឹកចិត្តយើងឲ្យអធិស្ឋានថា ព្រះរាជ្យរបស់ព្រះជាម្ចាស់នឹងមកលើផែនដី គឺដូចជានៅស្ថានសួគ៌ និងប្រាប់យើងឲ្យស្វែងរកព្រះរាជ្យរបស់ទ្រង់។

តើអ្នកអាចសម្រៃឃើញ តើវានឹងមានលក្ខណៈបែបណាដើម្បីរស់នៅក្នុងសហគមន៍ដែលមនុស្សគ្រប់គ្នារស់នៅដោយស្ដាប់បង្គាប់តាមព្រះជាម្ចាស់? ជាសហគមន៍ដែលមានគ្រួសារីករាយ អ្នកជិតខាងរួសរាយជួយគ្នាទៅវិញទៅមក និងរស់នៅចុះសម្រុងគ្នា ដោយគ្មានការឈ្លោះប្រកែក ឬទំនាស់ ឬក៏ការមិនស្មោះត្រង់។ តើអ្នកចង់រស់នៅក្នុងសហគមន៍បែបនោះដែរឬទេ?

វិធីសាស្ត្ររបស់ព្រះជាម្ចាស់ដើម្បីនាំព្រះរាជ្យរបស់ទ្រង់មកនោះគឺតាមរយៈយើង។ យើងនឹងរៀនបន្ថែមទៀតពីចំណុចនេះ នៅក្នុងមេរៀនទី៤ ប៉ុន្តែឥឡូវនេះសូមយើងគិតអំពីៈ (មើលលើសំណួរនីមួយៗខាងក្រោមនេះ ហើយទុកពេលឲ្យពួកគេគិតពីចម្លើយ។)

- តើនឹងមានអ្វីកើតឡើង ប្រសិនបើព្រឹកស្អែក ចាប់តាំងពីម៉ោង៦ព្រឹក មនុស្សគ្រប់គ្នានៅក្នុងក្រុមជំនុំចាប់ផ្ដើមប្រព្រឹត្តតាមគោលបំណងរបស់ព្រះជាម្ចាស់?
- តើនឹងមានអ្វីកើតឡើងចំពោះយើងម្នាក់ៗ ប្រសិនបើយើងធ្វើតាមគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ទំនាក់ទំនងរបស់យើង ការយកចិត្តទុកដាក់ចំពោះរូបកាយរបស់យើង និងដំណើរជីវិតរបស់យើងជាមួយព្រះជាម្ចាស់?
- តើនឹងមានអ្វីកើតឡើងនៅក្នុងគ្រួសាររបស់យើង ប្រសិនបើសមាជិកទាំងអស់ធ្វើតាមគោលបំណងរបស់ព្រះជាម្ចាស់ សម្រាប់ទំនាក់ទំនងរបស់ពួកគេទៅវិញទៅមក?
- តើនឹងមានអ្វីកើតឡើងនៅក្នុងក្រុមជំនុំរបស់យើង និងក្រុមជំនុំផ្សេងទៀតនៅក្នុងសហគមន៍របស់យើង ប្រសិនបើអ្នកដឹកនាំ និងសមាជិកគ្រប់រូបពិតជាស្រលាញ់គ្នា បម្រើគ្នា និងយកចិត្តទុកដាក់ចំពោះអ្នកគ្មានអំណាច និងអ្នកក្រីក្រ និងរស់នៅដោយសាមគ្គីគ្នា?

ព្រះជាម្ចាស់បានប្រទានមកឲ្យយើងនូវនិមិត្តដ៏អស្ចារ្យមួយៈ គឺនិមិត្តដែលនិយាយពីព្រះរាជ្យរបស់ព្រះជាម្ចាស់មកលើផែនដីនេះ។ ទ្រង់ចង់ឲ្យយើងធ្វើជាផ្នែកនៃការកសាងព្រះរាជ្យរបស់ទ្រង់នៅលើផែនដីនេះ។ សូមសម្រៃថាពិភពលោកនឹងមានលក្ខណៈបែបណា ប្រសិនបើមនុស្សគ្រប់គ្នាស្ដាប់បង្គាប់ព្រះជាម្ចាស់។ វានឹងដូចជាស្ថានសួគ៌! ទោះបីជាយើងដឹងថា ការនេះនឹងមិនសម្រេចសព្វគ្រប់រហូតទាល់តែព្រះយេស៊ូត្រឡប់មកម្ដងទៀត យើងក៏នៅតែអាចចាប់ផ្ដើមធ្វើការលើនិមិត្តដែលបានមកពីព្រះជាម្ចាស់ដែរ។

ជារៀងរាល់ថ្ងៃយើងគួរតែភ្ញាក់ឡើង ហើយគិតចំពោះខ្លួនឯងថា តើខ្ញុំអាចកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅថ្ងៃនេះដោយរបៀបណា? តើខ្ញុំអាចធ្វើអ្វីបាន ដើម្បីបង្កើនព្រះរាជ្យរបស់ព្រះជាម្ចាស់? តើខ្ញុំអាចរស់នៅដោយស្របទៅតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ដោយរបៀបណា? តើខ្ញុំអាចជួយដល់គ្រួសាររបស់ខ្ញុំឲ្យធ្វើដូចគ្នា បានដោយរបៀបណា?

## មេរៀនទី៣

# គុណតម្លៃនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

**ចំណុចគោល**

- បញ្ហានៅក្នុងសហគមន៍របស់យើង អាចដោះស្រាយបានតាមរយៈការស្តាប់បង្គាប់ព្រះជាម្ចាស់
- ព្រះរាជ្យរបស់ព្រះជាម្ចាស់មក នៅពេលដែលយើងយកព្រះគម្ពីរមកអនុវត្តនៅគ្រប់ផ្នែកនៅក្នុងជីវិតរបស់យើង។
- គោលការណ៍នៅក្នុងព្រះគម្ពីរខុសប្លែកពីគុណតម្លៃនៅក្នុងសហគមន៍របស់យើង។
- យើងអាចស្វែងរកគោលការណ៍នៅក្នុងព្រះគម្ពីរបាន នៅពេលដែលយើងអានព្រះគម្ពីរ។

**មេរៀន**

៣.១ ក្រដាសលំហាត់គុណតម្លៃនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់

រូបភាពជំនួយដល់ការសិក្សា

១. រូបភាពគោលការណ៍គ្រឹះ

## គោលការណ៍គ្រឹះ

---

សូមចាប់ផ្តើមដោយមើលទៅគោលការណ៍គ្រឹះចំនួន៣

**១. ពិភពលោកបានបាក់បែក។ ប្រាជ្ញារបស់មនុស្ស និងធនធានសម្ភារៈមិនអាចផ្សះផ្សាពិភពលោកនេះបានទេ។**

- តើឧទាហរណ៍មួយចំនួននៃផលប៉ះពាល់របស់អំពើបាបនៅក្នុងពិភពលោកនេះ មានអ្វីខ្លះ?

  *ចម្លើយអាចមានដូចជា*

  - ញៀនគ្រឿងស្រវឹង/ ល្បែងស៊ីសង/ ពេស្យាចារ
  - បែកបាក់គ្រួសារ
  - ជម្លោះរវាងមនុស្ស

សូមអាចនូវសាច់រឿងដូចខាងក្រោមៈ

ប្រជាជននៅប្រទេសហៃទី (Haiti) គឺជាឧទាហរណ៍មួយនៃការបែកបាក់ ដែលមិនអាចដោះស្រាយដោយប្រាជ្ញារបស់មនុស្ស និងធនធានបានសម្ភារៈបានឡើយ។ ប្រទេសហៃទីគឺជាប្រទេសក្រីក្រមួយស្ថិតនៅភាគខាងត្បូងនៃអាមេរិកកណ្ដាល។ ប្រទេសនេះមានប្រជាជន៨លាននាក់។ តាំងពីឆ្នាំ១៩៨០ មានកម្មវិធីអន្តរជាតិ កម្មវិធីរបស់រដ្ឋាភិបាល និងសង្គមស៊ីវិលត្រូវបានប្រតិបត្តិការនៅក្នុងប្រទេសនោះ។ ដើម្បីពង្រឹងបញ្ហាផ្នែកសេដ្ឋកិច្ច សង្គម និងព្រលឹងវិញ្ញាណរបស់ប្រទេសហៃទី ប្រាក់រាប់ពាន់លានដុល្លារត្រូវបានចំណាយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏គ្មានអ្វីបានរីកចម្រើនដែរ។ នៅក្នុងឆ្នាំ២០០៤ មានអង្គការអន្តរជាតិ និងរដ្ឋាភិបាលបានឧបត្ថម្ភ១ពាន់លានដុល្លាបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហានៅប្រទេសហៃទី។

ទោះបីជាបានចំណាយអស់ប្រាក់ជាច្រើនយ៉ាងនេះក៏ដោយ ក៏ប្រទេសហៃទីមិនបានផ្លាស់ប្ដូរអ្វីដែរ។ ប្រជាជននៅតែរងទុក្ខដដែល ពួកគេគ្មានសង្ឃឹមនោះទេ។ ៨០%នៃប្រជាជនទាំងអស់រស់នៅក្នុងភាពក្រីក្រ។ នៅប្រទេសនោះគ្មានរោងចក្រ អាជីវកម្មនៅនោះទេ មុខជំនួយទាំងអស់ត្រូវបានបិទទ្វា។ ភាពអត់ការងារធ្វើមានយ៉ាងហោចណាស់ ៧០%។ ជាង១០%នៃកុមារ មិនអាចរស់នៅលើសអាយុ៥ឆ្នាំទេ។ តំបន់អនាធិបតេយ្យមានកំណើនប្រជាជនយ៉ាងច្រើន ដោយគ្មានផ្ទះដែលនឹងនរទេ និងនៅតាមផ្លូវសុទ្ធតែសម្រាម។ ប្រទេសនោះមិនអាចគ្រប់គ្រងលើឧក្រិដ្ឋកម្មបានឡើយ។ នៅតាមដងផ្លូវគឺស្ថិតនៅក្នុងភាពភ័យខ្លាច ហើយមិនមានទឹកសម្រាប់បរិភោគគ្រប់គ្រាន់នោះទេ។ តាមតំបន់ជនបទវិញ មិនមានអ្វីប្រសើរឡើងទ្បើយ។ បន្ទាប់ពីកាប់ព្រៃឈើ និងបង្កឲ្យមានសំណឹកដីអស់ជាច្រើនឆ្នាំ ភូមិនីមួយៗគ្មានអ្វីដើម្បីការពារពួកគេពីខ្យល់ព្យុះត្រូពិក ហើយដីក៏គ្មានជីជាតិដើម្បីដាំដំណាំទៀតដែរ។

ទោះបីជាត្រូវចំណាយអស់ប្រាក់ និងគំនិតរបស់អ្នកជំនាញៗជាច្រើនក្ដី ក៏គ្មានការប្រសើរឡើងអ្វីបន្តិចដែរ។ ធនធានសេដ្ឋកិច្ច ឬគំនិតរបស់អ្នកជំនាញកំពូលក្នុងពិភពលោកក៏មិនបានជួយទឹកដីនៅប្រទេសនោះឲ្យបានប្រសើរឡើងដែរ។

- តើមានស្ថានភាពអ្វីកើតឡើងនៅក្នុងប្រទេសហៃទី?
- តើមានប្រាក់ចំនួនប៉ុន្មានដែលត្រូវបានចំណាយលើប្រទេសហៃទី?
- តើមានផលប៉ះពាល់អ្វីខ្លះ?
- តើហេតុអ្វីបានជាអ្នកគិតថា វាជាផលប៉ះពាល់?

ពិភពលោកត្រូវបានបែកបាក់ ហើយគំនិតល្អៗរបស់យើងមិនអាចដោះស្រាយវាបានទេ។ នៅក្នុងប្រទេសហៃទី ទោះបីជាត្រូវចំណាយអស់ប្រាប់រាប់ពាន់លានដុល្លារ និងអ្នកជំនាញរាប់ពាន់នាក់ ក៏ស្ថានភាពមិនអាចប្រសើរឡើងបានដែរ។ វាជាការពិត មានប្រទេសជាច្រើននៅលើពិភពលោក គឺមិនគ្រាន់តែ

ប្រទេសហៃទីទេ។ បន្ទាប់ពីបានចំណាយប្រាក់អស់ ៥០០០០លានដុល្លានៅក្នុងប្រទេសអាហ្វ្រិក និងបញ្ជូនអ្នកជំនាញរាប់ពាន់អ្នកទៅទីបនោះក្តី ក៏ឥឡូវនេះប្រទេសនោះកាន់តែក្រជាងកាលពី២០ឆ្នាំមុនទៅទៀត។ ប្រាជ្ញា និងធនធានរបស់មនុស្សមិនអាចមានគ្រប់គ្រាន់ដើម្បីព្យាបាលពិភពលោករបស់យើងបានទេ។ យើងត្រូវការអ្វីម្យ៉ាងបន្ថែមទៀត។

## ២. ការប្រោសឲ្យបានជា សម្រាប់ប្រជាជាតិមួយ កើតឡើងតាមរយៈមនុស្ស នៅពេលដែលពួកគេឆ្លើយតបទៅកាន់ព្រះជាម្ចាស់ និងរស់នៅការណែនាំរបស់ទ្រង់

សូមអាន ២របាក្សត្រ ៧៖១៤

- តើនៅក្នុងព្រះគម្ពីរបានចែងថា យើងត្រូវធ្វើអ្វី?
- តើនរណាត្រូវធ្វើវា? គ្រិស្តបរិស័ទ ឬអ្នកមិនមែនគ្រិស្តបរិស័ទ?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងធ្វើកិច្ចការទាំងអស់នេះ?
- តើអ្នកជឿថាខគម្ពីរនេះត្រឹមត្រូវដែរឬទេ?
- តើយើងគួរតែធ្វើអ្វី ប្រសិនបើយើងចង់ឃើញសហគមន៍របស់យើងត្រូវបានប្រោសឲ្យជា?

ព្រះជាម្ចាស់ពិតជាចង់ឃើញសង្គមរបស់យើងបានជាខ្លាំងណាស់។ ព្រះយេស៊ូបានយាងមកដើម្បីផ្សះផ្សារអ្វីៗទាំងអស់។ ទោះបីជាយ៉ាងក៏ដោយ ទ្រង់នៅតែបន្តធ្វើការតាមរយៈយើង។ ប្រសិនបើយើងមិនអធិស្ឋាន តមអាហារ និងដើរតាមបង្គាប់ព្រះជាម្ចាស់នោះទេ នោះនឹងគ្មានការប្រោសឲ្យជាឡើយ! ការព្យាបាលរបស់ព្រះជាម្ចាស់ សម្រាប់សហគមន៍របស់យើងមកនៅពេលដែលយើងធ្វើកិច្ចការទាំងអស់នេះ។ តើអ្នកចង់ឲ្យមានការព្យាបាលលើសហគមន៍របស់អ្នកដែរឬទេ? តើអ្នកមានចិត្តចង់ធ្វើកិច្ចការទាំងអស់នេះដែរឬទេ?

## ៣. ព្រះគម្ពីរប្រាប់យើងពីរបៀបដែលយើងគួររស់នៅ ដើម្បីប្រោសប្រជាជាតិរបស់យើងឲ្យបានជាសះស្បើយ និងកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។

ជួនកាលនៅពេលដែលយើងទិញអ្វីមួយដែលមានតម្លៃ យើងនឹងទទួលបានសៀវភៅណែនាំពីរបៀបប្រើប្រាស់វា។ សៀវភៅណែនាំ ត្រូវបានសរសេរឡើងដោយក្រុមហ៊ុនដែលផលិត និងបង្កើតផលិតផលនោះ។ ពួកគេដឹងពីរបៀបប្រើប្រាស់វា ដើម្បីឲ្យវាដំណើរការបានល្អ និងបានយូរ។ ប្រសិនបើយើងចង់ទទួលបានលទ្ធផលល្អពីផលិតផលថ្មីរបស់យើង យើងគួរតែអានសៀវភៅណែនាំនោះ។

ព្រះជាម្ចាស់ក៏ដូចគ្នាដែរ។ ទ្រង់បានរចនា និងបង្កើតពិភពលោកនេះ។ ទ្រង់បានរចនា និងបង្កើតយើងឡើង។ ទ្រង់ដឹងពីរបៀបដែលធ្វើឲ្យពិភពលោក និងជីវិតរបស់យើងកាន់តែល្អប្រសើឡើង ហើយទ្រង់បាន

សរសេរនូវសៀវភៅណែនាំមួយ ដែលហៅថាព្រះគម្ពីរ។ នៅក្នុងនោះ ទ្រង់ប្រាប់យើងពីរបៀបរស់នៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់យើង។ ព្រះគម្ពីរមានសេចក្តីណែនាំទាំងអស់ និងប្រាជ្ញាដែលយើងត្រូវការដើម្បីប្រោសពិភពលោក និងសហគមន៍ដែលបាក់បែកឲ្យបានជាសះស្បើយវិញ។ យើងត្រូវតែអាន ស្វែងយល់ និងអនុវត្តអ្វីដែលបានសរសេរនៅក្នុងនោះ ចំពោះគ្រប់ផ្នែកនៃជីវិតរបស់យើង ប្រសិនបើយើងចង់បានជីវិតដែលល្អប្រសើរ ហើយប្រសិនបើយើងចង់ឃើញសហគមន៍របស់យើងបានផ្លាស់ប្រែ។

រំឭកគំនិតទាំងបីនោះម្តងទៀត ដោយប្រើកាត។ ត្រូវប្រាកដថាសិស្សយល់ពីកាតនីមួយៗនោះឲ្យបានច្បាស់។

- តើយើងបានរៀនអ្វីខ្លះ ពីរបៀបប្រោសពិភពលោករបស់យើងឲ្យបានជាសះស្បើយ?
- តើយើងអាចរស់នៅដោយស្តាប់បង្គាប់តាមព្រះជាម្ចាស់បានដោយរបៀបណា?
- យើងត្រូវតែអានព្រះគម្ពីរដើម្បីអនុវត្តគោលការណ៍នោះទៅក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតរបស់យើង។
- តើអ្វីដែលព្រះជាម្ចាស់បានសន្យាថានឹងកើតមានឡើង នៅពេលដែលយើងស្តាប់បង្គាប់?

## ការយកអ្វីដែលមាននៅក្នុងព្រះគម្ពីរ មកអនុវត្តនៅលើគ្រប់ផ្នែកនៃជីវិតរបស់យើង

ប្រសិនបើអ្នកអានសាច់រឿងនៃពេលដែលព្រះយេស៊ូរស់នៅលើផែនដី អ្នកនឹងឃើញពួកសាវ័កមានគំនិតខុសៗគ្នាជាច្រើន ពីរបៀបដែលព្រះយេស៊ូគួរតែត្រួតត្រា ជាជាងអ្វីដែលព្រះយេស៊ូបានធ្វើ។

សូមអាន ម៉ាកុស ១០៖៣៥, ៤១-៤៥

- តើលោកយ៉ាកុប និងលោកយ៉ូហានកំពុងតែពិភាក្សារឿងអ្វី?
- តើព្រះយេស៊ូមានព្រះបន្ទូលថា អ្នកដឹកនាំគួរតែប្រព្រឹត្តយ៉ាងដូចម្តេច?

លោកយ៉ាកុប និងលោកយ៉ូហានកំពុងតែគិតពីវប្បធម៌របស់ពួកគេ។ ពួកគេចង់គ្រប់គ្រងលើអ្នកដទៃ ទាំងកំពុងតែស្រមៃពីថ្ងៃដែលពួកគេនឹងក្លាយជាអ្នកដឹកនាំដ៏ល្អ។ ប៉ុន្តែព្រះយេស៊ូបានកែតម្រូវពួកគេ និងប្រាប់ពួកគេថាអ្នកដឹកនាំល្អគួរមានលក្ខណៈបែបណា៖ អ្នកដឹកនាំដ៏ល្អគឺជាអ្នកបម្រើ។

- តើអ្នកគិតថា ជីវិតជាអ្នកបម្រើនៅសម័យនោះមានលក្ខណៈបែបណា?
- តើអ្នកគិតថា ពួកសាវ័កមានអារម្មណ៍យ៉ាងណានៅពេលដែលពួកគេបានឮពីការនេះ?

ភាគច្រើនគឺបែបនេះ៖ របៀបដែលពិភពលោក ឬរបៀបរបស់ប្រពៃណីណាមួយ មិនមែនជារបៀបរបស់ព្រះជាម្ចាស់ទេ។ យើងត្រូវតែស្គាល់មាគ៌ារបស់ព្រះជាម្ចាស់ ប្រសិនបើយើងចង់កសាងព្រះរាជ្យរបស់ព្រះអង្គនៅលើផែនដីនេះ។ ព្រះជាម្ចាស់បានប្រទានមកឲ្យយើងនូវព្រះគម្ពីរ ដែលប្រាប់យើងពីរបៀបដែលយើងគួរតែរស់នៅក្នុងរបៀបដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់។

**<u>នៅក្នុងក្រុមតូច</u>**

ចូរបំពេញនៅក្នុងតារាងខាងក្រោម (មេរៀន ៣.១)។ នៅក្នុងតារាងនីមួយៗ សូមគិតពីរបៀបដែលវប្បធម៌របស់អ្នកនឹងឆ្លើយតប។ រួចមើលនៅក្នុងខគម្ពីរ ទាំងមើលពីអ្វីដែលព្រះគម្ពីរប្រាប់យើងឲ្យធ្វើ។

| **គុណតម្លៃ** | **អត្ថបទគម្ពីរ** | **វប្បធម៌និងប្រពៃណីយើង** | **ព្រះរាជ្យរបស់ព្រះជាម្ចាស់** |
|---|---|---|---|
| តើយើងគួរប្រព្រឹត្តបែបណាក្នុងនាមជាស្វាមី? | កូឡូស ៣៖២១<br>១ពេត្រុស ៣៖៧<br>អេភេសូ ៥៖២៥, ២៨, ៣៣ | | |
| តើយើងគួរប្រព្រឹត្តបែបណាក្នុងនាមជាភរិយា? | លោកុប្បត្តិ ២៖១៨<br>អេភេសូ ៥៖២២-២៤, ៣៣ | | |
| តើយើងគួរតែប្រព្រឹត្តបែបណាចំពោះក្មេងៗ? | ទំនុកតម្កើង ១២៧៖៣<br>អេភេសូ ៦៖៤ | | |
| តើយើងគួរតែប្រព្រឹត្តបែបណាចំពោះមនុស្ស? | ម៉ាថាយ ២២៖៣៦-៤០<br>លូកា ១០៖២៥-៣៧ | | |
| តើយើងគួរប្រព្រឹត្តចំពោះខ្មាំងសត្រូវបែបណា? | លូកា ៦៖២៧-៣១ | | |
| ចិត្តគំនិតរបស់យើងចំពោះការងារ | កូឡូស ៣៖២២-៤៖១<br>អេភេសូ ៦៖៧-៨ | | |
| ចិត្តគំនិតរបស់យើងចំពោះបរិស្ថានដែលនៅជុំវិញខ្លួនយើង | ទំនុកតម្កើង ២៤៖១<br>លោកុប្បត្តិ ១៖២៨-៣០<br>លោកុប្បត្តិ ២៖១៥ | | |
| អ្វីដែលសំខាន់ជាងគេ | ម៉ាថាយ ៦៖២៥-៣៤ | | |

| | | | |
|---|---|---|---|
| | ម៉ាថាយ ២២៖៣៦-៤០ | | |
| ចិត្តគំនិតរបស់យើងចំពោះសេចក្តីស្លាប់ និងជិតស្លាប់ | យ៉ូហាន ១១៖២៥-២៦<br>ហេប្រឺ ២៖១៤-១៥<br>វិវរណៈ ១៖១៧-១៨ | | |
| ចិត្តគំនិតរបស់យើងចំពោះការរងទុក្ខលំបាក | លូកា ៦៖២២-២៣<br>២កូរិនថូស ១៖៨-១១ | | |

## ការស្វែងរកគោលការណ៍របស់ព្រះជាម្ចាស់

នៅពេលដែលអ្នកអានព្រះគម្ពីរនៅក្នុងសប្តាហ៍នេះ អ្នកត្រូវតែចាប់ផ្តើមស្វែងរកគោលការណ៍របស់ព្រះជាម្ចាស់ ដើម្បីអនុវត្តក្នុងជីវិតរបស់អ្នក។ នៅពេលដែលអ្នកអាននៅក្នុងជំពូកណាមួយ ឬអត្ថបទគម្ពីរណាមួយ ចូរសួរខ្លួនឯងនូវសំណួរ៤ ដូចខាងក្រោម៖

១. តើអត្ថបទគម្ពីរនេះបង្រៀនខ្ញុំយ៉ាងណា អំពីព្រះជាម្ចាស់?
២. តើអត្ថបទគម្ពីរនេះបង្រៀនខ្ញុំយ៉ាងណា អំពីរបៀបដែលខ្ញុំគួររស់នៅ?
៣. តើអត្ថបទគម្ពីរនេះបង្រៀនខ្ញុំយ៉ាងណា អំពីរបៀបដែលខ្ញុំគួរតែប្រព្រឹត្តចំពោះអ្នកដទៃ?
៤. តើអត្ថបទគម្ពីរនេះបង្រៀនខ្ញុំយ៉ាងណា អំពីរបៀបដែលខ្ញុំគួរប្រព្រឹត្តចំពោះបរិស្ថានដែលនៅជុំវិញខ្លួន ឬរបៀបដែលខ្ញុំគួរធ្វើការ ឬប្រើប្រាស់លុយកាក់-ល-?

## មេរៀនទី៤

# គុណតម្លៃនៅក្នុងព្រះរាជ្យ របស់ព្រះជាម្ចាស់ និងការងារ

**គោលបំណង**

- ការងារគឺជាផ្នែកដ៏សំខាន់នៅក្នុងជីវិតរបស់យើងម្នាក់ៗ ដែលយើងអាចថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់។ ព្រះគម្ពីរប្រាប់យើងពីរបៀបដែលយើងគួរចេះស្តាប់បង្គាប់ នៅក្នុងការងាររបស់យើង និងរបៀបដែលយើងគួរធ្វើការក្នុងរបៀបដែលថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់។

**មេរៀន**

៤.១ ការណែនាំពីការពិភាក្សានៅក្នុងក្រុមតូច

រូបភាពជំនួយដល់ការសិក្សា

២. ការណែនាំអំពីការងារ រៀបរៀងដោយលោកគ្រូ ចន វ៉េស្លីយ៍ (John Wesley)

## សេចក្តីផ្តើម

**ការពិភាក្សានៅក្នុងក្រុមធំ**

- តើជាទូទៅ មនុស្សចាត់ទុកការងារថាល្អ ឬអាក្រក់?
- តើនៅក្នុងវប្បធម៌របស់អ្នក មានពាក្យសុភាសិត ឬពាក្យស្លោកអ្វីខ្លះពីការងារ?

លោកុប្បត្តិ ១៖២៨

- តើសេចក្តីណែនាំដំបូងរបស់ព្រះជាម្ចាស់ ទៅកាន់អដាំជាអ្វី?
- តើព្រះអង្គមានបន្ទូលប្រាប់អដាំបែបនេះ មុនពេល ឬក្រោយពេលដែលអដាំបានប្រព្រឹត្តអំពើបាបដោយបរិភោគផ្លែឈើ?

លោកុប្បត្តិ ២៖២

- តើព្រះជាម្ចាស់សម្រាកពីអ្វី?

ម៉ាកុស ៦៖១-៣

- តើព្រះយេស៊ូមានការងារជាអ្វី មុនពេលទ្រង់ចាប់ផ្តើមបង្រៀន?

ដូចដែលយើងបានឃើញនៅក្នុងខគម្ពីរទាំងនេះ ព្រះជាម្ចាស់បានធ្វើការ ហើយដោយហេតុថា ទ្រង់បានបង្កើតយើងមកឲ្យមានលក្ខណៈដូចជាព្រះជាម្ចាស់ មានន័យថា ទ្រង់បង្កើតយើងមកដើម្បីធ្វើការ។ មនុស្សបានធ្វើការតាំងពីដើមដំបូង មុនពេលដែលអំពើបាបបានចូលមកដល់ផែនដីនេះ។

យើងបានរៀនអំពីនាងរស់នៅក្នុងគម្ពីរនាងរស់។ នាងកំពុងតែគេចចេញពីគ្រោះទុរ្ភិក្សជាមួយម្តាយក្មេករបស់នាង ដែលជាជនក្រីក្រ។ ពួកគេបានត្រឡប់ទៅស្រុកម៉ូអាប់ ដោយសារតែពួកគេបានឮថាមានស្បៀងអាហារនៅទីនោះ។ នាងរស់បានស្វែងរកការងារនៅក្នុងវាងស្រែរបស់លោកបូអូស ជាអ្នកដែលបានចាប់អារម្មណ៍លើនាង ហើយបានដឹងថានាងបានធ្វើខ្លះសម្រាប់ម្តាយក្មេករបស់នាង។

- តើលោកបូអូស បានធ្វើអ្វីដើម្បីជួយដល់នាងរស់? (នាងរស់ ២៖១៥-១៦)
- តើអ្នកគិតថា ហេតុអ្វីបានជាលោកមិនគ្រាន់តែឲ្យស្រូវសាឡីដល់នាងទៅ?
    - ព្រះជាម្ចាស់បានបង្កើតយើងមកដើម្បីធ្វើការ ហើយដោយហេតុនេះ យើងអាចស្វែងរកសេចក្តីថ្លៃថ្នូរនៅក្នុងការធ្វើការងារ ជាជាងការទទួលជំនួយសប្បុរសធម៌។ ដោយការធ្វើបែបនេះ លោកបូអូសបានផ្តល់នូវសេចក្តីថ្លៃថ្នូរដល់នាង។

# ទស្សនៈស្តីពីការងារតាមបែបព្រះគម្ពីរ

### នៅក្នុងក្រុមតូច (មេរៀនទី៤.១)

តើមានហេតុផលអ្វីខ្លះ ដើម្បីធ្វើការ? ចូរប្រើខគម្ពីរខាងក្រោម ហើយតើមានគំនិតអ្វីខ្លះនៅមេរៀននេះ។

- ១ ថេស្សាឡូនិក ១១-១២
- ១ ធីម៉ូថេ ៥៖៨
- អេភេសូ ៤៖២៨
- ១ កូរិនថូស ១០៖៣១

### ពិភាក្សានៅក្នុងក្រុមធំ

- តើអ្នកគិតថា ព្រះជាម្ចាស់មានគោលបំណងឲ្យយើងធ្វើការដែរឬទេ?
- តើចិត្តគំនិតបែបណាដែលមនុស្សតែងតែមានចំពោះការងារ?
- នៅពេលដែលព្រះជាម្ចាស់កំពុងរៀបចំសួនអេដែន ឬព្រះយេស៊ូធ្វើការជាជាងឈើ តើអ្នកគិតថាទ្រង់មានចិត្តគំនិតបែបណាខ្លះ?
- តើយើងអាចមានចិត្តគំនិតកាន់តែដូចព្រះជាម្ចាស់ បានដោយរបៀបណា?
- តើយើងអាចជួយអ្នកដទៃ ដើម្បីឲ្យមានចិត្តគំនិតកាន់តែដូចព្រះជាម្ចាស់ ចំពោះការងាររបស់ពួកគេបានដោយរបៀបណា?

**ផ្លាស់ខ្លួន**

-  តើអ្នកមានចិត្តគំនិតបែបណាចំពោះការងាររបស់អ្នក?
-  តើអ្នកត្រូវការផ្លាស់ប្តូរចិត្តគំនិតរបស់អ្នកដែរឬទេ?

ចូរអធិស្ឋានថា ព្រះជាម្ចាស់នឹងជួយអ្នកឲ្យមើលឃើញការងាររបស់អ្នក ដូចដែលទ្រង់ទតឃើញ ហើយទ្រង់នឹងផ្តល់ឲ្យមានមានចិត្តគំនិតកាន់តែដូចទ្រង់។

## ប្រភេទនៃការងារ

**ពិភាក្សានៅក្នុងក្រុមធំ**

-  តើអ្នកគិតថាការងារប្រភេទខ្លះ មានសារៈសំខាន់ជាងការងារដទៃឬ? តើអ្វីដែលធ្វើឲ្យវាមានសារៈសំខាន់ជាង?

**នៅក្នុងក្រុមតូច**

-  តើព្រះជាម្ចាស់បានប្រទានការងារអ្វីដល់លោកអដាំ?
-  តើព្រះជាម្ចាស់បានប្រទានការងារអ្វីដល់លោកណូអេ?
-  តើព្រះជាម្ចាស់បានប្រទានការងារអ្វីដល់លោកយ៉ូសែប?
-  តើព្រះជាម្ចាស់បានប្រទានការងារអ្វីដល់លោកដានីយ៉ែល?
-  តើព្រះជាម្ចាស់បានប្រទានការងារអ្វីដល់លោកគេឌាន?
-  តើព្រះជាម្ចាស់បានប្រទានការងារអ្វីដល់លោកម៉ូសេ?
-  តើព្រះជាម្ចាស់បានប្រទានការងារអ្វីដល់ស្តេចដាវីឌ?
-  តើអ្នកគិតថា ព្រះជាម្ចាស់នឹងពេញព្រះហឫទ័យដែរឬទេ ប្រសិនបើមនុស្សទាំងនេះបានដឹកនាំក្រុមជំនុំ ឬបានអធិប្បាយនៅក្នុងក្រុមជំនុំ ជាជាងធ្វើការដែលទ្រង់បានប្រទានមកឲ្យពួកគេ?
-  តើអ្នកគិតថាព្រះជាម្ចាស់ចាត់ទុកមនុស្សទាំងនេះ ថាមានឋានៈទាប ឬមិនសូវសំខាន់ជាងបូជាចារ្យឬ? ឧទាហរណ៍ តើការងាររបស់លោកម៉ូសេ មិនសូវសំខាន់ដូចការងាររបស់លោកអើរ៉ុនឬ?

គំនិតដែលនិយាយថា ការងារមួយចំនួនសំខាន់ជាងការងារមួយចំនួនគឺមិនបានរកឃើញនៅក្នុងព្រះគម្ពីរនោះទេ។ គំនិតនេះគឺជាផ្នែកមួយនៃវប្បធម៌ក្រិក ដែលបានក្លាយជាផ្នែកមួយនៃគំនិតរបស់គ្រិស្តបរិស័ទ រហូតដល់ពេលនៃសម័យកំណែទម្រង់គ្រិស្តសាសនា។ ជនជាតិក្រិកជឿថា ការងារដែលពាក់ព័ន្ធខាងផ្នែក

ព្រលឹងវិញ្ញាណ មានតម្លៃជាង និងថ្វាយកិត្តិយសច្រើនជាងទៅដល់ព្រះជាម្ចាស់ រីឯការងារផ្សេងៗទៀត មិនសូវមានតម្លៃ និងមិនសូវសំខាន់ដល់ព្រះជាម្ចាស់ឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ វាមិនមែនជាសាច់រឿងនៅក្នុងព្រះគម្ពីរនោះទេ។ ព្រះគម្ពីរចាប់ផ្តើមឡើងដោយចែងថា ព្រះជាម្ចាស់បង្កើតសកលលោក និងផែនដី។ នៅក្នុងគម្ពីរលោកុប្បត្តិ ២៖៨ យើងឃើញថា ព្រះជាម្ចាស់បានបង្កើតសួនឧទ្យាន។ ព្រះជាម្ចាស់ជាព្រះដែលយើងថ្វាយបង្គំ និងគោរពស្រលាញ់ បានដាំ និងរៀបចំសួន។ ខណៈពេលដែលយើងធ្វើការនៅក្នុងស្រែចម្ការ ចូរចងចាំថាព្រះជាម្ចាស់ជាអ្នកថែសួនមុនដំបូងគេ។ យើងកំពុងតែធ្វើកិច្ចការដែលទ្រង់បានធ្វើជាច្រើនឆ្នាំមកហើយ។ ព្រះជាម្ចាស់បានត្រាស់ហៅមនុស្សឲ្យបម្រើទ្រង់តាមរបៀបផ្សេងៗ ជាច្រើនលើកជាច្រើនសារ។ ការងារជាគ្រូអធិប្បាយ និងអ្នកផ្សាយដំណឹងល្អគឺជាការងារថ្លៃថ្នូរ ហើយការងារជាអ្នកថែសួន ជាងឈើ ឬជាគ្រូបង្រៀនក៏ដូចគ្នាដែរ។ យើងមិនគ្រាន់តែត្រូវការមនុស្សដើម្បីបង្រៀនយើងខាងព្រលឹងវិញ្ញាណនោះទេ ប៉ុន្តែយើងត្រូវដាំបន្លែបង្ការដើម្បីបរិភោគ សាងសង់ជម្រកដើម្បីរស់នៅ និងបង្រៀនកូនៗរបស់យើង។ លោកគ្រូចន វែស្លីយ៍ (John Wesley) គឺជាគ្រិស្តបរិស័ទដ៏ល្បីម្នាក់ ដែលបានរស់នៅកាលពីជាង ២០០ឆ្នាំមុន បានផ្តល់នូវការណែនាំដូចខាងក្រោមចំពោះការងារ។

ការណែនាំរបស់លោកគ្រូ ចន វែស្លីយ៍ (រូបភាពជំនួយដល់ការសិក្សាទី ២)

- ការងារមិនគួរផ្តល់គ្រោះថ្នាក់ដល់សុខភាពរបស់អ្នក
- ការងារមិនគួរផ្តល់គ្រោះថ្នាក់ដល់ក្រុមគ្រួសាររបស់អ្នក
- ការងារមិនគួរប្រឆាំងនឹងមនសិការរបស់យើង
- ការងារមិនគួរធ្វើឲ្យអ្នកជិតខាងរបស់យើងឈឺចាប់ ឬប៉ះពាល់ដល់សមត្ថភាពរបស់គេក្នុងការស្វែងរកចំណូល
- ការងារមិនគួរធ្វើឲ្យប៉ះពាល់ដល់រូបកាយរបស់អ្នកជិតខាងយើង
- ការងារមិនគួរបង្កឲ្យអ្នកជិតខាងរបស់អ្នកប្រព្រឹត្តអំពើបាបឡើយ។

លោកចន វែស្លីយ៍ ក៏បាននិយាយនៅក្នុងការណែនាំនេះដែរថា យើងគួរតែប្រើប្រាស់ទេពកោសល្យរបស់យើងដើម្បីធ្វើការតាមតែអាចធ្វើបាន។ យើងគួរតែខិតខំព្យាយាមស្វែងរកប្រាក់ឲ្យបានច្រើនតាមដែលយើងអាចធ្វើបាន ធ្វើដូច្នេះយើងនឹងអាចមើលថែរក្សាក្រុមគ្រួសាររបស់យើង សន្សំសម្រាប់អនាគត ថ្វាយ (តង្វាយ) ឲ្យដើម្បីពង្រីកការងាររបស់ព្រះជាម្ចាស់ និងចែកឲ្យជនក្រីក្រ។ នៅក្នុងរបៀបនេះ យើងកំពុងតែលើកព្រះកិត្តិយសដល់ព្រះជាម្ចាស់តាមរយៈការប្រើប្រាស់ទេពកោសល្យ កម្លាំង និងសុខភាពដែលទ្រង់បានប្រទានឲ្យ។

## <u>ការពិភាក្សានៅក្នុងក្រុមធំ</u>

សូមមើលនៅក្នុងការណែនាំរបស់លោក ចន វ៉េស្លីយ៍៖

- ចូរផ្តល់ឧទាហរណ៍នៃចំណុចនីមួយៗខាងលើនោះ
  - *ការងារមិនគួរផ្តល់គ្រោះថ្នាក់ដល់សុខភាពរបស់អ្នក៖ ធ្វើការនៅកន្លែងដែលមានគ្រោះថ្នាក់ ការងារដែលសមរម្យចំពោះសមត្ថភាពរបស់អ្នក ឧ. ប្រើប្រាស់កម្លាំងបាយច្រើនសម្រាប់មនុស្សចាស់។*
  - *ការងារមិនគួរផ្តល់គ្រោះថ្នាក់ដល់ក្រុមគ្រួសាររបស់អ្នក៖ ធ្វើការជាច្រើនម៉ោងដែលធ្វើឲ្យអ្នកមិនបានយកចិត្តទុកដាក់ចំពោះគ្រួសាររបស់អ្នក។ ការងារដែលតម្រូវឲ្យអ្នកទៅឆ្ងាយពីគ្រួសាររបស់អ្នកជាច្រើនថ្ងៃក្នុងមួយខែៗ ដោយពុំសូវបានមើលថែទាំពួកគេ។*
  - *ការងារមិនគួរប្រឆាំងនឹងមនសិការរបស់យើង៖ ការប្លន់ ឬកេងចំណេញលើនរណាម្នាក់។*
  - *ការងារមិនគួរធ្វើឲ្យអ្នកជិតខាងរបស់យើងឈឺចាប់ ឬប៉ះពាល់ដល់សមត្ថភាពរបស់គេក្នុងការស្វែងរកចំណូល៖ ចាប់ផ្តើមអាជីវកម្មនៅជិតនរណាម្នាក់ដោយលក់ក្នុងតម្លៃថោកជាង ដើម្បីអ្នកអាចឈោងចាប់អតិថិជនរបស់ពួកគេ។*
  - *ការងារមិនគួរធ្វើឲ្យប៉ះពាល់ដល់រូបកាយរបស់អ្នកជិតខាងយើង៖ ផលិតគ្រឿងស្រវឹង ឬបារី។*
  - *ការងារមិនគួរបង្កឲ្យអ្នកជិតខាងរបស់អ្នកប្រព្រឹត្តអំពើបាប៖ បើករង្គសាលនៅក្នុងតំបន់។*
- ប្រសិនបើយើងជឿថាការងារទាំងអស់ សុទ្ធតែថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់ តើវាមានផលប៉ះពាល់នៅលើរបៀបដែលអ្នកមើលឃើញការងាររបស់អ្នកយ៉ាងណាខ្លះ?
- តើវាធ្វើះឲ្យជះឥទ្ធិពលដល់របៀបដែលអ្នកធ្វើការងាររបស់អ្នកដែរឬទេ?

## ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ចំពោះរបៀបដែលយើងធ្វើការ

ជារឿយៗគេនិយាយថា បុគ្គលិកគ្រិស្តបរិស័ទជាបុគ្គលិកដែលពិបាកជាងគេ។

- ហេតុអ្វីបានជាអ្នកគិតថា វាអាចជាការពិត?
- តើវាបានកើតឡើងបែបនេះ នៅក្នុងតំបន់របស់អ្នកដែរទេ?
- តើអ្នកគិតថា ព្រះជាម្ចាស់មានអារម្មណ៍បែបណា ពីគ្រិស្តបរិស័ទដែលមានកេរ្តិ៍ឈ្មោះបែបនេះ?

ខណៈពេលដែលព្រះគម្ពីរមិនដែលណែនាំប្រាប់យើងថា ការងារមួយចំនួនមានសារៈសំខាន់ ឬមិនសូវសំខាន់ ក៏ប៉ុន្តែព្រះគម្ពីរមានអ្វីច្រើនត្រូវនិយាយទាក់ទងទៅនឹងរបៀបដែលយើងគួរធ្វើការ។ វាជាផ្នែកសំខាន់សម្រាប់ជីវិតប្រចាំថ្ងៃរបស់យើង។ យើងចំណាយពេលស្ទើរតែពេញមួយថ្ងៃដើម្បីធ្វើការ ដូច្នេះយើងត្រូវតែពិចារណាឲ្យបានប្រុងប្រយ័ត្នពីរបៀបដែលយើងធ្វើការ។

### <u>នៅក្នុងក្រុមតូច</u>

សូមមើលនៅខគម្ពីរខាងក្រោម។ តើនៅក្នុងខគម្ពីរទាំងនេះបង្រៀនយើងយ៉ាងណាអំពីការងារ?
ចូរសង្ខេបជាប្រយោគខ្លីមួយនៅក្នុងក្រុមតូចរបស់អ្នក។

- ២ថេស្សាឡូនិក ៣៖១០-១២
- សុភាសិត ១០៖៤
- សុភាសិត ១៩៖១៥
- សុភាសិត ២១៖២៥

តើអ្នកគិតថា ខគម្ពីរទាំងនេះបង្រៀនយើងអ្វីខ្លះ អំពីរបៀបដែលយើងគួរតែធ្វើការ?

- ១ កូរិនថូស ១០៖៣១ (ថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់)
- កូឡូស ៣៖២៣ (ធ្វើការដូចជាយើងធ្វើសម្រាប់ព្រះជាម្ចាស់)

### ការពិភាក្សានៅក្នុងក្រុមធំ

ស្ទើរតែពេញមួយជីវិតរបស់ព្រះយេស៊ូ ទ្រង់ធ្វើការជា ជាងឈើ។ ចូរស្រមៃថា ប្រសិនបើអ្នកឃើញទ្រង់ជាជាងឈើម្នាក់៖

- តើអ្នកគិតថា គុណភាពការងាររបស់ទ្រង់មានលក្ខណៈបែបណា?

- ចូរសម្រែមើល ថាអ្នកធ្វើការនៅក្នុងរោងជាងជាមួយទ្រង់៖ តើវានឹងមានលក្ខណៈបែបណា ក្នុងការដែលធ្វើការនៅក្នុងរោងជាងជាមួយនឹងព្រះយេស៊ូ?
- តើទ្រង់នឹងធ្វើសកម្មភាពបែបណានៅក្នុងម៉ោងធ្វើការ?
- តើទ្រង់នឹងធ្វើសកម្មភាពអ្វី នៅពេលដែលគ្មាននរណាម្នាក់កំពុងមើលទ្រង់?

នៅក្នុងអំឡុងពេលនៃការសម័យកំណែទម្រង់គ្រិស្តសាសនា មានការផ្លាស់ប្រែមិនគួរឲ្យជឿមួយបានកើតឡើងនៅក្នុងរបៀបដែលគ្រិស្តបរិស័ទបានធ្វើការងាររបស់ពួកគេ នៅពេលដែលមនុស្សចាប់ផ្តើមអានព្រះគម្ពីរជាលើកដំបូង ដើម្បីមើលពីរបៀបដើម្បីអនុវត្តវានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ នៅពេលនោះ ប្រសិនបើជាងឈើម្នាក់ធ្វើតុ គាត់នឹងត្រូវប្រាកដថាផ្ទៃខាងក្រោមនៃតុត្រូវស្អាតដូចផ្ទៃខាងលើ។ គាត់បាននិយាយថា ព្រះជាម្ចាស់អាចមើលឃើញផ្ទៃខាងក្រោមនៃតុបានយ៉ាងងាយស្រួល ដូចជាផ្ទៃខាងលើដែរ ហើយជាងឈើនោះបានធ្វើការដើម្បីផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់។ ផលិតផលដែលបានបង្កើតឡើងនាពេលនោះ សុទ្ធតែជាផលិតផលដែលមានគុណភាពខ្ពស់ជាងគេដែលមិនធ្លាប់មាន។

**<u>នៅក្នុងក្រុមតូច៖ សម្តែងរឿង</u>**

សូមជ្រើសរើសការងារមួយ ហើយបង្កើតជាសាច់រឿង២៖ ទីមួយ សូមបង្ហាញពីមនុស្សម្នាក់ធ្វើការនៅក្នុងរបៀបដែលថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ហើយមួយទៀត បង្ហាញពីមនុស្សម្នាក់ ធ្វើការដោយក្នុងរបៀបដែលមិនបានថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។ ចូរសម្តែងរឿងរបស់អ្នកទៅកាន់សិស្សទាំងអស់។

**<u>បន្ទាប់ពីធ្វើការសម្តែងឈុតនីមួយៗ ចូរពិភាក្សានៅក្នុងក្រុមធំ</u>**

- តើអ្នកបានឃើញមនុស្សថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់តាមរយៈការងាររបស់គេ ដោយរបៀបណាខ្លះ?
- តើអ្នកបានឃើញមនុស្សមិនបានថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់តាមរយៈការងាររបស់គេ ដោយរបៀបណាខ្លះ?
- តើមានគំនិតអ្វីខ្លះទៀត ដែលយើងអាចបន្ថែមនៅលើចំណុចទាំងអស់នេះ?

**<u>ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន</u>**

សូមគិតអំពីការងាររបស់អ្នក។ តើមានវិធីណាខ្លះ ដែលអ្នកអាចថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់តាមរយៈការងាររបស់អ្នក? សូមឲ្យព្រះជាម្ចាស់បង្ហាញអ្នកពីអ្វីមួយ ដែលអ្នកអាចធ្វើបានល្អប្រសើរជាងនេះ ដើម្បីផ្តល់កិត្តិយសដល់ទ្រង់បន្ថែមទៀត។

### មេរៀនទី៥

# ការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់

**គោលបំណង**

- យើងត្រូវតែចេះស្តាប់បង្គាប់ នៅក្នុងជីវិតរបស់យើងម្នាក់ៗ និងជីវិតក្រុមគ្រួសាររបស់យើង ដើម្បីផ្លាស់ប្រែសហគមន៍របស់យើង ឲ្យកាន់តែដូចជាព្រះរាជ្យរបស់ព្រះជាម្ចាស់ឡើង។

**មេរៀន**

៥.១ រឿង «ក្រុមគ្រួសារមួយ ធ្វើឲ្យមានការផ្លាស់ប្រែ»

៥.២ របៀបក្លាយជាអ្នកកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់

រូបភាពជំនួយដល់ការសិក្សា

៣. រូប «ពីបុគ្គលទៅគ្រួសារ»

## ចាប់ផ្តើមចេញពីយើង

នៅក្នុងមេរៀនទី១ យើងបាននិយាយអំពីរបៀបដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើងនូវនិមិត្តដ៏អស្ចារ្យមួយ។

- តើនិមិត្តនោះជាអ្វី?
    - ព្រះរាជ្យរបស់ព្រះជាម្ចាស់
- តើយើងអាចធ្វើអ្វីបាន ដើម្បីចាប់ផ្តើមសម្រេចបាននូវនិមិត្តនេះ?

## ការផ្លាស់ប្រែសហគមន៍

អាននូវដំណើររឿងខាងក្រោម

នៅក្នុងតំបន់មួយ គ្រិស្តបរិស័ទត្រូវបានគេស្គាល់ថាជាមនុស្សដែលក្រជាងគេ។ មានគ្រួសារជាច្រើនរកប្រាក់បានតែបន្តិចបន្តួចប៉ុណ្ណោះ។ ពួកគេត្រូវបានបង្ខំឲ្យដាំដំណាំនៅក្នុងចម្ការដ៏ឆ្ងាយពីផ្ទះរបស់ពួកគេ ហើយពួកគេត្រូវដឹកជញ្ជូនផលដំណាំរបស់ខ្លួនដាក់នៅលើខ្នង ដោយសារតែតាមផ្លូវមិនអំណោយផល មិនអាចដឹកដាក់រថយន្តបាន។ គ្រួសារភាគច្រើនមានអង្ករដែលបានមកពីការប្រមូលផលបានត្រឹមតែ៦ខែប៉ុណ្ណោះក្នុងមួយឆ្នាំ។ ប៉ុន្មានខែដែលនៅសល់ពួកគេដើរស្វែងរកឈើដើម្បីបានម្ហូបអាហារ។

ដោយសារតែពួកគេមិនយល់ពីរបៀបគ្រប់គ្រងចំណូលរបស់ពួកគេ ធ្វើឲ្យគ្រួសារជាប់បំណុលជារៀងរាល់ឆ្នាំ។ នៅក្នុងសហគមន៍គ្មានបន្ទប់ទឹកប្រើប្រាស់ ហើយប្រជាជនតែងតែឈឺ។ ផ្ទះរបស់ពួកគេតូចចង្អៀត ហើយជ្រាបទឹកទៀត។ ក្មេងៗនៅក្នុងសហគមន៍មិនបានទៅរៀនជាទៀងទាត់ទេ។ សម្រាប់ក្រុមជំនុំក៏ដូចគ្នាដែរ គឺតូចហើយក៏បានប្រឈមមុខជាមួយបញ្ហាជាប្រចាំ ដោយសារតែការបៀតបៀន និងការបែកបាក់ផ្ទៃក្នុង។

រីឯអង្គការអភិវឌ្ឍន៍ក៏មិនត្រូវបានអនុញ្ញាតឲ្យធ្វើការជាមួយសហគមន៍ទាំងនេះទៀត ដូច្នេះមើលទៅហាក់ដូចជាមានសង្ឃឹមតិចណាស់សម្រាប់ពួកគេ ក្នុងការគេចផុតពីភាពក្រីក្រ។ ប៉ុន្តែការនេះបានផ្លាស់ប្រែ ចាប់តាំងពីពេលដែលមានប្តីប្រពន្ធមួយគូបានទៅរស់នៅ និងចាប់ផ្តើមបណ្តុះបណ្តាលអ្នកដឹកនាំក្រុមជំនុំនៅក្នុងសហគមន៍ ពីរបៀបដែលពួកគេគួរតែស្រលាញ់អ្នកជិតខាងរបស់គេ និងនិយមន័យពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ថាតើមានអត្ថន័យបែបណា។ ប្តីប្រពន្ធមួយគូនេះមិនបានឲ្យប្រាក់ទៅក្នុងជំនុំក្នុងស្រុកទេ គឺពួកគេគ្រាន់តែបង្រៀនពួកជំនុំពីការស្តាប់បង្គាប់បទបញ្ញត្តិរបស់ព្រះជាម្ចាស់។

ពួកជំនុំបានអនុវត្តអ្វីដែលពួកគេបានរៀន តាមរយៈការជួយអ្នកដទៃនៅក្នុងសហគមន៍របស់ពួកគេ។ ពួកគេបានជួសជុល ពង្រីកផ្លូវថ្នល់។ ពួកគេបានជួយប្រមូលផលគ្នា។ ពួកគេបានសាងសង់ និងជួសជុលផ្ទះ។ ពួកគេបានសាងសង់បង្គន់។ ពួកគេបានបញ្ជូនកូនៗរបស់ពួកគេទៅសាលារៀន។ ហើយពួកគេក៏បានប្រព្រឹត្តល្អប្រសើរជាងមុនចំពោះប្តីប្រពន្ធរបស់ខ្លួន។

ត្រឹមរយៈពេលតែ៥ឆ្នាំប៉ុណ្ណោះ សហគមន៍ទាំងមូលត្រូវបានផ្លាស់ប្រែ! មេដឹកនាំសហគមន៍បានទៅប្រាប់ប្តីប្រពន្ធមួយគូនោះថា ពួកគេលែងក្រទៀតហើយ។ ចំណូលរបស់ពួកគេបានកើនឡើង ហើយពួកគេមានសុខភាពល្អជាងមុន។ កូនៗរបស់ពួកគេក៏បានទៅសាលារៀន។ លើសពីនេះទៅទៀតនោះ ក្រុមជំនុំក៏រីកចម្រើនដែរ! មនុស្សស្ទើរគ្រប់គ្នានៅក្នុងសហគមន៍នេះ បានក្លាយជាគ្រិស្តបរិស័ទ បន្ទាប់ពីបានឃើញរបៀបដែលក្រុមជំនុំបានបង្ហាញសេចក្តីស្រលាញ់ទៅកាន់សហគមន៍។ ពួកជំនុំមានទំនាក់ទំនងល្អជាមន្ត្រីក្នុងតំបន់ ហើយពួកគេក៏លែងត្រូវគេបៀតបៀនទៀតដែរ។

នៅពេលដែលបុគ្គលិករបស់ក្រុមអភិវឌ្ឍគ្រិស្តបរិស័ទមកពីអង្គការផ្សេងទៀត បានមកហើយឃើញពីអ្វីដែលបានកើតឡើងនៅក្នុងសហគមន៍ទាំងនេះ ពួកសឹងតែមិនជឿដោយដំបូងឡើយសហគមន៍នេះពិតជាក្រីក្រខ្លាំងណាស់ ហើយត្រឹមតែ៥ឆ្នាំសោះ។ នៅពេលដែលពួកគេបានយល់ច្បាស់ថា សហគមន៍នេះបានផ្លាស់ប្រែក្នុងរយៈពេលដ៏ខ្លី ពួកគេភ្ញាក់ផ្អើលជាខ្លាំង! ពួកគេចាប់ផ្តើមសួរអ្នកដឹកនាំគ្រប់គ្នាថា «តើអ្នកបានធ្វើអ្វី ដើម្បីនាំការផ្លាស់ប្រែនេះ?»

តើអ្នកដឹងពីអ្វីដែល អ្នកដឹកនាំទាំងនោះបាននិយាយដែរឬទេ? អ្នកដឹកនាំម្នាក់ៗបានផ្ដល់ចម្លើយដូចៗគ្នាថា៖ «យើងស្ដាប់បង្គាប់ព្រះជាម្ចាស់»។

**<u>ពិភាក្សានៅក្នុងក្រុមធំ៖</u>**

- តើអ្វីដែលបានផ្លាស់ប្រែសហគមន៍នេះ?
- តើវាជាផ្នែកខាងវិញ្ញាណ ឬផ្នែករូបកាយ?
- នៅពេលដែលបុគ្គលិកខាងអង្គការអភិវឌ្ឍន៍បានសួរថា «តើអ្វីដែលសហគមន៍បានធ្វើដើម្បីនាំការផ្លាស់ប្រែ» តើអ្នកគិតថាពួកគេរំពឹងថានឹងទទួលបានចម្លើយអ្វី?
- តើមនុស្សគ្រប់គ្នាបានឆ្លើយប្រាប់ពួកគេយ៉ាងដូចម្ដេច?
- តើពួកជំនុំបានធ្វើអ្វីនៅក្នុងសហគមកន៍ ដើម្បីបង្ហាញការស្ដាប់បង្គាប់ទៅកាន់ព្រះជាម្ចាស់?

## តើយើងផ្លាស់ប្រែសហគមន៍របស់យើងដោយរបៀបណា?

ប្រសិនបើយើងចង់ឃើញសហគមន៍របស់យើងផ្លាស់ប្រែ យើងត្រូវតែដើរដោយស្ដាប់បង្គាប់ព្រះជាម្ចាស់។ ជំហានដំបូងនោះគឺ ការផ្លាស់ប្រែជីវិតរបស់យើងផ្ទាល់។ យើងត្រូវតែចាប់ផ្ដើមអនុវត្តគុណតម្លៃក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅកាន់អ្វីៗទាំងអស់ដែលយើងធ្វើ។

ពិភាក្សានៅក្នុងក្រុមធំ៖

- តើជីវិតរបស់យើងនឹងមានលក្ខណៈយ៉ាងដូចម្ដេចទៅ ប្រសិនបើយើងស្ដាប់បង្គាប់តាមបំណងព្រះហឫទ័យព្រះជាម្ចាស់គ្រប់ពេលជារៀងរាល់ថ្ងៃ?
- សូមគិតពីកិច្ចការពីរ បីដែលអ្នកធ្វើនៅក្នុងថ្ងៃធម្មតា។ ប្រសិនបើអ្នកស្ដាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គ្រប់ពេលក្នុងមួយថ្ងៃ តើអ្នកនឹងធ្វើកិច្ចការទាំងអស់នេះដែរឬទេ? តើអ្នកនឹងធ្វើវាខុសប្លែកពីមុនដែរឬទេ?
- តើព្រះជាម្ចាស់នឹងប៉ះពាល់ទៅកាន់កិច្ចការទូទៅដូចជា ការដេក ការបរិភោគ ការរៀបចំអាហារ ការដាំដំណាំ ឬប្រមូលទឹកយ៉ាងដូចម្ដេច? តើព្រះជាម្ចាស់ខ្វល់ខ្វាយពីរបៀបដែលយើងធ្វើកិច្ចការទាំងអស់នេះដែរឬទេ?
- សូមអាន ម៉ាថាយ ៦៖២៥-៣៣
    - តើមនុស្សទាំងនេះខ្វល់ខ្វាយអំពីអ្វី? តើវាទាក់ទងនឹងខាងវិញ្ញាណ ឬជារឿងសាមញ្ញទូទៅ?
    - តើព្រះយេស៊ូឆ្លើយតបយ៉ាងដូចម្ដេច?

- តើអ្នកគិតថាព្រះយេស៊ូ ចង់សំដៅលើអ្វី? តើយើងអាចស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងអ្វីៗគ្រប់យ៉ាងបានដូចម្ដេចទៅ?

ខនេះអាចត្រូវបានយល់ច្រឡំក្នុងការគិតថា នៅពេលដែលមនុស្សបានមកទូលប្រាប់ទ្រង់ថា ពួកគេបានព្រួយបារម្ភពីអ្វីដើម្បីបរិភោគ និងផឹក ចម្លើយរបស់ទ្រង់នោះគឺ «ស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុន»។ តើទ្រង់ចង់សំដៅលើអ្វី? តើទ្រង់ចង់មានន័យថា យើងមិនគួរគិតអំពីបញ្ហាទាំងអស់នេះ ប៉ុន្តែចំណាយពេលទាំងប៉ុន្មានធ្វើកិច្ចការខាងវិញ្ញាណដូចជាអធិស្ឋាន មែនដែរឬទេ? ប្រសិនបើយើងធ្វើដូច្នេះនោះជីវិតយើងនឹងប្រែជាជីវិតល្អឥតខ្ចោះឬ?

គួរឲ្យរីករាយ ដែលមានមនុស្សម្នាក់បានរស់នៅក្នុងជីវិតដ៏ល្អឥតខ្ចោះ និងព្រមទាំងបានធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅគ្រប់ពេលទាំងអស់នោះគឺ ព្រះយេស៊ូ (យ៉ូហាន ១៤៖៣១)។ យើងអាចសម្លឹងមើលទៅជីវិតរបស់ទ្រង់ ដើម្បីមើលឃើញពីអត្ថន័យនៃការស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់ជាមុន។ សូមអាននូវខគម្ពីរទាំងនេះ។ តើខទាំងនេះបង្រៀនយើងអ្វីខ្លះ អំពីអ្វីដែលព្រះយេស៊ូបានធ្វើ?

- ម៉ាកុស ៦៖៣ - ព្រះយេស៊ូជាជាងឈើរហូតដល់អាយុ៣០ឆ្នាំ។ នៅក្នុងសហគមន៍របស់ទ្រង់ ទ្រង់មិនត្រូវបានគេមើលឃើញថាជាមេដឹកនាំខាងវិញ្ញាណទេ ប៉ុន្តែជាមនុស្សធម្មតាម្នាក់។ នៅពេលដែលព្រះយេស៊ូជាជាងឈើ ទ្រង់នៅតែរស់នៅក្នុងជីវិតដ៏ល្អឥតខ្ចោះ។ មិនដែលមានម្ដងណា ក្នុងជីវិតរបស់ព្រះយេស៊ូដែលទ្រង់នៅឆ្ងាយពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជិវិតរបស់ទ្រង់ឡើយ។ ចាប់ពីអាយុ១០ឆ្នាំ រហូតដល់៣០ឆ្នាំ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ព្រះយេស៊ូនោះ គឺឲ្យទ្រង់ធ្វើជំនួញតាមគ្រួសាររបស់ទ្រង់ដែលជាជាងឈើ។
- យ៉ូហាន ២១៖៩-១៤ - ព្រះយេស៊ូបានចម្អិនម្ហូបមួយពេលសម្រាប់សាវ័ករបស់ទ្រង់។
- ម៉ាកុស ៤៖៣៨ - នៅពេលដែលព្រះយេស៊ូហត់នឿយ ទ្រង់បានសម្រាក។
- យ៉ូហាន ២៖១-១ - ព្រះយេស៊ូបានចូលរួមពិធីមង្គលការ។
- តើកិច្ចការខាងលើនេះ ជាកិច្ចការខាងវិញ្ញាណ ឬក៏ជាអ្វីដែលសាមញ្ញ?
    - កិច្ចការទាំងនេះ ជាអ្វីដែលសាមញ្ញ ហើយនៅមានកិច្ចការផ្សេងទៀតដែលទ្រង់បានចំណាយពេលពេញមួយថ្ងៃដើម្បីធ្វើវា។ ខណៈដែលទ្រង់ស្វែងកំពុងតែរកព្រះរាជ្យរបស់ព្រះជាម្ចាស់នៅគ្រប់ពេលវេលា ទ្រង់នៅតែចំណាយពេលពេញមួយថ្ងៃដើម្បីធ្វើកិច្ចការសាមញ្ញៗ។ នៅក្នុងពេលទាំងអស់នោះ ទ្រង់មិនដែលនៅឆ្ងាយពីបំណងរបស់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ឡើយ ប៉ុន្តែទ្រង់បានបម្រើព្រះជាម្ចាស់ជាស្រុង។

សូមអាន ម៉ាកុស ១៖២១-៣៤

-  តើមានសកម្មភាពអ្វីខ្លះដែលព្រះយេស៊ូបានធ្វើនៅក្នុងថ្ងៃនេះ?

នៅក្នុងខគម្ពីរទាំងនេះ យើងឃើញមានថ្ងៃសប្ប័ទនៅក្នុងជីវិតរបស់ព្រះយេស៊ូ។ ទ្រង់បានចំណាយពេលនៅពេលព្រឹកបង្រៀននៅក្នុងសាលាប្រជុំ។ បន្ទាប់មកទ្រង់បានយាងត្រឡប់ទៅផ្ទះរបស់លោកពេត្រុស ហើយប្រោសម្ដាយរបស់គាត់ឲ្យបានជាសះស្បើយ ទ្រង់សម្រាកនៅពេលរសៀល ខណៈដែលម្ដាយរបស់លោកពេត្រុសបម្រើទ្រង់ និងគាត់។ នៅពេលល្ងាច ទ្រង់បានចេញទៅក្រៅ ហើយចំណាយពេលបម្រើអ្នកដទៃផ្សេងទៀត តាមរយៈការប្រោសឲ្យបានជាពីជំងឺ។

-  ចុះបើប្រៀបធៀបជាមួយយើង តើយើងបានចំណាយពេលថ្ងៃអាទិត្យរបស់យើងយ៉ាងដូចម្ដេចដែរ? តើមានអ្វីខ្លះដែលខុសគ្នា និងអ្វីខ្លះដែលដូចគ្នា?

ដូចដែលយើងបានឃើញ សម្រាប់រយៈពេលប៉ុន្មានឆ្នាំដំបូងនៃជីវិតរបស់ព្រះយេស៊ូ គឺទ្រង់ជាជាងឈើ។ ទោះបីជានៅពេលដែលទ្រង់ចាប់ផ្ដើមបង្រៀនអ្នកដទៃ ទ្រង់នៅតែមិនបានចំណាយពេលគ្រប់ម៉ោងដើម្បីអធិស្ឋាន និងបង្រៀននោះទេ។ ទ្រង់បានបរិភោគជាមួយមិត្តភក្តិ ទ្រង់បម្រើមិត្តភក្តិ ទ្រង់បានសម្រាក និងសម្រាក។ អ្វីគ្រប់យ៉ាងដែលទ្រង់បានធ្វើ ពិតជាល្អឥតខ្ចោះដោយយោងទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ទោះបីជាទ្រង់បានធ្វើកិច្ចការសាមញ្ញក៏ដោយ ក៏ទ្រង់បានធ្វើអ្វីដែលព្រះជាម្ចាស់ចង់ឲ្យទ្រង់ធ្វើដែរ។

## បងប្រុស ឡារ៉ែនស៍ ( Lawrence )

នៅក្នុងឆ្នាំ១៦០៨ មានបុរសម្នាក់បានចាប់កំណើតនៅប្រទេសបារាំង។ គាត់បានក្លាយជាគ្រិស្តបរិស័ទទៅអាយុ១៨ឆ្នាំ។ នៅអាយុ២០គាត់បានសម្រេចចិត្តថ្វាយជីវិតរបស់គាត់ទៅកាន់ព្រះជាម្ចាស់ទាំងស្រុង។ គាត់បានទៅព្រះវិហារ ដែលគេបានដាក់ឈ្មោះឲ្យគាត់ថា បងប្រុស ឡារ៉ែនស៍។ គាត់ធ្លាប់សម្រេចថា តាមរយៈការរស់នៅក្នុងព្រះវិហារ គាត់នឹងចំណាយពេលរបស់គាត់ទាំងអស់នៅសាលជំនុំអធិស្ឋាន និងថ្វាយបង្គំព្រះជាម្ចាស់។ ទោះបីជាយ៉ាងនោះក៏ដោយ គាត់ត្រូវបានចាត់ឲ្យទៅធ្វើកិច្ចការនៅក្នុងផ្ទះបាយ។ អស់រយៈពេល១០ឆ្នាំ នៅក្នុងផ្ទះបាយធ្វើឲ្យគាត់ស្អប់វាជាខ្លាំង ខណៈពេលដែលអ្នកផ្សេងទៀតនៅសាលជំនុំ។ គាត់អន់ចិត្តខ្លាំងណាស់ ដែលត្រូវបានទទួលការងារគ្មានប្រយោជន៍បែបនេះ។

**<u>ការពិភាក្សានៅក្នុងក្រុមតូច</u>**

-  ប្រសិនបើអ្នកបានជួបជាមួយបងប្រុស ឡារ៉ែនស៍នៅក្នុងកំឡុងពេល១០ឆ្នាំនោះ តើអ្នកនឹងផ្ដល់យោបល់អ្វីទៅកាន់គាត់?

- តើអ្នកគិតថាការងាររបស់បងប្រុស ឡារ៉ែនស៍ នៅក្នុងផ្ទះបាយជាការងារមិនសូវសំខាន់ដូចគ្រូអាចារ្យនៅក្នុងសាលជំនុំដែរឬទេ?
- ចូរអាននៅក្នុងខគម្ពីរខាងក្រោយ ហើយគិតពីរបៀបដែលខគម្ពីរទាំងនេះអាចឆ្លើយតបចំពោះស្ថានភាពនេះ៖
    - ម៉ាថាយ ២៥៖៤០ (៣៤-៤០)
    - ១កូរិនថូស ១០៖៣១
    - ១កូរិនថូស ១៣៖១-៣

ដប់ឆ្នាំក្រោយមក បងប្រុស ឡារ៉ែសន៍ បានដឹងថាគាត់អាចបម្រើ និងថ្វាយបង្គំព្រះជាម្ចាស់មិនថានៅកន្លែងណាក៏ដោយ។ គាត់នៅតែបន្តការងារនៅក្នុងផ្ទះបាយ ប៉ុន្តែឥឡូវនេះគាត់មានអារម្មណ៍នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ច្រើនជាងមុននៅទីនោះ គឺដូចដែលគាត់កំពុងតែថ្វាយបង្គំនៅសាលជំនុំដែរ។

នៅក្នុងព្រះគម្ពីរបង្ហាញយើងថា ព្រះជាម្ចាស់យកព្រះទ័យទុកដាក់ខ្លាំង នៅលើរបៀបដែលយើងធ្វើកិច្ចការជាងកិច្ចការអ្វីដែលយើងធ្វើទៅទៀត។ អ្វីដែលសំខាន់នោះគឺ យើងធ្វើកិច្ចការដែលមិនប្រព្រឹត្តបាប។ អ្វីៗទាំងអស់ដែលយើងធ្វើ ត្រូវបានប្រើប្រាស់ដើម្បីថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់បាន។

## ពីបុគ្គលទៅកាន់គ្រួសារ ទៅកាន់សហគមន៍

ការផ្លាស់ប្តូរចាប់ផ្តើមចេញពីបុគ្គល ហើយពង្រីកទៅជាគ្រួសារ បន្ទាប់មកសហគមន៍ ហើយទៅកាន់ប្រទេសជាតិតែម្តង។ វាជាដំណើរការមួយ។ នៅពេលដែលបុគ្គលម្នាក់ៗ និងគ្រួសារនានាស្តាប់បង្គាប់ព្រះជាម្ចាស់ វានឹងធ្វើឲ្យជះឥទ្ធិពលដល់សហគមន៍របស់ពួកគេ។ នៅពេលដែលសហគមន៍រស់នៅដោយស្តាប់បង្គាប់ វានឹងជះឥទ្ធិពលទៅសហគមន៍ដែលនៅជុំវិញពួកគេ ហើយបន្តទៅពាសពេញប្រទេសជាតិ។




## គ្រួសារ

សូមអានខគម្ពីរខាងក្រោម៖

- ទុតិយកថា ៦៖៧

- ទីតុស ២៖៣-៤
- ១ធីម៉ូថេ ៣៖១២
- ទីតុស ១៖៦
- តើយើងគួរតែជះឥទ្ធិពលបែបណាទៅកាន់គ្រួសាររបស់យើង?
  *យើងត្រូវតែបង្រៀន និងធ្វើជាគំរូល្អសម្រាប់ពួកគេ។*

សូមអាន លូកា ២៖៥២

- តើយើងបានរៀនពីខគម្ពីរនេះ នៅក្នុងមេរៀនមួយណានៅក្នុងវគ្គបណ្តុះបណ្តាលលើកមុន?

  *យើងត្រូវតែរីកចម្រើននៅគ្រប់ផ្នែកទាំង៤។*

<u>**នៅក្នុងក្រុមតូច**</u>

លើកឡើងនូវរបៀបពីរ បីខុសៗគ្នា ដើម្បីជួយក្រុមគ្រួសាររបស់អ្នកឲ្យរីកចម្រើននៅក្នុងផ្នែកទាំងបួននោះ តាមដែលអាចធ្វើបាន។ សូមឲ្យមនុស្សម្នាក់ៗជ្រើសរើសអ្វីមួយ ដែលពួកគេនឹងយកទៅអនុវត្តក្នុងចំណុចនីមួយៗ (សង្គម វិញ្ញាណ រូបកាយ និងប្រាជ្ញា) នៅសប្តាហ៍នេះ។

## សហគមន៍

នៅពេលដែលក្រុមគ្រួសារត្រូវបានផ្លាស់ប្រែ នោះពួកគេនឹងមានបំណងចិត្តដើម្បីឃើញសហគមន៍ពួកគេផ្លាស់ប្រែដែរ។ ចូរអានរឿងអំពីបុរសម្នាក់ និងគ្រួសាររបស់គាត់ដែលបានផ្លាស់ប្រែសហគមន៍។ (សម្រាប់សិស្សដែលចេះអក្សរ សូមឲ្យមេរៀន ៥.១ ហើយសុំឲ្យពួកគេអានដោយខ្លួនឯង។)

នេះជាសាច់រឿងពិតដែលនិយាយពីបុរសម្នាក់ និងគ្រួសាររបស់គេបានផ្លាស់ទីលំនៅទៅតំបន់មួយដែលគ្មានគ្រិស្តបរិស័ទដើម្បីទៅប្រាប់ពួកគេអំពីព្រះគ្រិស្តនៅក្នុងតំបន់នោះ។ គាត់ចង់ឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ត្រូវបានកសាង ហើយស្តារជីវិតមនុស្សនៅគ្រប់ផ្នែកទាំងអស់ដូចជា វិញ្ញាណ សង្គម ប្រាជ្ញា និងរូបកាយ។

### គ្រិស្តបរិស័ទមួយគ្រួសារធ្វើឲ្យមានការខុសប្លែកកើតឡើង

កាលពីបួនឆ្នាំមុននៅពេលដែលអ្នកផ្សាយដំណឹងល្អបានផ្លាស់ទីលំនៅ មករស់នៅក្នុងតំបន់នេះ ដែលសហគមន៍ទាំងមូលកាន់សាសនាហិណ្ឌូ។ ភូមិនេះមានទីតាំងស្ថិតនៅក្នុងភ្នំហិម៉ាឡៃ មានកម្ពស់ ៣០៥ម៉ែត្រ ពីកម្រិតទឹកសមុទ្រ។ ប្រហែលជា២ ឬ៣គីឡូម៉ែតឆ្ងាយពីភូមិនោះ ជាចម្ការតែមួយកន្លែង។

ចម្ការនេះបានផ្តល់ការងារសម្រាប់មនុស្សនៅក្នុងភូមិនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រាក់ឈ្នួលមានកម្រិតទាបនៅឡើយ ដែលធ្វើឲ្យមនុស្សជួបការលំបាកក្នុងការរស់នៅជាមួយការងារមួយនោះ។

នៅក្នុងភូមិនេះ មានប្រហែល២៥គ្រួសារស្ថិតនៅក្នុងស្ថានភាពលំបាក ដែលមានផ្ទះសង់ពីឈើ និងដំបូលស័ង្កសី។ នៅក្នុងភូមិនោះគ្មានបង្គន់ប្រើប្រាស់ទេ។ ដោយសារតែវាខ្ពស់ពេក ហើយថែមទាំងត្រជាក់ផង រីឯក្មេងៗវិញដើរដោយជើងទទេ ថែមទាំងហើមពោះទៀតផង។

ផ្ទះនីមួយៗសង់នៅលើដីឡូត៍តូចមួយ។ ពួកគេចម្អិនអាហារនៅក្នុងខ្ទមតូចមួយ ដាច់ដោយឡែកពេញទៅដោយផ្សែង នៅលើចង្ក្រានចំហរដែលមានជើង៣ និងឆ្នាំង។ នៅទីនោះមានមាន់ពីរបី រត់ចុះឡើងពេញផ្ទះ និងមានសភាពស្មោកគ្រោក។

សាលាដែលនៅជិតជាងគេបំផុតមានចំងាយពីរគីឡូម៉ែត្រ។ វាឆ្ងាយខ្លាំងណាស់សម្រាប់ក្មេងៗដើរទៅរៀនជារៀងរាល់ថ្ងៃ ហើយពួកគេក៏ត្រូវធ្វើការនៅផ្ទះដែរ។ ដូច្នេះហើយ បានជាក្មេងៗភាគច្រើនមិនបានទៅរៀននៅសាលា។ មានមនុស្សពេញវ័យជាច្រើនមិនចេះសរសេរ និងអានអក្សរទេ ដូច្នេះធ្វើឲ្យមនុស្សនៅក្នុងភូមិផ្សេងបោកពួកគេយកផលប្រយោជន៍តាមដែលអាចធ្វើបាន។

នៅទីនោះមានសួនដំណាំតិចតួចណាស់ ដោយសារតែអាងទឹកដែលជិតបំផុតមានចំងាយ២គីឡូម៉ែត្រ។ វាពិតជាពិបាកខ្លាំងណាស់ ក្នុងការដឹកជញ្ជូនទឹកគ្រប់គ្រាន់សម្រាប់ផឹក និងប្រើប្រាស់ ចុះទំរាំតែការស្រោចស្រពសួនដំណាំទៀត។ កាលពីមុនធ្លាប់មានបំពង់បង្ហូរទឹកចេញពីអាងស្តុកទឹកនោះដែរ ប៉ុន្តែវាលែងដំណើរការ ហើយពួកគេក៏មិនបានយកវាទៅជួសជុលដែរ។

ភ្លៀងក៏មិនសូវមានច្រើនដែរ លើកលែងតែរដូវបង្កបង្កើនផលមួយរដូវ ជាពេលដែលមានភ្លៀងធ្លាក់គ្រប់ល្មមសម្រាប់ដំណាំស្រូវរបស់ពួកគេ។ នៅទីនោះគ្មានដី ឬពេលវេលាគ្រប់គ្រាន់សម្រាប់ដាំបន្លែទេ។ ប្រសិនបើពួកគេមានសំណាងល្អ នោះពួកគេនឹងប្រមូលផលគ្រប់គ្រាន់ ដើម្បីឲ្យពួកគេអាចរស់បានរហូតដល់ការប្រមូលផលលើកក្រោយទៀត។

ប្រជាជនទាំងអស់កាន់សាសនាហិណ្ឌូ ដូច្នេះពួកគេគោរព និងថ្វាយបង្គំព្រះជាច្រើន។ មានព្រះជាងមួយលាន ដែលសាសនាហិណ្ឌូត្រូវបន់ស្រន់ និងថ្វាយបង្គំ។ នៅក្នុងភូមិនោះមានរូបសំណាកតូចៗជាច្រើនដែលតំណាងឲ្យព្រះនៅក្នុងសាសនាហិណ្ឌូ។ គ្រប់ពេលដែលពួកគេបរិភោគ ពួកគេតែងតែទម្លាក់ម្ហូបអាហារខ្លះទៅលើដី សម្រាប់វិញ្ញាណដែលវង្វេងតែលតោល។

នៅទីនោះមានវិញ្ញាណនៃការបរាជ័យ និងអស់សង្ឃឹម។ ក្តីសង្ឃឹមតែមួយគត់របស់ពួកគេគឺនៅជាតិក្រោយ ពួកគេចាប់ជាតិទៅក្នុងស្ថានភាពដែលល្អប្រសើរជាងមុន។ ប៉ុន្តែ វាក៏មានឱកាសមួយទៀតនោះគឺ

ថា ប្រសិនបើពួកគេធ្វើឲ្យព្រះរបស់ពួកគេមិនសប្បាយចិត្ត ពួកគេនឹងអាចចាប់ជាតិទៅជាកណ្ដុរ ឬក៏ជាឆ្កែ។ ពួកគេមានអារម្មណ៍ថាជាប់គាំង គ្មានផ្លូវដែលអាចគេចចេញបាន ហើយគ្មានផ្លូវដែលល្អប្រសើរសម្រាប់ពួកគេឡើយ។

លោក ឡេបឆា (Lepcha) អ្នកជាផ្សាយដំណឹងល្អដែលបានផ្លាស់ទីលំនៅមកតំបន់នេះ។ គាត់បានសិក្សាអំពីមូលដ្ឋាននៃការជួយអ្នកដទៃឲ្យមានសុខភាពល្អប្រសើរឡើងក្នុងវគ្គសិក្សារយៈពេលមួយខែ។ នៅពេលដែលគាត់បញ្ចប់វគ្គសិក្សានោះ គាត់និងក្រុមគ្រួសារបានផ្លាស់ទីលំនៅទៅភូមិមួយទៀត ដើម្បីឲ្យពួកគេបានរស់នៅដោយជួយអ្នកជិតខាង ដោយចែករំលែកនូវអ្វីដែលពួកគេបានរៀន។ ពួកគេរស់នៅក្នុងបរិស្ថានដែលមានអនាម័យ ដែលមានផ្ទះបាយ មានចង្រ្កាននៅកន្លែងខ្ពស់ ដើម្បីចម្អិនម្ហូបដោយប្រើអុសតិច។ ពួកគេមានទ្រុងតូចមួយសម្រាប់ចិញ្ចឹមមាន់។ ពួកគេបានដាំបន្លែនៅលើដីមួយកន្លែងតូច ដែលជួយផ្ដល់អាហារូបត្ថម្ភដល់កូនៗរបស់ពួកគេ។ ពួកគេមានបង្គន់នៅខាងក្រៅ ហើយកូនៗរបស់ពួកគេដូចជាមិនមានព្រូន ឬជំងឺរាគញឹកញាប់ដូចក្មេងៗនៅក្នុងភូមិឡើយ។

លោកឡេបឆា បានធ្វើពាងសម្រាប់ត្រងទឹកភ្លៀង ដាក់នៅក្រោមទទឹក នៅពេលដែលពួកគេដាក់ដំបូលប្រក់ស័ង្កសី ដើម្បីប្រមូលទឹកភ្លៀងដែលធ្លាក់យ៉ាងរប៉េះរប៉ោះមក។ អ្នកដទៃបានចម្លងគំនិតមួយនេះ ហើយឥឡូវនេះនៅពេលដែលមានភ្លៀង ពួកគេក៏មានទឹកប្រើប្រាស់ដែរ។

ពួកគេបានប្រមូលមនុស្សនៅក្នុងសហគមន៍ឲ្យមកធ្វើការជាមួយគ្នា ដើម្បីដាក់បំពង់បង្ហូរទឹកចេញពីអាងស្តុកទឹកនៅក្នុងភូមិ ហើយឥឡូវនេះអ្នកភូមិមានទឹកប្រើប្រាស់ច្រើនណាស់ និងគ្រប់គ្រាន់សម្រាប់សួនបន្លែថ្មីរបស់ពួកគេទៀតផង។ មានមនុស្សជាច្រើនបានចម្លងទ្រុងមាន់ និងសង់បង្គន់ដែលមិនមានក្លិនស្អុយ ហើយក៏លែងមានរុយទៀតដែរ។

នៅពេលដែលគ្រួសាររបស់លោក ឡេបឆា បានមករស់នៅទីនោះ ពួកគេបានចាប់ផ្ដើមបង្រៀនមនុស្សពេញវ័យ និងក្មេងៗដែលចង់រៀនអាន និងសរសេរ។ ពួកគេចាប់ផ្ដើមបង្រៀនក្មេងៗ និងជំទង់ពីរបៀបអានមុន។ ថ្ងៃនេះ នៅក្នុងភូមិនោះមានសាលារៀនផ្ទាល់ខ្លួន សម្រាប់ក្មេងៗរហូតដល់ថ្នាក់ទី៤។

សព្វថ្ងៃនេះ មានអគារក្រុមជំនុំតូចមួយ ដោយសារតែមាន២៣គ្រួសារ ក្នុងចំណោម២៥គ្រួសារមានទំនាក់ទំនងជាមួយព្រះគ្រិស្ដ។ អ្វីៗទាំងអស់នេះកើតឡើង ដោយសារតែមានគ្រួសារមួយបានចែករំលែកពីព្រះគ្រិស្ដតាមរយៈពាក្យសម្ដី និងកិច្ចការរបស់ពួកគេ។

មនុស្សមានអារម្មណ៍អំពីភាពជោគជ័យ ហើយពួកគេមើលឃើញថាពួកគេអាចរស់នៅប្រកបដោយសុភមង្គល ដោយសារតែមួយគ្រួសារបានខ្វល់ខ្វាយនិងយកចិត្តទុកដាក់ និងមកដើម្បីចែករំលែកពីជីវិតរបស់ពួកគេជាមួយអ្នកដទៃ។

រឿងដដែលនេះ ត្រូវបានតំណាលប្រាប់ពីមួយពេលទៅមួយពេលនៅក្នុងភូមិនីមួយៗនៅភាគខាងជើងនៃប្រទេសឥណ្ឌា និងភាគខាងកើតនៃប្រទេសនេប៉ាល់។ ថ្ងៃនេះមានអ្វីដូចគ្នាកំពុងកើតឡើងនៅក្នុង១២០ភូមិក្នុងតំបន់នេះ។ ជីវិតរបស់មនុស្សត្រូវបានផ្លាស់ប្រែផ្នែករូបរាងកាយ។ ប៉ុន្តែ អ្នកភូមិក៏ត្រូវបានផ្លាស់ប្រែខាងវិញ្ញាណដែរ ដែលមានក្រុមជំនុំតាមផ្ទះ១០៧កន្លែង បានចាប់ផ្តើមរួចទៅហើយ ដែលក្រុមជំនុំ១២ដែលធំជាងគេមានសមាជិក២០០នាក់។

ក្រុមគ្រូគង្វាលជនជាតិឥណ្ឌា បានបង្កើតនិកាយផ្ទាល់របស់ពួកគេហៅថា ក្រុមជំនុំអាកាប៉េ (Agape) ដែលមានភាគច្រើនសុទ្ធជាអ្នកជឿថ្មីនឹងចូលរួម។ នៅពេលដែលមានគ្រិស្តបរិស័ទមួយគ្រួសារ ដូចជាគ្រួសាររបស់លោក ឡៃបធា ដែលមាននិមិត្តចង់ឃើញសហគមន៍របស់ពួកគេផ្លាស់ប្រែ អ្វីៗអស្ចារ្យជាច្រើនបានកើតឡើងដោយសារតែព្រះជាម្ចាស់ ប្រសិនបើពួកគេស្វែងរកបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ នោះពួកគេនឹងបំណងដើម្បីសម្រេចនិមិត្តដែលព្រះជាម្ចាស់បានប្រទានមកឲ្យពួកគេ។ គំរូនៅក្នុងគ្រួសារមួយចំនួនបានផ្លាស់ប្រែទៅជាគំរូដែលមានមូលដ្ឋានបែបក្រុមជំនុំ ដោយបណ្តុះបណ្តាលមនុស្សសំខាន់ៗនៅក្នុងក្រុមជំនុំ។ វាជាសេចក្តីអធិស្ឋានរបស់យើង ដើម្បីក្លាយជាសហគមន៍គំរូសម្រាប់ពេលអនាគត។

- តើការផ្លាស់ប្រែដែលលោក ឡៃបធា បាននាំមកនៅក្នុងសហគមន៍ មានអ្វីខ្លះ? សូមអានរឿងនេះម្តងទៀត ហើយសរសេរបញ្ចីដាក់នៅក្រោម ផ្នែកសង្គម វិញ្ញាណ រូបកាយ ប្រាជ្ញា។
- តើគាត់បាននាំការផ្លាស់ប្រែទាំងនេះយ៉ាងដូចម្តេច? តើគាត់ចាប់ផ្តើមជាមួយនរណា? *គ្រួសាររបស់គាត់*
- តើសហគមន៍នេះខុសប្លែកពីមុនត្រង់ណាខ្លះ ដោយសារតែលោក ឡៃបធា?
- តើអ្នកអាចធ្វើដូចជាលោក ឡៃបធា នៅក្នុងសហគមន៍របស់អ្នកបានយ៉ាងដូចម្តេច?

*នៅក្នុងដំណាក់កាលទី៤ យើងនឹងនាំមកឲ្យអ្នកនូវ មេរៀនជាភាគនៃការបង្រៀនអំពីសុខភាព ស្រដៀងនឹងអ្វីដែលលោក ឡៃបធា បានរៀនដែរ។*

## គំរូផ្សេងទៀតរបស់មនុស្សដែលបានកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់

សូមអានរឿងទាំងប៉ុន្មានខាងក្រោម ហើយពិភាក្សាអំពីសំណួរនៅក្រោមរឿងនីមួយៗ។

### ឈោងចាប់ទៅកាន់មន្ទីរពេទ្យ

គ្រូគង្វាលម្នាក់នៅក្នុងប្រទេសផ្តាច់ការមួយ បានចែកចាយខិតប័ណ្ណនៅក្នុងវិហារឥស្លាម។ រដ្ឋាភិបាលមិនសប្បាយចិត្តទេ ដូច្នេះពួកគេបានដកឋានៈជាមន្ត្រីរបស់លោក។ វិធីសាស្រ្តផ្សាយដំណឹងល្អរបស់គាត់

មិនត្រូវបានទទួលការស្វាគមន៍ទេ។ នៅថ្ងៃមួយគាត់បានចូលរួមវគ្គបណ្តុះបណ្តាលអំពីការបង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ តាមរយៈសកម្មភាពនៃសេចក្តីស្រលាញ់។ គាត់ក៏បាននឹកឃើញពីផែនការថ្មីមួយ។ គាត់ក៏បានយកអ្នកស្ម័គ្រចិត្ត៤នាក់ ទិញនំប៉័ង ហើយបានសុំការអនុញ្ញាតពីប្រធានមន្ទីរពេទ្យ ដើម្បីទៅសួរសុខទុក្ខអ្នកជំងឺ ចែកនំប៉័ង និងអធិស្ឋានដល់ពួកគេ។ បន្ទាប់មកក្រុមរបស់គាត់ក៏បានទទួលការអនុញ្ញាត ប៉ុន្តែត្រូវចាត់ទៅឲ្យមណ្ឌលដែលពិបាកជាងគេ ជាអគារបិទជិតសម្រាប់អ្នកជំងឺវិកលចរិតដែលមើលមិនជា។ មានអ្នកជំងឺម្នាក់ ដែលមិននិយាយអស់ជាច្រើនឆ្នាំមកហើយ។ គាត់លូន ជំនួសដោយការដើរ។ មុខរបស់គាត់ហើម ហើយខូចទ្រង់ទ្រាយទៀតផង។ ត្រចៀកម្ខាងរបស់គាត់ហើមធំ ហើយគាន់មានក្លិនស្អុយទៀត។ ខ្លួនគាត់ទាំងមូលឡើងស្នោកគ្រោក។ អ្នកមកសួរសុខទុក្ខបានដាក់ដៃលើគាត់ដើម្បីអធិស្ឋាន ហើយមិនចង់ប៉ះកន្លែងណាផ្សេងទៀតទេ លុះត្រាតែកន្លែងនោះស្អាត។

នៅសប្តាហ៍ក្រោយ លោកគ្រូគង្វាល និងអ្នកស្ម័គ្រចិត្តក៏ត្រឡប់មកវិញ។ មានបុរសខ្ពស់ រាងស្តើងម្នាក់ដែលនៅពីក្រោយរបារមណ្ឌលវិកលចរិតក៏បានមកជួបពួកគេ។ ពួកគេបានសុំគាត់ឲ្យនាំពួកគេ ទៅជួបអ្នកជំងឺមួយក្រុម។ បុរសនោះបានប្រកាសថា គាត់ជាបុរសដែលពួកគេបានអធិស្ឋានឲ្យកាលពីសប្តាហ៍មុន សេចក្តីអធិស្ឋានរបស់ពួកគេបានផ្លាស់ប្រែគាត់ ដូច្នេះហើយបានជាគាត់ឲ្យពួកគេអធិស្ឋានឲ្យម្តងទៀត។ ទោះជាយ៉ាងណាក៏ដោយ ក្រុមនោះមិនបានចាំរូបគាត់ទេ ដូច្នេះពួកគេបានប្រាប់គាត់ថា ពួកគេមិនមានពេលច្រើន ហើយបានសុំឲ្យគាត់នាំពួកគេទៅជួបអ្នកជំងឺផ្សេងទៀត។ គាត់ក៏បាននាំពួកគេទៅ ហើយបុគ្គលិកនៅក្នុងមណ្ឌលនោះបានបញ្ជាក់ប្រាប់ថា គាត់ពិតជាបុរសចម្លែកម្នាក់ដែលពួកគេបានអធិស្ឋានកាលពីសប្តាហ៍មុនប្រាកដមែន។ ក្រុមនៅក្នុងព័ន្ធកិច្ចនោះបានភ្ញាក់ផ្អើលជាខ្លាំង។ បុរសម្នាក់នោះបានជាសះស្បើយ។ គាត់បានដើរផង និងនិយាយផង។ គាត់ថែមទាំងចេះសរសេរទៀតផង។ ស្ថានភាពជំងឺរបស់គាត់បានប្រែក្លាយពីមើលមិនជា ទៅជាជំងឺដែលអាចមើលជា។

ពេលវេលាក៏បានកន្លងផុតទៅ ក្រុមបម្រើព័ន្ធកិច្ចនោះនៅតែបន្តមកសួរសុខទុក្ខ ហើយបានយកនំប៉័ង និងសំលៀកបំពាក់ ថែមទាំងអធិស្ឋានសម្រាប់អ្នកជំងឺ។ អ្នកជំងឺដទៃទៀតក៏បានឆ្លើយតបក្នុងរបៀបដូចគ្នាដែរ។ បន្ទាប់មក ក្រុមនោះត្រូវបានអញ្ជើញឲ្យទៅធ្វើព័ន្ធកិច្ចជាមួយអ្នកជំងឺទាំង៨០០នាក់ និងបុគ្គលិករបស់មន្ទីរពេទ្យ។ ព្រះជាម្ចាស់បានទ្វេគុណធនធាន ហើយអ្នកដទៃផ្សេងទៀតក៏បានឮពីកិច្ចការរបស់ពួកគេដែរ។ ក្នុងរយៈតែ៣ឆ្នាំ និងការផ្តល់ងារជាមន្ត្រីក្នុងតំបន់ គាត់ថែមទាំងបានពង្រីកក្រុមរបស់គាត់ដែលធ្វើព័ន្ធកិច្ចជារៀងរាល់សប្តាហ៍ ទៅកាន់មនុស្ស២៦០០នាក់ នៅក្នុងមន្ទីរពេទ្យចំនួន៥កន្លែង មណ្ឌលកុមារកំព្រាចំនួន៥កន្លែង និងពន្ធនាគារចំនួន២កន្លែង ហើយនិងមជ្ឈមណ្ឌលស្តារនីតិសម្បទាសម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង។ ពួកគេបានចាប់ផ្តើមធ្វើព័ន្ធកិច្ចជាមួយក្មេងៗនៅតាមចិញ្ចើមផ្លូវ និងទុរគតជន។

- តើមានអ្វីបានកើតឡើងនៅក្នុងរឿងនេះ?
- តើអ្វីដែលបានចាប់ផ្តើមកិច្ចការទាំងអស់នេះឡើង?
- តើគាត់បានធ្វើអ្វី?
- តើមានលទ្ធផលអ្វី?
- តើសហគមន៍របស់គាត់ឥឡូវនេះ បានប្រែក្លាយទៅតាមបំណងរបស់ព្រះជាម្ចាស់តិច ឬច្រើនជាងមុន ដោយសារតែសកម្មភាពរបស់គាត់?
- តើយើងអាចរៀនបានអ្វីខ្លះ ពីរឿងនេះ?

**ពីការដែលរងនូវការបៀតបៀន ទៅជាការដឹកនាំ**

មានគ្រូគង្វាលម្នាក់ នៅក្នុងប្រទេសផ្តាច់ការមួយទៀត ដែលតែងតែត្រូវបានគេចាប់ទៅប៉ុស្តិ៍ប៉ូលីស។ ក្នុងមួយឆ្នាំយ៉ាងហោចណាស់មាន៦ដង ដែលប៉ូលីសមកវគ្គបណ្តុះបណ្តាលដែលគាត់កំពុងតែបង្រៀន ហើយក៏បានចាប់គាត់យកទៅប៉ុស្តិ៍ប៉ូលីស។ នៅថ្ងៃមួយគាត់បានរៀនអំពីគំនិតនៃការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ ហើយចាប់ផ្តើមបង្រៀនពួកជំនុំរបស់គាត់អំពីគំនិតទាំងអស់នេះ។ គាត់បានលើកទឹកចិត្តពួកជំនុំរបស់គាត់ អ្នកដែលគាត់ទទួលបន្ទុកលើ ឲ្យចាប់ផ្តើមបម្រើដល់អ្នកជិតខាង និងសម្លឹងមើលឱកាសដើម្បីធ្វើឲ្យសហគមន៍របស់ពួកគេ កាន់តែក្លាយទៅដូចជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ពួកជំនុំបានអនុវត្តគម្រោងជាច្រើនដូចជា៖ ឧបត្ថម្ភដល់ជនក្រីក្រ សាងសង់ផ្ទះឲ្យស្ត្រីមេម៉ាយ ជុសជុលផ្លូវ សាងសង់បង្គន់ -ល-។ ពួកជំនុំក៏បានចាប់ផ្តើមរីកចម្រើន ហើយអ្នកជឿក៏កាន់តែយល់ដឹងបានច្បាស់។ អំពើអាក្រក់នៅក្នុងសង្គមដូចជា ការផឹកស្រា និងការលេងល្បែងស៊ីសងក៏ត្រូវបានបញ្ឈប់នៅក្នុងសហគមន៍នេះ។ មិនយូរប៉ុន្មានខាងមន្ត្រីក្នុងជួររដ្ឋាភិបាលបានកត់សម្គាល់ឃើញឥទ្ធិពលរបស់គ្រូគង្វាលម្នាក់នេះ និងពួកជំនុំដែលគាត់ទទួលបន្ទុកដែលកំពុងមានសកម្មភាពនៅក្នុងសហគមន៍។ ជាលទ្ធផល ពួកគេបានតែងតាំងគ្រូគង្វាលធ្វើជាអ្នកដឹកនាំក្នុងជួររដ្ឋាភិបាលថ្មី នៅក្នុងតំបន់នោះ។ គាត់ក៏ចាប់ផ្តើមជាមួយតួនាទីថ្មីរបស់គាត់ ដោយបង្រៀនអ្នកនៅក្រោមគាត់ពីមេរៀនសុខភាព ដើម្បីឲ្យពួកគេអាចបង្រៀនមនុស្សគ្រប់គ្នានៅក្នុងសហគមន៍ជាមួយមេរៀនទាំងនេះ។ ឥឡូវនេះសុខភាពរបស់ប្រជាជននៅក្នុងសហគមន៍ក៏កាន់តែប្រសើរឡើងដែរ។

- តើលោកគ្រូគង្វាលនេះ បានធ្វើអ្វី?
- តើគាត់កំពុងតែកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងរបៀបណាខ្លះ?
- តើមានលទ្ធផលបែបណា?
- តើមានមេរៀនអ្វីខ្លះពីរឿងនេះ ដែលយើងអាចយកទៅអនុវត្តនៅក្នុងជីវិតរបស់យើងបាន?

### ក្មេងៗទៅសាលារៀន

នៅក្នុងតំបន់មួយ ចំនួនក្មេងៗដែលទៅចូលរៀននៅសាលាមានកម្រិតទាបណាស់។ មានបុរសម្នាក់បានយល់ពីសារៈសំខាន់នៃការអប់រំ បានសម្រេចចិត្តដើម្បីព្យាយាមធ្វើអ្វីមួយពីបញ្ហានេះ។ គាត់បាននិយាយទៅកាន់អ្នកដទៃទៀតនៅក្នុងក្រុមជំនុំអំពីបញ្ហានេះ ហើយប្រមូលគ្នាជាក្រុមតូចដែលមានចិត្តធ្វើការជាមួយគាត់ដើម្បីដោះស្រាយបញ្ហាមួយនេះ។ ពួកគេបានចាប់ផ្តើមពីផ្ទះមួយ ទៅផ្ទះមួយដើម្បីលើកទឹកចិត្តទៅដល់គ្រួសារមួយចំនួនឲ្យបញ្ជូនកូនៗរបស់ពួកគេទៅសាលារៀន។ ជាលទ្ធផល ក្មេងៗទាំងអស់នៅក្នុងតំបន់របស់គាត់បានទៅរៀននៅសាលា។ មន្ត្រីខាងផ្នែកអប់រំនៅក្នុងតំបន់ផ្សេងៗទៀត បានកត់សម្គាល់ពីអ្វីដែលបានកើតឡើងនៅក្នុងសហគមន៍របស់គាត់ ហើយអញ្ជើញគាត់ឲ្យទៅតំបន់ផ្សេងទៀត ដើម្បីលើកទឹកចិត្តអាណាព្យាបាលឲ្យនៅតែបន្តបញ្ជូនកូនៗរបស់ពួកគេទៅសាលា។ ឥឡូវនេះ មិនត្រឹមតែក្មេងៗនៅក្នុងភូមិរបស់គាត់នោះទេ ប៉ុន្តែមានថែមទាំងក្មេងៗដែលនៅភូមិជុំវិញក៏បានទៅសាលារៀនដែរ។

- តើបុរសម្នាក់នេះ បានកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងរបៀបណា?
- តើវាអាចទៅរួចដែរឬទេ ក្នុងការដែលធ្វើកិច្ចការស្រដៀងនេះនៅក្នុងសហគមន៍របស់អ្នក?

យើងទាំងអស់គ្នា អាចធ្វើជាមនុស្សដែលនាំការផ្លាស់ប្រែមកសហគមន៍របស់យើងបាន។ មនុស្សទាំងអស់ខាងលើនេះ មិនមែនជាមនុស្សពិសេស ឬមានព្រះពរបន្ថែមអ្វីនោះទេ។ ពួកគេក៏ជាមនុស្សសាមញ្ញដូចជាអ្នកហើយនឹងខ្ញុំដែរ។ មានមនុស្សមួយចំនួនមានចំណេះដឹងតែបន្តិចប៉ុណ្ណោះ ប៉ុន្តែពួកគេទាំងអស់មានសុខចិត្តធ្វើអ្វីដែលពួកគេអាចធ្វើបាន ដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងសហគមន៍របស់ពួកគេ។

## របៀបក្លាយជាអ្នកកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់

ព្រះទ្រង់អាចធ្វើអ្វីៗតាមតែព្រះហឫទ័យរបស់ទ្រង់។ ទ្រង់អាចកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ដោយគ្មានយើងបាន។ ប៉ុន្តែ នោះមិនមែនជាផែនការរបស់ទ្រង់ទេ។ ផែនការរបស់ទ្រង់គឺប្រើប្រាស់យើងក្នុងការកសាងព្រះរាជ្យរបស់ទ្រង់។ ការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់គឺចាប់ផ្តើមជាមួយយើង។ សូមអាន ឬក៏ចែកមេរៀន ៥.៣។ សូមឲ្យពួកគេអធិស្ឋានយ៉ាងយកចិត្តទុកដាក់ និងគិតអំពីរបៀបដែលពួកគេអាចឆ្លើយតបបាន។

មេរៀន ៥.២ របៀបដើម្បីក្លាយជាអ្នកកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់

### ១. ចាប់ផ្តើមពីខ្លួនអ្នក

ជំហានដំបូង ក្នុងការមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ត្រូវបានកសាងនៅក្នុងជីវិតរបស់អ្នក នៅក្នុងគ្រួសាររបស់អ្នក នៅក្នុងក្រុមជំនុំរបស់អ្នក នៅក្នុងសហគមន៍របស់អ្នក និងនៅក្នុងពិភពលោកនោះគឺត្រូវពិនិត្យមើលខ្លួនឯង។ តើអ្នកមានចិត្តចង់ឲ្យព្រះជាម្ចាស់ប្រើប្រាស់ដែរឬទេ? តើអ្នកមានចិត្តចង់ស្តាប់បង្គាប់ព្រះជាម្ចាស់នៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់អ្នកដែរឬទេ? តើកិច្ចការមួយ ឬពីរដែលអ្នកអាចធ្វើបានដើម្បីឲ្យកាន់តែប្រសើរឡើងនៅក្នុងសប្តាហ៍នេះមានអ្វីខ្លះ?

### ២. បង្រៀន និងលើកទឹកចិត្តក្រុមគ្រួសាររបស់អ្នក

នៅពេលដែលអ្នកចាប់ផ្តើមអនុវត្តព្រះរាជ្យរបស់ព្រះជាម្ចាស់ទៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់អ្នក អ្នកត្រូវតែចាប់ផ្តើមលើកទឹកចិត្តក្រុមគ្រួសាររបស់អ្នកដើម្បីធ្វើដូចគ្នា។ នៅពេលដែលយើងអាន យើងគួរតែបង្រៀនគ្រួសាររបស់យើងគ្រប់ពេល (ទុតិយកថា ៦៖៧) មិនថាយើងកំពុងតែធ្វើអ្វីទេ។ ចូរស្វែងរកពីរបៀបក្នុងការបង្រៀនគ្រួសាររបស់អ្នកតាមរយៈអ្វីដែលអ្នកធ្វើ តាមរយៈការនិយាយទៅកាន់ពួកគេ និងតាមរយៈការរកមើលរបៀបដើម្បីជួយពួកគេឲ្យចាប់ផ្តើមបម្រើអ្នកដទៃផងដែរ។

ចូរចងចាំពីអ្វីៗដែលអ្នកបានប្តេជ្ញាធ្វើនៅក្នុងមេរៀន នៅគ្រប់ផ្នែកទាំងបួនដើម្បីជួយដល់គ្រួសាររបស់អ្នកឲ្យរីកចម្រើនឡើង។

### ៣. សូមឲ្យព្រះជាម្ចាស់ប្រើប្រាស់អ្នកដើម្បីជះឥទ្ធិពលដល់អ្នកដទៃ

ចូរចាប់ផ្តើមអធិស្ឋាន ហើយសូមឲ្យព្រះជាម្ចាស់ជួយអ្នកដើម្បីជះឥទ្ធិពលដល់អ្នកដទៃ។ សូមសម្លឹងមើលឱកាសផ្សេងៗ។ នៅពេលដែលអ្នកឃើញមនុស្សកំពុងតែមានតម្រូវការ សូមឲ្យព្រះជាម្ចាស់បង្ហាញពីរបៀបដែលអ្នកអាចជួយមនុស្សទាំងនោះ។

ព្រះជាម្ចាស់មានចិត្តចង់ជួយយើងដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ទ្រង់ចង់បង្ហាញមកកាន់យើងនៅពេលវេលាត្រឹមត្រូវ និងរបៀបត្រឹមត្រូវក្នុងការជួយ។

### ៤. បម្រើអ្នកដទៃ

សូមចូលរួមក្នុងសកម្មភាពនៃសេចក្តីស្រលាញ់ ដើម្បីស្វែងរករបៀបផ្សេងទៀតដើម្បីបម្រើ។ ទោះបីជាអ្នកមានអារម្មណ៍ថា អ្នកមិនអាចធ្វើអ្វីបានច្រើននោះទេ អ្នកគួរតែនៅបន្តប្រើប្រាស់អំណោយទានទាំងអស់ ដែលព្រះជាម្ចាស់ប្រទានមកឲ្យអ្នកដើម្បីបម្រើ។ នៅពេលដែលអ្នកបម្រើ អ្នកនឹងចាប់ផ្តើមរីកចម្រើន និងដឹងថាអ្នកអាចធ្វើអ្វីកាន់តែច្រើនឡើងៗ។

### មេរៀនទី ៦

# តួនាទីរបស់ក្រុមជំនុំ ក្នុង ការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់

**គោលបំណង**

- ក្រុមជំនុំគួរតែជាមណ្ឌលនៃការផ្លាស់ប្រែសហគមន៍ ឲ្យកាន់តែក្លាយដូចជាព្រះរាជ្យរបស់ព្រះជាម្ចាស់។
- មនុស្សគ្រប់រូបនៅក្នុងក្រុមជំនុំ គឺពិតជាមានសារៈសំខាន់ណាស់ ហើយមនុស្សគ្រប់គ្នាគួរតែរួមចំណែកនៅក្នុងការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅក្នុងរបៀបមួយចំនួន។

រូបភាពជំនួយដល់ការសិក្សា

៤. កាតអំពីផ្នែកនៃសារពាង្គកាយ

## សេចក្តីផ្តើម

នៅក្នុងមេរៀនមុន យើងបានមើលទៅលើដំណើរការនៃការផ្លាស់ប្រែ ពីរបៀបដែលវាចាប់ផ្តើមជាមួយអ្នកទៅកាន់គ្រួសាររបស់អ្នក ហើយឈានទៅកាន់សហគមន៍ និងប្រទេសជាតិ។ ទោះជាយ៉ាងណា មានផ្នែកដែលសំខាន់មួយទៀតនៅក្នុងដំណើរមួយនេះគឺ ក្រុមជំនុំ។

ដើម្បីសម្រេចបាននូវនិមិត្តដ៏ធំនេះ ជាផែនការរបស់ព្រះជាម្ចាស់គឺក្រុមជំនុំនឹងមានតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរនៃការផ្លាស់ប្រែ។

សូមអាន អេភេសូ ១៖២២-២៣

- តើអ្វីជាតួនាទីរបស់ក្រុមជំនុំ?
    - ដើម្បីសម្រេចឲ្យបាននូវកិច្ចការរបស់ព្រះយេស៊ូ

សូមអាន អេភេសូ ៣៖១០

- តើព្រះជាម្ចាស់ប្រើប្រាស់អ្វី ដើម្បីឲ្យគេស្គាល់ពីប្រាជ្ញារបស់ទ្រង់?

- ក្រុមជំនុំ

ខគម្ពីរទាំងនេះមិនមែនតែងតែងាយស្រួលក្នុងការយល់នោះទេ ប៉ុន្តែវាបានរំឭកយើងថាព្រះជាម្ចាស់បានប្រទានឲ្យក្រុមជំនុំមានតួនាទីពិសេសនៅក្នុងការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ក្រុមជំនុំគឺជាព្រះកាយរបស់ព្រះគ្រិស្ត។ វាជាតួនាទីរបស់ក្រុមជំនុំដើម្បីសម្រេចកិច្ចការរបស់ព្រះយេស៊ូ និងនាំយកការផ្សះផ្សាទៅកាន់អ្វីៗ**ទាំងអស់**។

- តើនឹងមានអ្វីកើតឡើង ប្រសិនបើក្រុមជំនុំរបស់អ្នកត្រូវបិទទ្វារ? តើអ្នកមិនជឿ (អ្នកមិនមែនជាគ្រិស្តបរិស័ទ) នៅក្នុងសហគមន៍របស់អ្នកនឹងត្អូញត្អែរដែរឬទេ? ហេតុអ្វី?

ក្រុមជំនុំគួរតែមានឥទ្ធិពលទៅលើសហគមន៍ រហូតដល់មនុស្សនៅក្នុងសហគមន៍នឹងពិបាកចិត្តនៅពេលដែលក្រុមជំនុំចេញទៅ។

ចូរគូសក្រាបនៅក្នុងមេរៀនមុនតាមវិធីផ្សេង។ ចូរចាប់ផ្តើមពីបុគ្គល ទៅកាន់គ្រួសារ ហើយទៅកាន់សហគមន៍ និងទៅកាន់ប្រទេសជាតិ។ (គូសនៅលើក្តារខៀន)




## បំពាក់បំប៉នបុគ្គលម្នាក់ៗ

សូមចែកកាតរូបភាពអំពីផ្នែកនៃសារពាង្គកាយ ទៅកាន់សិស្សម្នាក់ៗនៅក្នុងថ្នាក់រៀន
(រូបភាពជំនួយដល់ការសិក្សា X)។

- តើផ្នែកណាខ្លះដែលមិនសំខាន់ ឬមិនមានគោលបំណងអ្វីសោះ?
- តើផ្នែកណាខ្លះនៅលើសារពាង្គកាយដែលតូចតាចជាងគេ?

- តើនឹងមានផលប៉ះពាល់អ្វីខ្លះ ប្រសិនបើដកផ្នែកដែលតូចជាងគេបំផុតនោះចេញ?
- ប្រសិនបើផ្នែកទាំងអស់ ត្រូវបានបែងចែក ឬផ្តាច់ពីគ្នា តើសារពាង្គកាយនៅតែដំណើរការបានដែរឬទេ?
- ចូរឲ្យឧទាហរណ៍ពីរបៀបដែលផ្នែកផ្សេងៗនៃសារពាង្គកាយត្រូវការផ្នែកផ្សេងទៀត។
- តើសារពាង្គកាយនឹងដំណើរការដោយប្រសិទ្ធភាពដែរឬទេ ប្រសិនបើបាត់ផ្នែកមួយចំនួន?

ឲ្យសមាជិកទាំងអស់ដាក់កាតរបស់ពួកគេចុះ។

- តើសារពាង្គកាយនឹងប្រសើរឡើងជាងមុនដែរឬទេ?
- តើការបាត់បង់ផ្នែកទាំងនោះ នឹងនាំឲ្យមានផលប៉ះពាល់អ្វីខ្លះ?

ឲ្យសិស្សជ្រើសរើសផ្នែកនៃសារពាង្គកាយណាដែលសំខាន់ជាងគេ ហើយដាក់ផ្នែកផ្សេងៗដែលនៅសល់ចុះ។

- តើសារពាង្គកាយនៅអាចបន្តដំណើរការទៀតបានដែរឬទេ? ហេតុអ្វី (ពីព្រោះយើងមានផ្នែកដែលសំខាន់ជាងគេហើយតើ)?

**<u>១ កូរិនថូស ១២៖១២-២០</u>**

- គ្រប់ផ្នែកនៃរាងកាយគឺសុទ្ធតែសំខាន់។ ក្រុមជំនុំគឺដូចជារាងកាយមួយ ដែលសមាជិកក្រុមជំនុំគ្រប់រូបសុទ្ធតែសំខាន់នៅក្នុងការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ គ្មានសមាជិកណាដែលគ្មានប្រយោជន៍នោះទេ។ តើសមាជិកគ្រប់រូបសុទ្ធតែដើរតួយ៉ាងសំខាន់ដែរឬទេ? តើមានមនុស្សណាខ្លះដែលមិនបង្កឲ្យមានផលប៉ះពាល់នៅក្នុងដំណើការរបស់ក្រុមជំនុំ ឬព័ន្ធកិច្ចរបស់ក្រុមជំនុំ ប្រសិនបើពួកគេឈប់មកចូលរួម?
- តើមានប៉ុន្មានភាគរយនៃពួកជំនុំដែលពិតជាកំពុងតែរួមចំណែកយ៉ាងសកម្ម? តើមានប៉ុន្មានភាគរយនៃសារពាង្គកាយដែលមិនបានចូលរួម ឬមិនបានប្រើការ?
សួរថាតើមានប៉ុន្មានភាគរយដែលសិស្សបានដាក់កាតរបស់គេចុះ។
- ប្រសិនបើសារពាង្គកាយរបស់អ្នកមានតែប៉ុន្មានភាគរយនោះដែលធ្វើការ តើវានឹងមានលក្ខណៈបែបណា? តើវាពិតដូចជាក្រុមជំនុំដែរឬទេ? តើក្រុមជំនុំនឹងកាន់តែមានប្រសិទ្ធភាព ប្រសិនបើមានភាគរយច្រើនមានប្រសិទ្ធភាព?
- តើយើងអាចធ្វើអ្វី ដើម្បីចាប់ផ្តើមដោះស្រាយពីបញ្ហានេះ?

## ហេតុអ្វីបានជាមនុស្សគ្រប់គ្នា ចាំបាច់ត្រូវបម្រើ?

**សូមអាន អេភេសូ ២៖១០**

- តើព្រះជាម្ចាស់បានសង្គ្រោះយើងឲ្យធ្វើអ្វី?
- តើមនុស្សដែលទទួលបានការសង្គ្រោះ ត្រូវប្រព្រឹត្តអំពើល្អគ្រប់រូប ឬគ្រាន់តែមួយចំនួន?
- តើមនុស្សគ្រប់គ្នាទៅក្រុមជំនុំរបស់អ្នកប្រព្រឹត្តអំពើល្អដែរឬទេ។

**សូមអានប្រស្នាអំពីប្រាក់ណែន (ម៉ាថាយ ២៥៖១៤-៣០)**

- នៅពេលដែលអ្នកអាននូវប្រស្នាមួយនេះ តើអ្នកគិតថាវាបង្ហាញពីគ្រិស្តបរិស័ទមួយចំនួនដែលមិនចាំបាច់ប្រើប្រាស់ប្រាក់ណែន (ព្រះអំណោយទាន) របស់គេ ដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ដែរឬទេ?
- តើគ្រិស្តបរិស័ទគ្រប់រូបនៅក្នុងក្រុមជំនុំរបស់អ្នកប្រើប្រាស់ប្រាក់ណែន (ព្រះអំណោយទាន) របស់ពួកគេបានពេញលេញដែរឬទេ?
- តើយើងអាចជួយមនុស្សបន្ថែមទៀត ដោយប្រើប្រាស់ប្រាក់ណែន (ព្រះអំណោយទាន) របស់ពួកគេពេញលេញ ដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់បានដោយរបៀបណា?

ដើម្បីកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ យើងទាំងអស់ត្រូវតែធ្វើការជាមួយគ្នា។ ខណៈពេលដែលមនុស្សម្នាក់កសាងផ្នែកតូចមួយនៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ក្រុមជំនុំទាំងមូលត្រូវចាប់ផ្តើមរស់នៅដោយស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់ពួកគេ ហើយជួយអ្នកដទៃឲ្យធ្វើដូចគ្នាដែរ នោះយើងនឹងអាចកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់កាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ សូមស្រមៃថា ប្រសិនបើមនុស្សគ្រប់គ្នានៅក្នុងក្រុមជំនុំរបស់អ្នក ប្តេជ្ញាខ្លួនគេដើម្បីឲ្យព្រះហឫទ័យរបស់ព្រះជាម្ចាស់បានសម្រេចនៅក្នុងជីវិតរបស់ខ្លួន ក្រុមជំនុំ និងនៅក្នុងសហគមន៍។ តើនឹងមានផលប៉ះពាល់អ្វី ដែលកើតមានចំពោះក្រុមជំនុំ និងសហគមន៍?

**អេភេសូ ៤៖១១-១២**

- តើតួនាទីរបស់អ្នកដឹកនាំ (សាវ័ក [គ្រិស្តទូត] ព្យាការី អ្នកផ្សាយដំណឹងល្អ គ្រូគង្វាល និងគ្រូបង្រៀន) ជាអ្វី?
- នៅក្នុងក្រុមជំនុំភាគច្រើន និយាយថា ១០%នៃមនុស្សធ្វើ ៩០%នៃកិច្ចការរបស់ពួកគេ។ តើវាត្រឹមត្រូវដែរឬទេ? តើយើងអាចផ្លាស់ប្រែវាបានដោយរបៀបណា?

- តើយើងអាចកាន់តែប្រសើរក្នុងការកសាងអ្នកដទៃ ដើម្បីឲ្យពួកគេអាចធ្វើកិច្ចការនៅក្នុងព័ន្ធកិច្ចដោយរបៀបណា?

គេតែងនិយាយថា អស់អ្នកដែលរៀនច្រើនជាងគេ ហើយរីកចម្រើនច្រើនជាងគេ គឺជាអ្នកដែលបម្រើអ្នកដទៃ។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី មានបេសកជនមួយចំនួនធ្វើការជាមួយយុវជន។ ទោះបីជាពួកគេបង្រៀនជារៀងរាល់សប្តាហ៍ក៏ដោយ ពួកគេចាប់ផ្តើមអន់ចិត្តពីរបៀបដែលគ្រិស្តបរិស័ទនៅទន់ខ្សោយ និងមានការីកចម្រើនយឺតនៅឡើយ។ ពួកគេក៏បានសម្រេចចិត្តថា យុវជនត្រូវតែចាប់ផ្តើមបម្រើ ដូច្នេះពួកគេបានបង្កើតច្បាប់ថ្មីដែលមានតែអ្នកដែលបម្រើនៅក្នុនព័ន្ធកិច្ចមួយចំនួន ទើបអនុញ្ញាតឲ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលប្រចាំសប្តាហ៍ប៉ុណ្ណោះ។ យុវជនភាគច្រើនចាប់ផ្តើមចូលបម្រើនៅក្នុងព័ន្ធកិច្ចមួយចំនួន។ ពួកគេបានធ្វើអ្វីៗគ្រប់យ៉ាងដូចជា ការឈោងចាប់ទៅកាន់គ្រួសារក្រីក្រនៅក្នុងសហគមន៍របស់ពួកគេ បង្រៀនក្មេងៗក្រីក្រ ហើយជួយនៅក្នុងព័ន្ធកិច្ចកុមារ។ ក្នុងរយៈពេលដែលពីរបីខែប៉ុណ្ណោះ បេសកជនទាំងនោះបានកត់សម្គាល់ថាយុវជនទាំងនោះចាប់ផ្តើមមានជំនឿរឹងមាំ។ ហើយឥឡូវនេះ ពួកគេត្រូវតែអានព្រះគម្ពីរ និងអធិស្ឋាន។ ពួកគេត្រូវតែជឿថាព្រះជាម្ចាស់នឹងជួយពួកគេ ដើម្បីឲ្យពួកគេអាចជួយអ្នកដទៃបាន។

**<u>ពិភាក្សានៅក្នុងក្រុមធំ</u>**

- តើមានអ្វីកើតឡើងនៅក្នុងរឿងនេះ?
- តើមានរបៀបណាខ្លះដែលយុវជនចាប់ផ្តើមបម្រើ?
- តើអ្នកធ្លាប់ឃើញថាមនុស្សមានគំនិតចាស់ទុំ នៅពេលដែលពួកគេចាប់ផ្តើមបម្រើព័ន្ធកិច្ចនៅក្នុងក្រុមជំនុំដែរឬទេ?
- ហេតុអ្វីបានជាអ្នកគិតថាមនុស្សមានគំនិតចាស់ទុំ នៅពេលដែលពួកគេចាប់ផ្តើមបម្រើ?

# ការផ្លាស់ប្តូរនៅក្នុងក្រុមគ្រួសារ

ក្រុមជំនុំអាចដើរតួនាទីក្នុងការជួយក្រុមគ្រួសារនានាឲ្យរស់នៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយបង្រៀនសមាជិកក្រុមជំនុំពីរបៀបដែលមានចំណងអាពាហ៍ពិពាហ៍រឹងមាំ និងរបៀបធ្វើជាឪពុកម្តាយដ៏ល្អ និងផ្តល់ឱកាសដល់ក្រុមគ្រួសារទាំងនោះឲ្យថ្វាយបង្គំ និងបម្រើជាមួយគ្នា។ ក្រុមជំនុំត្រូវសម្លឹងរកមើលឱកាសដើម្បីជួយបុគ្គលម្នាក់ៗឲ្យបម្រើគ្រួសាររបស់ពួកគេ និងជួយគ្រួសាររបស់ពួកគេឲ្យរស់នៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

## ការផ្លាស់ប្តូរនៅក្នុងសហគមន៍

ក្នុងនាមជាក្រុមជំនុំ យើងអាចជះឥទ្ធិពលដល់សហគមន៍របស់យើងនៅក្នុងរបៀបជាច្រើន។ ចំណុចសំខាន់បី ដែលសហគមន៍គួរទទួលបានការជះឥទ្ធិពលមានដូចជា៖

**១. បង្កើនចំនួនគ្រិស្តបរិស័ទ**

នេះមិនតែងតែដូចគ្នាទេ នៅពេលដែលក្រុមជំនុំរបស់យើងកាន់តែរីកចម្រើនឡើង។ (យើងធ្វើដូច្នេះបាន ដោយការលួចកូនចៀម)។ ការបង្កើនចំនួនគ្រិស្តបរិស័ទមានន័យថា កាន់តែមានអ្នកមិនជឿច្រើនឡើងៗ បានមកស្គាល់ព្រះជាម្ចាស់ ហើយទទួលព្រះគ្រិស្តធ្វើជាព្រះសង្គ្រោះរបស់ពួកគេ។ ក្រុមជំនុំដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយមនុស្សឲ្យយល់ពីដំណឹងល្អ និងថែទាំគ្រិស្តបរិស័ទថ្មីៗ។

**២. បង្រៀនសហគមន៍ឲ្យរស់នៅដោយស្តាប់បង្គាប់ព្រះជាម្ចាស់**

នៅពេលដែលយើងបានរៀនថា ព្រះជាម្ចាស់បានបង្កើតយើង ហើយទ្រង់ជ្រាបពីអ្វីដែលល្អប្រសើរសម្រាប់យើង។ ទ្រង់បានបង្ហាញពីរបៀបដែលយើងគួរតែរស់នៅ នៅក្នុងព្រះគម្ពីរ។ យើងក៏អាចបង្រៀនអ្នកដទៃពីគោលការណ៍គ្រឹះក្នុងព្រះគម្ពីរ។ ក្នុងនាមជាក្រុមជំនុំ អ្នកអាចចាប់ផ្តើមស្វែងរកឱកាសដើម្បីជួយមនុស្សឲ្យរស់នៅដោយស្តាប់បង្គាប់ព្រះជាម្ចាស់ នៅគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់ពួកគេ។

សូម្បីតែអ្នកមិនចាប់អារម្មណ៍ពីគ្រិស្តសាសនាក៏នឹងចាប់អារម្មណ៍ក្នុងការរៀនអំពីសុខភាព របៀបមានចំណងអាពាហ៍ពិពាហ៍រឹងមាំ ឬរបៀបចាត់ចែងថវិកាដោយឈ្លាសវៃដែរ។ ការបណ្តុះបណ្តាលប្រភេទទាំងនេះ នឹងជួយមនុស្សឲ្យពង្រឹងជីវិតរស់នៅរបស់ពួកគេ ហើយក៏ជួយពួកគេឲ្យរស់នៅដោយស្របតាមគោលការណ៍ព្រះគម្ពីរ និងជួយកសាងទំនាក់ទំនងល្អរវាងអ្នកមិនជឿ និងក្រុមជំនុំដែរ។

**៣. ជួយសហគមន៍របស់ពួកគេឲ្យរស់នៅស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់តាមរយៈការបម្រើក្នុងព័ន្ធកិច្ច**

<u>**នៅក្នុងក្រុមតូច**</u> ចូរឆ្លើយសំណួរដូចខាងក្រោម៖

- ម៉ាថាយ ២០៖២៨ - ហេតុអ្វីបានជាព្រះយេស៊ូយាងមក?
- ភីលីព ២៖៤-៩ - តើលោកប៉ូលពណ៌នាយ៉ាងដូចម្តេចពីព្រះយេស៊ូ?

  ព្រះយេស៊ូបានយាងមកដើម្បីបម្រើ។ តាមការពិត នៅពេលដែលព្រះគម្ពីរចែងថា «ព្រះអង្គមានឋានៈជាព្រះជាម្ចាស់» ឬក៏យើងអាចអានថា «**ដោយសារតែទ្រង់ជាព្រះជាម្ចាស់** ក៏

ព្រះអង្គពុំបានក្ដោបក្ដាប់ឋានៈដែលស្មើនឹងព្រះជាម្ចាស់នេះទុកជាកម្មសិទ្ធិដាច់មុខរបស់ព្រះអង្គឡើយ ផ្ទុយទៅវិញ ព្រះអង្គបានបានលះបង់អ្វីៗទាំងអស់មកយកឋានៈជាទាសករ»។ សូមស្រមៃថា ដោយសារតែទ្រង់ជាព្រះជាម្ចាស់ ទ្រង់បានលះបង់អ្វីៗទាំងអស់ ហើយមកយកឋានៈជាអ្នកបម្រើ។ ឋានៈរបស់ព្រះជាម្ចាស់ គឺមកដើម្បីបម្រើ។ ក្នុងនាមជាក្រុមជំនុំដែលជាព្រះកាយរបស់ព្រះគ្រិស្ត ក្រុមជំនុំក៏គួរតែមានឋានៈជាអ្នកបម្រើដែរ។

- យ៉ាកុប ១៖២៧ - តើសាសនាបែបណាដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់?
- ម៉ាកុស ១២៖៣១ - តើព្រះជាម្ចាស់បានបង្គាប់យើងឲ្យធ្វើអ្វី?

សេចក្ដីស្រលាញ់របស់យើងចំពោះព្រះជាម្ចាស់ និងសម្រាប់អ្នកជិតខាងរបស់យើងគួរតែបណ្ដាលឲ្យយើងបម្រើ។ ជាមួយគ្នានេះដែរ ខណៈដែលព្រះគ្រិស្តយាងមកដើម្បីបម្រើ គោលបំណងរបស់ក្រុមជំនុំគឺដើម្បីបម្រើតាមរយៈការជួយមនុស្សឲ្យស្គាល់ និងរីកចម្រើនក្នុងព្រះគ្រិស្ត តាមរយៈការបង្ហាញសេចក្ដីស្រលាញ់របស់ទ្រង់ទៅកាន់អ្នកដទៃ។

នៅពេលដែលយើងបម្រើសហគមន៍របស់យើង យើងនឹងឃើញពួកគេផ្លាស់ប្រែ។ សូមអាននូវសាច់រឿងខាងក្រោម អំពីសហគមន៍ដែលបានផ្លាស់ប្រែនៅពេលដែលក្រុមជំនុំបម្រើសហគមន៍នោះ។

**សាលានៅក្នុងសហគមន៍**

កាគីស៊ូ (Kagishu) ជាតំបន់សំណង់អនាធិបតេយ្យដែលមានផ្ទះធ្វើពីឈើបាក់បែក និងសន្លឹកដែកដែលគេបោះចោល ហើយមានក្រុមជំនុំដែលមានសមាជិក១៥នាក់។ ក្រុមជំនុំមួយនេះបានទទួលសំបុត្រអញ្ជើញឲ្យចូលរួមសិក្ខាសាលាបណ្ដុះបណ្ដាលគ្រប់ព័ន្ធកិច្ចទាំងអស់ ហើយបានឲ្យលោក មេស្ហាក (Meshack) ដែលមានអាយុ២១ឆ្នាំឲ្យទៅចូលរួម។ លោក មេស្ហាក បានត្រឡប់មកវិញទាំងមាននិមិត្តថ្មីមួយ ៖ «ខ្ញុំបានរៀនអំពីការស្ដាប់បង្គាប់ព្រះយេស៊ូថា គឺមិនមែនស្រេចចិត្តទេ!» ដូច្នេះហើយ លោក មេស្ហាក លោក ឌីស្មុស (Dismus) (អ្នកចាស់ទុំក្នុងក្រុមជំនុំ) គ្រូគង្វាល និងប្រពន្ធរបស់គាត់បានអធិស្ឋាន និងសូមឲ្យព្រះជាម្ចាស់បង្ហាញពីគម្រោងមួយដើម្បីបង្ហាញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ទៅកាន់សហគមន៍របស់ពួកគេ។ ស្រាប់តែមានចម្លើយថា៖ ចាប់ផ្ដើមបង្កើតសាលាមត្តេយ្យសម្រាប់ក្មេងៗនៅក្នុងក្រុមជំនុំ។

ភ្លាមៗនោះ ពួកគេក៏ចាប់ផ្ដើមនិយាយជាមួយសមាជិកក្រុមជំនុំដែលមានកូនៗ ហើយមិនមានលទ្ធភាពបង់ថ្លៃសាលារដ្ឋបាន។ មានមនុស្សមួយចំនួនបានយល់ព្រមបញ្ជូនកូនៗរបស់ពួកគេទៅ «សាលារៀនថ្មី» នេះ។ ដោយមិនបានទទួលវគ្គបណ្ដុះបណ្ដាលអ្វីទេ លោកមេស្ហាក គ្រូគង្វាល និងប្រពន្ធរបស់គ្រូគង្វាលបានចាប់ផ្ដើមបង្រៀនក្មេង១៣នាក់ ដែលមានអាយុពី៦ ទៅ ១២ឆ្នាំ នៅក្នុងបន្ទប់មួយរបស់ក្រុមជំនុំដែលគ្មានតុ សៀវភៅ ឬសម្ភារៈអ្វីទេ។ អ្នកភូមិដែលមិនចង់មានទំនាក់ទំនងជាមួយសាលា បានមក

លួចសម្ភារៈមួយចំនួននៅក្នុងអគារនៅពេលយប់។ លោក មេស្វាក បានទទួលប្រាក់ខែដំបូងក្នុងរយៈពេល៧ខែ គឺ១ដុល្លារសហរដ្ឋអាមេរិកដែលបង់ថ្លៃសាលា និងប្រាក់ដង្វាយមកពីឪពុកម្ដាយរបស់ក្មេងៗ។

លោក មេស្វាក និងលោក ឪស្មុស បានអញ្ជើញកូនៗអ្នកជិតខាងឲ្យមកចូលរួម ហើយសាលាក៏រីកចម្រើនឡើង។ មិនយូរប៉ុន្មាន សាលាក៏មានសិស្សចំនួន ៤៥នាក់ មានអាយុផ្សេងៗនៅក្នុងមួយថ្នាក់។ គ្រូបង្រៀនទី២ បានស្ម័គ្រចិត្តបង្រៀនរយៈពេល៦ខែ ហើយគ្រូបង្រៀនទី៣ ស្ម័គ្រចិត្តបង្រៀនរយៈពេល៨ខែ។ ដោយមានសិស្សកើនឡើងដល់ ១០០នាក់ គ្រូបង្រៀននាំគ្នាឈរទល់ខ្នងគ្នានៅចំកណ្ដាលបន្ទប់បង្រៀនសិស្សរបស់ពួកគេ។ មិនយូរប៉ុន្មានអ្នកជិតខាងក៏បានរើចេញ នៅពេលដែលពួកគេរើចេញ ធ្វើឲ្យសាលាកាន់តែមានទំហំកាន់តែធំ។ នៅពេលនោះសាលាមានអាយុ២ឆ្នាំ ហើយមានអគារពីរខ្នង ដែលមានជាង១០បន្ទប់ ហើយថែមទាំងអាចប្រើដើម្បីថ្វាយបង្គំថ្ងៃអាទិត្យថែមទៀតផង។

មួយឆ្នាំក្រោយមក ក្រុមជំនុំបានទិញដីមួយកន្លែង ដែលនៅជិតតំបន់ ខាវ៉ាងវែរ (Kawangware) ហើយបានទិញអគារអចិន្ត្រៃយ៍មួយ និងផ្លាស់ប្ដូរទីតាំង។ នៅឆ្នាំទី៦ មានគ្រូបង្រៀនដែលទទួលបានប្រាក់ខែចំនួន១៧នាក់ បុគ្គលិក៥នាក់ និងមានកុមារ ៤៤៥នាក់។

នេះគ្រាន់តែជាការចាប់ផ្ដើមនៃសាច់រឿងនៃសហគមន៍ សាលា និងក្រុមជំនុំ។ ជាលទ្ធផលនៃការខិតខំប្រឹងប្រែងដោយផ្ទាល់នេះ ធ្វើឲ្យមានអនុវិទ្យាល័យនៅភូមិជិតនោះ ដែលមានបុគ្គលិកចំនួន១០នាក់ និងសិស្ស៦០នាក់។ ក្រុមជំនុំមួយទៀតបានចាប់ផ្ដើមកន្លែងមើលថែទារក ដែលមានកុមារ២០នាក់ ដែលមានម្ដាយត្រូវទៅធ្វើការ។ ក្រុមជំនុំបានរីកចម្រើនដោយមានសមាជិក៦០នាក់ ហើយថែមទាំងបានដាំក្រុមជំនុំមួយទៀត ដែលមានសមាជិកច្រើនជាង៤០នាក់។ ក្រុមជំនុំនីមួយៗនេះ បានដាំក្រុមជំនុំថ្មី ២ ទៀតនៅក្នុងតំបន់ផ្សេងៗគ្នា។

៦ឆ្នាំក្រោយមក បន្ទាប់ពីការស្ដាប់បង្គាប់ និងការលះបង់របស់ក្រុមជំនុំដ៏តូចមួយ និងសមាជិករបស់ខ្លួននៅទីនោះ ធ្វើឲ្យជះឥទ្ធិពលដែលអាចឲ្យសហគមន៍ និងក្រុមជំនុំដទៃទៀតនៅក្នុងតំបន់នេះមើលឃើញ។ ការផ្លាស់ប្រែពិតប្រាកដគឺនៅក្នុងតំបន់ខាគីស៊ូ ដែលត្រូវបានសហគមន៍ទទួលស្គាល់ និងណែនាំឲ្យមានការផ្លាស់ប្ដូរសហគមន៍នោះពីឈ្មោះ ខាគីស៊ូ (មានន័យថា «កាំបិត») ទៅជា រូអ៊ីតា (Ruita) (មានន័យថា «ដកចេញនូវអ្វីដែលបង្កឲ្យមានគ្រោះថ្នាក់»)។

**<u>ពិភាក្សានៅក្នុងក្រុមធំ</u>**

- តើមានអ្វីបានកើតឡើងនៅក្នុងរឿងនេះ?
- តើក្រុមជំនុំនោះមានទំហំប៉ុណ្ណា?
- តើសកម្មភាពរបស់ពួកគេជះឥទ្ធិពលយ៉ាងណាខ្លះ?

ជាប្រពៃណីនៅក្នុងភូមិមួយ នៅពេលដែលមានការប្រមូលផលដំណាំ គឺសមាជិកនៃសហគមន៍នឹងជួយគ្នាប្រមូលផលទៅវិញទៅមក។ ទោះជាយ៉ាងណាក៏ដោយ ម្ចាស់ស្រែដែលជួយប្រមូលផលត្រូវជួយផ្តល់អាហារ និងភេសជ្ជៈជាច្រើនរាល់ថ្ងៃដល់សហគមន៍ដែលជួយប្រមូលផល។ ជាអកុសល ថ្លៃនៃម្ហូបអាហារចំណាយអស់ច្រើន ដែលធ្វើឲ្យម្ចាស់ស្រែភាគច្រើនទទួលបានប្រាក់ចំណេញតិចពីការប្រមូលផល។

ក្រុមជំនុំបានសម្រេចចិត្តធ្វើសកម្មភាពនៃសេចក្តីស្រលាញ់ ដែលពួកគេនឹងជួយគ្រួសារក្រីក្រនៅក្នុងសហគមន៍ប្រមូលផលពីស្រែរបស់ពួកគេ ដោយមិនទាមទារអ្វីឡើយ។ ផ្ទុយទៅវិញ ពួកគេបែរជាយកអាហាររបស់ខ្លួនសម្រាប់បរិភោគនៅពេលថ្ងៃ មកជាមួយដោយខ្លួនឯងវិញ។ ខណៈពេលដែលសមាជិកសហគមន៍ផ្សេងទៀត ឃើញពីរបៀបដែលពួកជំនុំកំពុងបម្រើអ្នកក្រ ពួកគេក៏សម្រេចចិត្តថាពួកគេក៏គួរតែជួយអ្នកផ្សេងទៀតដោយមិនចាំបាច់ទាមទារអាហារ និងភេសជ្ជៈច្រើនដែរ។

សព្វថ្ងៃនេះ មនុស្សគ្រប់គ្នាជួយប្រមូលផលដំណាំគ្នាទៅវិញទៅមក។ មិនមាននរណាម្នាក់ចាំបាច់ត្រូវផ្តល់ស្រា ឬអាហារអ្វីទេ។ ប្រាក់ចំណេញដែលកសិករទទួលបានពីដីរបស់ខ្លួន បានកើតឡើងយ៉ាងគួរឲ្យកត់សម្គាល់ ហើយជាលទ្ធផល នៅពេលនេះពួកគេមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគពេញមួយឆ្នាំទៀតផង។

- តើក្រុមជំនុំបានធ្វើអ្វី ដើម្បីជួយទៅដល់សហគមន៍នេះ?
- តើអ្វីដែលជាឥទ្ធិពល? តើអ្វីជាផ្លាស់ប្រែទៅដល់សហគមន៍ទាំងមូល?

## ការពិភាក្សានៅក្នុងក្រុមតូច

- តើមានអ្វីខ្លះដែលក្រុមជំនុំរបស់យើងអាចធ្វើ ដើម្បីជួយបម្រើដល់សហគមន៍?
- តើក្រុមជំនុំអាចជួយបុគ្គលម្នាក់ៗឲ្យរស់នៅស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានដោយរបៀបណា?

### មេរៀនទី ៧

# កម្មវិធីផ្លាស់ប្រែសហគមន៍ ដោយផ្ដោតលើសេចក្ដីពិត

**គោលបំណង**

-  កម្មវិធីផ្លាស់ប្រែសហគមន៍ ដោយផ្ដោតលើសេចក្ដីពិត (The Truth Centered Transformation Program) គឺជាកម្មវិធីបំពាក់បំប៉នដល់ក្រុមជំនុំដើម្បីនាំការផ្លាស់ប្រែដល់សហគម៍របស់ពួកគេ។

រូបភាពជំនួយដល់ការសិក្សា៖

៥. និមិត្តរបស់គម្រោង

៦. រូបភាពអំពីក្រុមជំនុំផ្លាស់ប្រែដល់សហគមន៍

៧. ប្រធានបទបង្រៀននាពេលអនាគត

## សេចក្ដីផ្ដើម

សូមឲ្យអ្នកស្ម័គ្រចិត្តពីរនាក់ឈរទល់មុខគ្នានៅចុងម្ខាងៗនៃជ្រុងតុ។ សូមឲ្យពួកគេទាញតុក្នុងទិសដៅផ្ទុយគ្នា។ បន្ទាប់ពីមួយឬពីរនាទី សូមឲ្យពួកគេលើកតុនៅក្នុងទិសដៅដូចគ្នា។

-  តើមួយណាស្រួលជាង រវាងទិសដៅដូចគ្នា ឬក៏ទិសដៅផ្ទុយគ្នា?

នៅក្នុងមេរៀនពីរបីមុននេះ យើងបាននិយាយអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់។ បំណងចិត្តរបស់យើងក្នុងនាមជាអង្គភាពមួយ គឺដើម្បីជួយកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ។ និមិត្តរបស់យើងសម្រាប់កម្មវិធីនេះគឺ (លើកក្រដាសរូបភាព ឬសរសេរនៅលើក្ដាខៀន)៖

*បំពាក់បំប៉នក្រុមជំនុំដើម្បីផ្លាស់ប្រែសហគមន៍របស់ពួកគេ*

និមិត្តរបស់យើងគឺអ្វីដែលយើងចង់ឃើញជាលទ្ធផលនៃភាពជាដៃគូជាមួយអ្នក។ នៅពេលដែលអ្នកស្ដាប់ សូមគិតអំពីអ្វីមួយដែលអ្នកចង់ចូលរួម។ សូមចាំអំពីឧទាហរណ៍នៃតុដែលបានបង្ហាញមុននេះ។ តើវាងាយស្រួលនៅពេលណាជាង? គឺនៅពេលដែលមនុស្សដើរក្នុងទិសដៅដូចគ្នា។ តើវាដូចគ្នាជាមួយ

នឹងការចាប់ដៃគូជាមួយគ្នាដែរឬទេ? ប្រសិនបើយើងព្យាយាមសម្រេចគោលដៅផ្សេងគ្នា នោះយើងនឹងចាប់ផ្តើមអន់ចិត្តចំពោះគ្នាទៅវិញទៅមក។ យើងនឹងមិនមែនជាដៃគូល្អទេ។ ប្រសិនបើយើងយល់ស្របនឹងគោលដៅដូចគ្នានៃការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ នោះយើងទាំងអស់គ្នាកំពុងតែដើរនៅក្នុងទិសដៅដូចគ្នា។ យើងនឹងក្លាយជាដៃគូដ៏ល្អជាមួយគ្នា។

## និមិត្តរបស់គម្រោង

### បំពាក់បំប៉នក្រុមជំនុំដើម្បីផ្លាស់ប្រែសហគមន៍របស់ពួកគេ

**ការបំពាក់បំប៉នក្រុមជំនុំ**

ដូចដែលបានលើកឡើងនៅក្នុងមេរៀនមុនរបស់យើង ក្រុមជំនុំដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ក្រុមជំនុំជាអ្នកបន្តនូវនិមិត្ត និងបង្រៀន ហើយជួយគាំទ្រមនុស្សដែលធ្វើកិច្ចការ។ យើងមានបំណងចិត្តដើម្បីជួយក្រុមជំនុំឲ្យបំពេញតួនាទីរបស់ពួកគេ។ យើងមិនមែនព្យាយាមដណ្តើមយកពីក្រុមជំនុំ ឬក៏ដើរតួនាទីជំនួសក្រុមជំនុំទេ។ (បង្ហាញរូបទី៥)

ការបំពាក់បំប៉នក្រុមជំនុំ**មិនមែន**បានន័យថា៖

១. យើងមានគ្រប់ទាំងចម្លើយ៖ គ្រប់ផ្នែក និងគ្រប់ស្ថានភាពទាំងអស់គឺសុទ្ធតែខុសៗពីគ្នា។ យើងនឹងរៀនជាមួយគ្នា ពីរបៀបដែលល្អប្រសើរបំផុតដើម្បីជួយដល់សហគមន៍របស់អ្នក។

២. អ្នកខ្វះខាត ឬមិនមានសមត្ថភាព៖ យើងទាំងអស់គ្នាមានអំណោយទាន ជំនាញ និងសមត្ថភាពពិសេសៗផ្សេងគ្នា។ ចូរប្រើប្រាស់អ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានប្រទានមកឲ្យអ្នក អ្នកអាចផ្លាស់ប្រែសហគមន៍របស់អ្នកបាន។ យើងនឹងជួយផ្តល់គំនិត និងជំនាញដែលអ្នកត្រូវការ។

៣. យើងទាំងអស់គ្នាជាអ្នកគ្រប់គ្រងអ្វីដែលកើតឡើង៖ នេះគឺជាក្រុមជំនុំ និងសហគមន៍របស់អ្នក។ អ្នកដឹងច្បាស់បំផុតពីអ្វីដែលត្រូវធ្វើ។ ជាមួយគ្នានេះដែរ យើងសូមណែនាំអំពីសកម្មភាពនៃសេចក្តីស្រលាញ់ ហើយយើងក៏នឹងជួយណែនាំដែរ។ ទោះបីជាយ៉ាងណា ជាមួយសកម្មភាពនៃសេចក្តីស្រលាញ់ យើងមិនប្រាប់អ្នកពីអ្វីត្រង់ៗ ដែលត្រូវធ្វើនោះទេ។ អ្នកជាអ្នកសម្រេចចិត្តថាគម្រោងមួយណាដែលល្អប្រសើរសម្រាប់តំបន់របស់អ្នក។

៤. (ចំណុចនេះ នឹងមិនសមរម្យសម្រាប់គ្រប់ទីកន្លែងនោះទេ ឬក៏អាចរំលងក៏បានដែរ) យើងចាប់ផ្តើមនិកាយមួយ ឬក៏ចង់ផ្លាស់ប្តូរនិកាយ។ ផ្ទុយទៅវិញវាជាការពិត។ យើងជឿថា

អ្នកមិនគួរផ្លាស់ប្ដូរនិកាយ ឬប្រឆាំងជាមួយនឹងអ្នកដឹកនាំរបស់អ្នកឡើយ។ សូមមើលពីរបៀបដែលដាវីឌបានប្រព្រឹត្តចំពោះសូលៈ ដាវីឌនៅតែបន្តលេងពិណឲ្យសូល ទោះបីជាព្រះបាទសូលបានគប់លំពែងទៅខ្លួនក៏ដោយ។ នៅពេលដែលគាត់កំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ស្ទើរតែនឹងបាត់បង់ជីវិតទៅហើយ រួចគាត់ក៏ចេញទៅដោយខ្លួនឯង។ គាត់មិនបានព្យាយាម ចង់ដណ្ដើមតំណែងរបស់ស្ដេចសូល ឬសូមឲ្យមនុស្សផ្សេងទៀតចាកចេញដែរ ទោះបីជាព្រះជាម្ចាស់បានសន្យានឹងគាត់ថា គាត់នឹងក្លាយទៅជាស្ដេចនាពេលអនាគតក្ដី។ នៅពេលដែលគាត់មានឱកាស គាត់ក៏អាចសម្លាប់សូលដែរ ប៉ុន្តែគាត់ឲ្យសូលនៅរស់រានមានជីវិតទៅវិញ។

យើងបានលើកទឹកចិត្តមនុស្សឲ្យធ្វើតាមគំរូរបស់ដាវីឌ។ ទោះបីជាអ្នកគិតថាអ្នកដឹកនាំរបស់អ្នកមិនល្អក៏ដោយ អ្នកក៏គួរតែនៅបន្តបម្រើគាត់ និងអធិស្ឋានដល់គាត់។ ប្រសិនបើអ្វីៗកាន់តែយ៉ាប់ទៅៗ នោះអ្នកអាចចាកចេញបានដោយខ្លួនឯង។ កុំនាំអ្នកដទៃទៅជាមួយលើកលែងតែ ប្រពន្ធនិងកូនរបស់អ្នក។ កុំព្យាយាមវាយប្រហារអ្នកដឹកនាំមុនរបស់អ្នក។ ដូចដាវីឌ យើងគួរតែគោរពកោតខ្លាចទោះបីជាក្នុងការនិយាយប្រឆាំងនឹងអ្នកដឹកនាំក៏ដោយ។

ក្នុងនាមជាអ្នកដឹកនាំនៅក្នុងអង្គភាពនេះ យើងពិតជាខកចិត្តខ្លាំងណាស់ពីរបៀបដែលក្រុមជំនុំមួយចំនួន និងអ្នកដឹកនាំឆាប់ផ្លាស់ប្ដូរនិកាយ។ យើងជឿថា ការនេះមិនបានថ្វាយព្រះកិត្តិយសដល់ព្រះជាម្ចាស់ទេ។ យើងពិតជាមិនចង់ឲ្យអ្នកផ្លាស់ប្ដូរនិកាយឡើយ។ សមាជិកនៃក្រុមអ្នកដឹកនាំរបស់យើង កាន់និកាយខុសៗគ្នា។ យើងចង់ឃើញក្រុមជំនុំទាំងអស់គោរពទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ យើងជឿថាព្រះជាម្ចាស់អាចកសាងព្រះរាជ្យរបស់ទ្រង់តាមរយៈនិកាយទាំងអស់។

**អត្ថន័យរបស់វាៈ**

១. យើងនឹងបង្ខំកបង្អាក់អ្នកដើម្បីផ្លាស់ប្រែសហគមន៍របស់អ្នក។ យើងនឹងមិនបញ្ជូនបុគ្គលិករបស់យើងទៅសហគមន៍របស់អ្នក ហើយផ្លាស់ប្រែសហគមន៍របស់អ្នកទេ។ យើងជឿថា ក្រុមជំនុំគឺឧបករណ៍របស់ព្រះជាម្ចាស់ ដើម្បីនាំការផ្សះផ្សា ដូច្នេះបានជាយើងចង់ជួយ និងគាំទ្រដល់អ្នក នៅពេលដែលអ្នកធ្វើតាមព្រះបំណងរបស់ទ្រង់តាមរបៀបនេះ។

២. វាជានិមិត្ត និងផែនការរបស់អ្នក។ យើងនឹងណែនាំគំនិតជាច្រើនទៀត ប៉ុន្តែវាអាស្រ័យទៅលើអ្នកផ្ទាល់ ថាតើអ្នកនឹងយកគំនិត និងផែនការមួយណាទៅអនុវត្តនៅក្នុងក្រុមជំនុំរបស់អ្នក។ អ្នកមិនត្រូវបានបង្ខំឲ្យធ្វើវាទេ ប្រសិនបើអ្នកយកចិត្តទុកដាក់ចង់ឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់ត្រូវបានកសាងនៅក្នុងសហគមន៍របស់អ្នក នោះយើងលើកទឹកចិត្តអ្នកឲ្យអនុវត្តវាកាន់តែច្រើនតាមដែលអាចធ្វើបាន។

នៅពេលដែលយើងបានចុះសួរសុខទុក្ខនៅក្នុងកម្មវិធីនេះ យើងបានឃើញថា អ្នកដែលបានអនុវត្តកាន់តែច្រើន គេនឹងឃើញមានការផ្លាស់ប្រែកាន់តែខ្លាំងនៅក្នុងសហគមន៍របស់ពួកគេ។ រីឯអ្នកណាធ្វើបានតែបន្តិចបន្តួច គេឃើញមានការផ្លាស់ប្រែតែបន្តិចបន្តួចដែរ។ វាអាស្រ័យទៅអ្នក និងអ្វីដែលអ្នកប្រាថ្នា។ ការដែលធ្វើឲ្យសហគមន៍របស់អ្នកផ្លាស់ប្រែ ត្រូវការការខិតខំប្រឹងប្រែងជាខ្លាំង។




## ការផ្លាស់ប្រែសហគមន៍

ផ្នែកដំបូងនៃនិមិត្តរបស់យើងគឺដើម្បីបំពាក់បំប៉នក្រុមជំនុំ។ នៅផ្នែកបន្ទាប់គឺជាអ្វីដែលយើងកំពុងតែបំពាក់បំប៉នឲ្យក្រុមជំនុំធ្វើ៖ ផ្លាស់ប្រែសហគមន៍របស់ពួកគេ។

ការផ្លាស់ប្រែ៖

- តើអ្នកគិតថា ហេតុអ្វីបានជាយើងប្រើប្រាស់ពាក្យ ផ្លាស់ប្រែ នេះ? តើពាក្យផ្លាស់ប្រែនេះ មានអត្ថន័យយ៉ាងណា?

នៅពេលដែលមានអ្វីមួយផ្លាស់ប្រែ មានន័យថាវាត្រូវបានផ្លាស់ប្តូរទាំងស្រុងក្នុងរបៀបដែលវាមិនអាចត្រឡប់មកក្រោយវិញបាន។ ឧទាហរណ៍ សូមគិតពីដង្កូវមេអំបៅ និងមេអំបៅ។ ដង្កូវមេអំបៅផ្លាស់ប្រែទៅជាមេអំបៅ។ វាមិនអាចត្រឡប់ទៅជាដង្កូវវិញទេ។ វាជាផ្លាស់ប្តូរទាំងស្រុង ហើយមិនអាចត្រឡប់ទៅជាដង្កូវវិញបានទេ។ យើងក៏ចង់ឃើញការផ្លាស់ប្រែនៅក្នុងសហគមន៍។ យើងចង់ឃើញសហគមន៍ដែល

បានផ្លាស់ប្រែទាំងស្រុង ដើម្បីរស់នៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយមិនចង់ត្រឡប់ទៅអតីតកាល កាលពីពីរបីឆ្នាំមុនទៀតទេ។

## ផ្នែកនៃការផ្លាស់ប្រែ

### <u>នៅក្នុងក្រុមតូច</u>

សូមឲ្យក្រុមនីមួយៗគិតអំពីការផ្លាស់ប្រែណា ដែលពួកគេចង់ឃើញនៅក្នុងសហគមន៍របស់ពួកគេ នៅខាងក្រោមប្រធានបទនីមួយៗ ដូចជាវិញ្ញាណ សង្គម ប្រាជ្ញា និងរូបកាយ និងជាលទ្ធផលនៃកម្មវិធីនេះផងដែរ។ សូមរំឭកទៅកាន់ក្រុមថា សង្គមគឺជាអ្វីដែលទាក់ទងទៅនឹងទំនាក់ទំនងរបស់យើង ឧទាហរណ៍៖ អាពាហ៍ពិពាហ៍ លក្ខណៈជាឪពុកម្តាយ ទំនាក់ទំនងរវាងអ្នកជិតខាង សាមគ្គីភាព -ល-។ រូបកាយរួមបញ្ចូលដូចជា លុយ ការងារ សុខភាព -ល-។ ពួកគេក៏អាចនិយាយពីគំនិតផ្សេងៗដែលមាននៅក្នុងមេរៀនទី១ ក៏បានដែរ។

នៅពេលក្រុមទាំងអស់បានបញ្ចប់ សូមឲ្យក្រុមនីមួយៗឡើងធ្វើបទបង្ហាញ។ តើមានអ្វី ដែលក្រុមនីមួយៗបានសរសេរច្រើនជាងគេដែរឬទេ? តើនោះជាអ្វី?

ចូរគូសតារាងខាងក្រោមដាក់នៅលើក្តារខៀន។ សូមឲ្យក្រុមនីមួយ មើលទៅលើប្រធានបទនីមួយៗនៅខាងក្រោមប្រធានបទ សង្គម ប្រាជ្ញា រូបកាយ និងវិញ្ញាណ។ ចូរមើលទៅលើប្រធានបទនីមួយៗហើយពិភាក្សាពីសំណួរទាំងពីរនេះ សម្រាប់ប្រធានបទនីមួយៗ។




<u>**ការពិភាក្សានៅក្នុងក្រុមធំ**</u>

- តើគោលដៅដែលអ្នកបានបង្កើត និងគោលដៅដែលយើងបានលើកយកមកបង្ហាញនេះ មានលក្ខណៈខុសគ្នាបែបណាខ្លះ?
- តើមានគោលដៅណាខ្លះដែលយើងបានលើកឡើងនេះ ដែលធ្វើឲ្យអ្នកភ្ញាក់ផ្អើល ហើយគោលដៅណាដែលអ្នកមិនយល់ស្របជាមួយ?

នៅពេលដែលអ្នកបានមើលទៅលើផ្នែកទាំងបួននេះ ចូរពិភាក្សា៖

- នៅពេលដែលអ្នកបានបញ្ជីនៃគោលដៅទាំងពីរនេះ តើអ្នកគិតថាមានភាពប្រហាក់ប្រហែលគ្នាគ្រប់គ្រាន់ ដើម្បីឲ្យយើងធ្វើការជាមួយគ្នាដែរឬទេ?

## វិធីសាស្ត្រ

នេះគឺជាកម្មវិធីបណ្ដុះបណ្ដាល។ យើងមិនឲ្យលុយទៅកាន់ក្រុមជំនុំដើម្បីអនុវត្តកម្មវិធីទេ។ នៅពេលដែលយើងរៀនក្នុងវគ្គបណ្ដុះបណ្ដាលបន្ទាប់ យើងនឹងឃើញថា មូលហេតុជាច្រើនដែលធ្វើឲ្យយើងក្រ

នោះគឺមិនមែនដោយសារតែយើងខ្វះខាតធនធានទេ។ ហើយវិធីសាស្ត្រដែលយើងចាកចេញពីភាពក្រីក្រនោះ ក៏មិនមែនដោយសារតែការទទួលបានធនធានដែរ។ ប្រសិនបើយើងមើលទៅជីវិតរបស់ព្រះយេស៊ូទ្រង់មិនដែលបានផ្តល់ជារបស់ទ្រព្យអ្វីដែរ។ ដូចដែលលោកពេត្រុសបាននិយាយនៅក្នុងគម្ពីរកិច្ចការ ៣៖៦ថា «ខ្ញុំគ្មានប្រាក់ គ្មានមាសទេ តែអ្វីៗដែលខ្ញុំមាន ខ្ញុំសុំជូនអ្នកដូច្នេះក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត»។ ចំពោះករណីរបស់យើង អ្វីដែលយើងមានដើម្បីផ្តល់ឲ្យនោះគឺជាចំណេះដឹង និងគំនិតដែលយើងជឿថាវានឹងជួយដល់សហគមន៍របស់អ្នក ឲ្យកាន់តែខិតទៅជិតបំណងព្រះហឫទ័យដែលព្រះជាម្ចាស់មានសម្រាប់អ្នក។ យើងជឿថាវគ្គបណ្តុះបណ្តាលនេះ បូករួមទាំងការលះបង់ និងការខិតខំប្រឹងប្រែងរបស់អ្នករួមទាំងអំណាចដ៏អស្ចារ្យដែលមកពីព្រះជាម្ចាស់ នឹងនាំការផ្លាស់ប្រែមកដល់ប្រទេសជាតិរបស់យើង។

យើងផ្តល់ជូននូវការបណ្តុះបណ្តាលនេះទៅកាន់មនុស្សគ្រប់គ្នានៅក្នុងក្រុមជំនុំ ដើម្បីជួយអ្នកឲ្យមានគំនិត និងជំនាញដែលអ្នកត្រូវការដើម្បីជួយនាំការផ្លាស់ប្រែទៅកាន់សហគមន៍របស់អ្នក។

## ប្រធានបទសម្រាប់វគ្គបណ្តុះបណ្តាលនាពេលអនាគត

ចូរលើកផ្ទាំងរូបភាពនិយាយអំពីចំណងជើងមេរៀនរបស់យើង នៅវគ្គបណ្តុះបណ្តាលបន្ទាប់។ សូមពន្យល់ពីប្រធានបទទាំងអស់ដែលយើងមានគម្រោងនឹងបង្រៀន ទោះបីជាមានការផ្លាស់ប្តូរក៏ដោយ។

ជំពូកទី៣៖ របៀបដែលសេចក្តីកុហករបស់សាតាំង ជះឥទ្ធិពលលើយើង និងរបៀបយកឈ្នះលើវា
ជំពូកទី៤៖ សុខភាព
ជំពូកទី៥៖ អាពាហ៍ពិពាហ៍ និងគ្រួសារ
ជំពូកទី៦៖ ការគ្រប់គ្រងលុយកាក់
ជំពូកទី៧៖ អំបិល និងពន្លឺ
ជំពូកទី៨៖ កសិកម្ម
ជំពូកទី៩៖ ការផ្សាយដំណឹងល្អ
ជំពូកទី១០៖ ការរស់នៅតាមគោលបំណងព្រះជាម្ចាស់

ប្រធានបទមួយចំនួន ដូចជា សុខភាព អាពាហ៍ពិពាហ៍ និងគ្រួសារ កសិកម្ម និងការគ្រប់គ្រងលុយកាក់ មានរួមបញ្ចូលទាំងការបណ្តុះបណ្តាលនៅក្នុងក្រុមតូច ដែលយើងអាចធ្វើវាបានជាមួយពួកជំនុំ និងសហគមន៍ដែលមិនបានមកចូលរួមវគ្គនេះ។ យើងនឹងផ្តល់ឲ្យអ្នកនូវគំនិតផ្សេងៗទៀត ដើម្បីឲ្យអ្នកយកទៅអនុវត្ត។

# មេរៀនទី ៨

# ជំហានបន្ទាប់

**គោលបំណង**

- យើងត្រូវតែរៀបចំផែនការ និងមានចេតនាជាក់លាក់អំពីកិច្ចការដែលយើងធ្វើ។

មេរៀន

៨.១ ជំហានផែនការនៃសកម្មភាពនៃសេចក្តីស្រលាញ់

## ហេតុផលដែលការរៀបចំផែនការសំខាន់

លោកលីមគឺជាកសិករម្នាក់ ដែលបានចេញទៅរៀបចំដីមួយកន្លែងរបស់លោកដើម្បីដាំដំណាំ ប៉ុន្តែនៅតាមផ្លូវលោកបានចាំថា ប្រពន្ធឲ្យរបស់គាត់បានប្រាប់ឲ្យគាត់ឲ្យដាក់ចំណីមាន់ ដូច្នេះគាត់ក៏ត្រឡប់ទៅផ្ទះវិញហើយឲ្យចំណីមាន់។ នៅពេលដែលគាត់កំពុងតែឲ្យចំណីមាន់ គាត់ក៏បានមើលទៅឯក្រោលពពែហើយឃើញថាក្រោលបានបាក់។ គាត់ព្រួយបារម្ភថា ប្រសិនបើមិនជួសជុលវាភ្លាមៗទេ នោះនឹងមានសត្វពពែរត់ចេញមិនខាន។ គាត់ក៏ត្រឡប់ទៅផ្ទះ ដើម្បីស្វែងរកលួសយកទៅជួសជុលទ្រុងពពែ។ ដោយសារតែគាត់មិនមានសម្ភារៈគ្រប់គ្រាន់ គាត់ក៏បានទៅផ្ទះអ្នកជិតខាងដែលមានឈ្មោះថាលោក សាន់ ហើយបានសុំខ្ចីឧបករណ៍មួយចំនួនពីគាត់។ ដោយសារតែគាត់បានទៅលេងនៅទីនោះ គាត់ក៏សម្រេចចិត្តចំណាយពេលពីរបីនាទីបន្ថែម ដើម្បីនិយាយជាមួយលោក សាន់ ដែលជាអ្នកទើបនឹងជឿថ្មីនៅក្នុងក្រុមជំនុំ ទាំងដឹងថាគាត់កំពុងតែមានទុក្ខលំបាក។

នៅម៉ោង ១១៖៣០ព្រឹក ប្រពន្ធរបស់គាត់បានអញ្ជើញគាត់ឲ្យនៅពិសាបាយថ្ងៃត្រង់នៅទីនោះជាមួយគ្នា។ គាត់ដឹងថាគាត់បានចំណាយពេលនៅទីនោះរៀងយូរដែរហើយ គាត់ក៏បានសុំទោស ហើយត្រឡប់មកផ្ទះវិញយ៉ាងលឿនដើម្បីទទួលទានអាហារថ្ងៃត្រង់ជាមួយគ្រួសាររបស់គាត់។ បន្ទាប់ពីសម្រាកថ្ងៃត្រង់បានបន្តិច គាត់ក៏ទៅធ្វើបង្ហើយទ្រុងពពែរបស់គាត់។ នៅពេលដែលគាត់កំពុងធ្វើការ ប្រពន្ធរបស់គាត់បានរំឭកគាត់ថា ម៉ាស៊ីនបូមទឹកនៅលើអណ្តូងក៏ខូចដែរ ឲ្យគាត់ជួយមើលផងទាន់នៅមានសម្ភារៈប្រើប្រាស់របស់លោកសាន់។ នៅថ្ងៃរៀបលិច គាត់ធ្វើម៉ាស៊ីនបូមទឹកជិតហើយ។ ប៉ុន្តែ គាត់មិនទាន់បានទៅស្រែនៅឡើយទេ ប៉ុន្តែគាត់មានអារម្មណ៍ថា ថាគាត់នឹងត្រូវធ្វើបង្ហើយម៉ាស៊ីនបូមទឹកនៅព្រឹកស្អែក ហើយត្រូវសងឧបករណ៍ទៅគេវិញ ទើបគាត់អាចចាប់ផ្តើមការងារនៅស្រែបាន។

១. តើមានរឿងអ្វីកើតឡើងនៅក្នុងរឿងនេះ?
២. តើអ្វីៗដែលគាត់ធ្វើជាអ្វីដែលអាក្រក់ ឬជាអ្វីដែលចាំបាច់?
៣. តើនៅចុងបញ្ចប់នឹងមានលទ្ធផលបែបណា ប្រសិនបើកសិករម្នាក់នេះនៅតែបន្តគ្រប់គ្រងកសិដ្ឋានរបស់គាត់បែបនេះ ហើយមិនបានបញ្ចប់ការងារជាំដុះរបស់គាត់?
៤. តើអ្នកធ្លាប់មានថ្ងៃបែបនេះដែរឬទេ?
៥. តើយើងអាចប្រាកដថា រឿងនេះនឹងមិនអាចកើតឡើងចំពោះយើងបានដោយរបៀបណា?

មានគម្រោងជាច្រើនដែលមានលក្ខណៈដូចជាថ្ងៃរបស់កសិករម្នាក់នេះអញ្ចឹង។ យើងរវល់តែធ្វើកិច្ចការល្អៗ ដោយដោះស្រាយបញ្ហាមួយហើយមួយទៀត ហើយពេលខ្លះរឿងដែលសំខាន់ជាងគេ យើងមិនបានធ្វើទៅវិញ ដោយសារតែយើងត្រូវធ្វើកិច្ចការបន្ទាន់បែបនេះ។ ជាលទ្ធផល យើងបរាជ័យក្នុងការសម្រេចបាននូវកិច្ចការដ៏សំខាន់បំផុតនៅក្នុងជីវិត។ អ្វីដែលគួរឲ្យព្រួយបារម្ភបន្ថែមទៀត ជីវិតរបស់មនុស្សមួយចំនួន គឺដូចជាជីវិតកសិករម្នាក់នេះអញ្ចឹង។ យើងពិតជារវល់តែពីរឿងមួយទៅរឿងមួយ ដោយមិនបានចំណាយពេលវេលាគិតថាមួយណាសំខាន់ជាង ហើយធ្វើវានោះទេ។ រឿងដំបូងដែលយើងសម្រេចត្រូវធ្វើនោះ គឺអ្វីមួយដែលសំខាន់។ ប្រសិនបើយើងដឹងពីសារៈសំខាន់របស់វា នោះវានឹងជួយយើងឲ្យសម្រេចចិត្តបានត្រឹមត្រូវអំពីរបៀបចំណាយពេលវេលារបស់យើង។

តើអ្នកគិតថា មានកិច្ចការសំខាន់ៗណាខ្លះដែលអ្នកចាំបាច់ត្រូវធ្វើនៅក្នុងរយៈពេល៣ខែ ដើម្បីទទួលបានជោគជ័យ?

- ការបង្រៀនអ្នកដទៃ៖ ប្រសិនបើយើងចង់ឲ្យសរីរាង្គជាច្រើនទៀតនៃព្រះកាយ (របស់ព្រះគ្រិស្ត) បម្រើ យើងត្រូវតែបង្រៀនមេរៀនមួយចំនួន ដែលយើងបានរៀនរួចហើយ។
- ការសម្របសម្រួលសកម្មភាពនៃសេចក្តីស្រលាញ់៖ យើងត្រូវតែបន្តធ្វើសកម្មភាពនៃសេចក្តីស្រលាញ់ នៅក្នុងលក្ខណៈជាទៀងទាត់មួយ។
- ជួបជុំគ្នាជាប្រចាំ។

## ការជួបជុំ

អ្នកត្រូវតែជ្រើសរើសក្រុមដើម្បីជួបជុំគ្នាជាប្រចាំ ក្នុងការរៀបចំផែនការធ្វើសកម្មភាពនៃសេចក្តីស្រលាញ់។ ជាទូទៅ នេះជាក្រុមគណៈកម្មការក្រុមជំនុំ ហើយអាចជួបជុំនៅក្នុងការប្រជុំរបស់គណៈកម្មការ ប្រសិនបើគណៈកម្មការក្រុមជំនុំ បានជួបជុំគ្នាពីរបីដងក្នុង១ខែហើយ។

- តើអ្នកត្រូវធ្វើអ្វីខ្លះ នៅពេលដែលអ្នកជួបជុំគ្នា?
    - អធិស្ឋាន៖ គឺមានតែកម្លាំងដែលមកពីព្រះជាម្ចាស់ទេ ទើបយើងអាចឃើញសហគមន៍របស់យើងផ្លាស់ប្រែ។ យើងត្រូវតែចំណាយពេលជាមួយគ្នាអធិស្ឋាន ប្រសិនបើយើងពិតជាចង់ឃើញការផ្លាស់ប្រែមែន។
    - ធ្វើសេចក្តីសម្រេចចិត្តអំពីសកម្មភាពនៃសេចក្តីស្រលាញ់ថ្មី
    - គិតអំពីគំនិតផ្សេងៗ ដើម្បីអ្វីដែលអ្នកអាចធ្វើបានក្នុងការជួយដល់សហគមន៍របស់អ្នក។

នៅក្នុងពេលប្រជុំ អ្នកគួរតែចំណាយពេលដើម្បីអធិស្ឋាន និងពិភាក្សាអំពីអ្វីដែលសហគមន៍ត្រូវការ។ ចូរអធិស្ឋានពីរបៀបដែលយើងគួរជួយ។ បន្ថែមលើសពីនេះ អ្នកគួរតែចំណាយពេលខ្លះ ដើម្បីពិនិត្យទៅលើសកម្មភាពនៃសេចក្តីស្រលាញ់ និងគិតអំពីអ្វីដែលដំណើរការល្អ និងអ្វីដែលមិនទាន់ដំណើរការល្អ។ ចូរសួរខ្លួនឯងពីអ្វីដែលអ្នកអាចធ្វើបានខុសប្លែកពីលើកមុន នៅពេលក្រោយទៀត។

## សកម្មភាពនៃសេចក្តីស្រលាញ់

សូមមើលទៅលើរូបភាពនៃសហគមន៍របស់អ្នក ដែលអ្នកបានធ្វើនៅក្នុងមេរៀនទី១។

ដោយមើលគ្រប់រូបភាពទាំងអស់ ចូរធ្វើបញ្ជីពីអ្វីដែលត្រូវផ្លាស់ប្រែធំៗ ដើម្បីឲ្យរូបភាពនីមួយក្លាយទៅជាការពិត។

នៅក្នុងក្រុម ចូរអធិស្ឋានអំពីរបៀបដែលអ្នកអាចចាប់ផ្តើមធ្វើអ្វីមួយ ដើម្បីឲ្យការផ្លាស់ប្រែនេះក្លាយជាការពិត។ ចូរជ្រើសរើសការផ្លាស់ប្រែមួយ ហើយរៀបចំផែនការជាមួយគ្នា ពីសកម្មភាពនៃសេចក្តីស្រលាញ់ ដើម្បីនាំការផ្លាស់ប្រែពីការនេះ។

សូមរំឭកពីទម្រង់ផែនការ សកម្មភាពនៃសេចក្តីស្រលាញ់ (ទំព័របន្ទាប់) និងរៀបចំផែនការមួយ។

## ជំហាននៃការរៀបចំផែនការ សកម្មភាពនៃសេចក្តីស្រលាញ់

### ជំហានទី១៖ អធិស្ឋាន

រឿងដំបូងដែលត្រូវធ្វើមុនគេគឺអធិស្ឋាន។ ឥឡូវ សូមចំណាយពេលអធិស្ឋាន។ ចូរទូលសុំឲ្យព្រះជាម្ចាស់បង្ហាញពីអ្វីដែលអ្នកគួរធ្វើ សម្រាប់សកម្មភាពនៃសេចក្តីស្រលាញ់។

### ជំហានទី២៖ ជ្រើសយកសកម្មភាពមួយ

ចូរសម្រេចចិត្តជាក្រុម ដោយជ្រើសរើសសកម្មភាពមួយដែលយើងអាចធ្វើ ជាសកម្មភាពនៃសេចក្តីស្រលាញ់។ ចូរស្រង់យកគំនិតខ្លះៗពីមេរៀនទី១ រួចសម្រេចយកមតិរួមគ្នា ក្នុងការធ្វើនូវអ្វីដែលអ្នកមានអារម្មណ៍ថា ព្រះជាម្ចាស់កំពុងដឹកនាំឲ្យអ្នកធ្វើ។

នៅពេលអ្នកសម្រេចយកប្រធានបទណាមួយហើយ ត្រូវឲ្យប្រាកដថា វាជាប្រធានបទដែលអ្នកអាចធ្វើបានជោគជ័យក្នុងរយៈពេលមួយ ឬពីរថ្ងៃ។ ប្រសិនបើមិនដូច្នោះទេ តើអ្នកអាចធ្វើវាមួយជំហាន ឬពីរជំហានសិនបានដែរឬទេ ?

### ជំហានទី៣៖ សម្រេចចិត្តពីអ្វីដែលត្រូវការ

ជំហានបន្ទាប់មកទៀតគឺត្រូវចាប់ផ្តើមរៀបចំផែនការតែម្តង។ ជាដំបូងយើងត្រូវសម្រេចចិត្តមើលថា យើងចាំបាច់ត្រូវការអ្វីខ្លះដើម្បីអនុវត្តន៍គម្រោង ដែលក្នុងនោះរួមមានដូចជា តើត្រូវការមនុស្សប៉ុន្មាននាក់ សម្ភារៈអ្វីខ្លះ និងត្រូវសុំការអនុញ្ញាតិពីនរណាខ្លះជាដើម។ ដើម្បីជួយឲ្យអ្នកគិតបានច្បាស់លាស់ អ្នកអាចប្រើក្រដាសលំហាត់នៅក្នុងសៀវភៅសិស្ស។ ពេលអ្នកសរសេរបំពេញពីអ្វីដែលអ្នកត្រូវការនៅក្នុងតារាងរួចហើយ អ្នកអាចសម្រេចចិត្តថា តើនរណាគួរតែជាអ្នកទទួលខុសត្រូវ និងត្រូវចាប់ផ្តើមអនុវត្តន៍គម្រោងនោះនៅពេលណា។

### ជំហានទី៤៖ សរសេរពីផែនការ

នៅពេលដែលអ្នកបានរៀបចំអ្វីៗដែលត្រូវធ្វើ អ្នកអាចសរសេរពីកាលបរិច្ឆេទតាមលំដាប់លំដោយ ដើម្បីដឹងថាអ្នកណាទទួលខុសត្រូវលើកិច្ចការណាមួយនៅថ្ងៃនោះ។ ចូរជ្រើសរើសមនុស្សម្នាក់ធ្វើជាប្រធានគម្រោង។ ម្នាក់នោះ គឺអ្នកដែលទទួលខុសត្រូវក្នុងការទាក់ទងមនុស្សនៅថ្ងៃនោះ មុនមួយថ្ងៃដើម្បីឲ្យពួកគេអាចបញ្ជាប់កិច្ចការរបស់ពួកគេ ដើម្បីអាចសម្រេចការងារនោះបាន ឬក៏មានបញ្ហាអ្វី ហើយតើពួកគេត្រូវការជំនួយដែរឬទេ។

### ជំហានទី៥៖ អធិស្ឋាន

នៅពេលសរសេរផែនការចប់សព្វគ្រប់ហើយ អ្នកត្រូវចំណាយពេលអធិស្ឋានម្តងទៀត។ ចូរទូលសុំឲ្យព្រះជាម្ចាស់ជួយអ្នកឲ្យសម្រេចបានលើគម្រោងនោះ និងបង្កើនផលផ្លែឲ្យបានច្រើន។ អធិស្ឋានថាព្រះ

នាមទ្រង់នឹងត្រូវបានទទួលសិរីរុងរឿង។ ក្នុងអំឡុងពេល ១ ឬ ២ សប្តាហ៍ក្រោយមកទៀត នៅពេលកំពុងរៀបចំគម្រោង អ្នកគួរតែបន្តអធិស្ឋានដើម្បីឲ្យព្រះជាម្ចាស់ជួយអ្នកជាមួយគម្រោងនោះ។

**ជំហានទី៦៖ អនុវត្តន៍គម្រោង**

ជំហានបន្ទាប់ គឺត្រូវអនុវត្តនូវគម្រោងដែលអ្នកបានធ្វើផែនការរួច។ ត្រូវចាប់ផ្តើមអនុវត្តន៍ដោយការអធិស្ឋាន និងថ្វាយរាល់ការខិតខំប្រឹងប្រែងទៅកាន់ព្រះជាម្ចាស់។ ត្រូវចងចាំថា មូលហេតុដែលអ្នកធ្វើគម្រោងនេះ គឺដើម្បីបង្ហាញពីក្តីស្រលាញ់របស់ព្រះជាម្ចាស់ដល់សហគមន៍របស់អ្នក។ ហើយត្រូវរក្សាចិត្តគំនិតដែលស្របនឹងគោលបំណងនេះ។

**ជំហានទី៧៖ ត្រូវវាយតម្លៃ និងរាយការណ៍ពីគម្រោង**

ជំហានចុងក្រោយបង្អស់គឺត្រូវវាយតម្លៃ និងរាយការណ៍ពីគម្រោង។ ហេតុអ្វីបានជាយើងត្រូវវាយតម្លៃ? ដោយសារវាជួយឲ្យយើងរៀនបានបន្ថែមទៀត។ យើងអាចគិតអំពីអ្វីដែលយើងធ្វើបានល្អប្រសើរ និងអ្វីដែលយើងអាចកែប្រែសម្រាប់គម្រោងក្រោយៗទៀត។ អ្នកមិនចាំបាច់ត្រូវចំណាយពេលវេលាច្រើន ដើម្បីវាយតម្លៃនោះទេ គឺអ្នកអាចចំណាយពេលត្រឹមតែ ២ ទៅ ៣នាទីដើម្បីពិភាក្សាសំណួរខាងក្រោមជាការស្រេច៖

- តើអ្វីខ្លះដែលដំណើរការបានល្អ?
- តើអ្វីខ្លះដែលដំណើរការមិនបានល្អ?
- តើគម្រោងនេះត្រូវការការកែប្រែអ្វីខ្លះ?
- តើលទ្ធផលដូចតាមបំណងដែលបានគិតទុកដែរឬទេ? បើមិនដូច តើមកពីមូលហេតុអ្វី?
- តើព្រះជាម្ចាស់ទទួលបានសិរីរុងរឿងដែរឬទេ?

គ្រូបណ្តុះបណ្តាលមានទម្រង់របាយការណ៍គម្រូសម្រាប់សិស្ស។ ហេតុអ្វីបានជាយើងត្រូវធ្វើរបាយការណ៍? នៅក្នុងគម្ពីរ ម៉ាកុស ៦៖៣០ បានចែងថា ពួកសាវ័ករបស់ព្រះយេស៊ូបានរាយការណ៍ប្រាប់ព្រះអង្គគ្រប់សកម្មភាពទាំងអស់ដែលគេបានធ្វើ។ យើងធ្វើរបាយការណ៍ដើម្បីបង្ហាញពីភាពស្មោះត្រង់ និងការដឹងគុណដល់អ្នកដែលបានបង្រៀន និងរៀបចំសម្ភារៈ និងផ្តល់គ្រូបណ្តុះបណ្តាលដល់យើង។ ការរាយការណ៍ផ្តល់ឱកាសឲ្យអ្នកចែកចាយពីអ្វីដែលអ្នកបានធ្វើ ក៏ដូចជាចែកចាយពីទីបន្ទាល់នូវអ្វីដែលព្រះជាម្ចាស់បានប្រើប្រាស់អ្នកក្នុងគម្រោងនោះ។ ម្យ៉ាងវិញទៀត វាក៏ផ្តល់ឱកាសដល់គ្រូបណ្តុះបណ្តាលឲ្យឃើញពីបញ្ហា និងស្វែងរកមធ្យោបាយដើម្បីកែតម្រូវឲ្យកាន់តែប្រសើរឡើងពេលអនាគត។